# សង្គីតិកថា

ឧបត្ថម្ភការសិក្សាធម្មវិន័យ ថ្នាក់ទោ




ផ្សាយចេញអំពី

**បណ្ណាគារពេត្ររតន៍**

គ.ស. ២០០៤ ព.ស. ២៥៤៧

# សង្គីតិកថា

ទទួលអំណោយពីលោក ឡៅ ឈុនស៊ីវង់ ដល់ការាការខ្មែរ
ដើម្បីទុកដាក់ក្នុង elibrary of cambodia
៧ កក 2015

បណ្ឌិត **ឱម ណាគ្រី**
រៀបរៀង

បោះពុម្ពឡើងវិញ លើកទី ២ ចំនួន ៣០០០ ច្បាប់
តាមច្បាប់បោះពុម្ពលើកទី ១ ក្នុងឆ្នាំ ១៩៤៤



ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
គ.ស. ២០០១

# SANGITIKATHA

by

Pandit OM NAKRI

2nd Edition 3000 copies

PHNOM PENH
Published by Buddhist Institute
2001

# សេចក្តីបញ្ជាក់
# ចំពោះការបោះពុម្ពឡើងវិញ

---

សៀវភៅ " **សង្គីតិកថា** " នេះ ត្រូវបានបោះពុម្ពឡើងវិញ ក្រោមជំនួយឧបត្ថម្ភរបស់ក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព នៃប្រទេសជប៉ុន (WCRP/Japan) និងកិច្ចសហប្រតិបត្តិការជាមួយអង្គការសន្តិស្ម័គ្រចិត្តកម្ពុជា (SVA Cambodia) ។

ក្រសួងធម្មការ និងសាសនា បានស្នើសុំអង្គការសន្តិស្ម័គ្រចិត្តកម្ពុជា ជួយបោះពុម្ព និងចែកផ្សាយសៀវភៅនេះ ដើម្បីជាគុណប្រយោជន៍ដល់ :

- ការលើកស្ទួយការសិក្សា របស់ប្រជាពលរដ្ឋកម្ពុជា គ្រប់ស្រទាប់ ។
- រក្សាមរតកវប្បធម៌ អក្សរសាស្ត្រ ឱ្យបានគង់វង្ស និងរីកចំរើន ។

ការបោះពុម្ពឡើងវិញនេះ ធ្វើឡើងដោយថតចម្លងពីសៀវភៅច្បាប់ដើម បោះពុម្ពលើកទី ១ ក្នុងឆ្នាំ ១៩៤៤ ។ ហេតុនេះ ប្រសិនបើមានកំហុសអក្ខរាវិរុទ្ធក្តី កំហុសក្នុងការរៀបរៀងឃ្លាក្តី នោះគឺជាលក្ខណៈដែលមានក្នុងច្បាប់ដើមពីមុនមក ។

ក្រសួងធម្មការ និងសាសនា សូមអភ័យទោសជាមុន ចំពោះកង្វះខាតផ្សេងៗ ដែលអាចនឹងកើតមានដោយអចេតនា ក្នុងការបោះពុម្ពឡើងវិញនេះ ។

សូមឧទ្ទិសសៀវភៅនេះ ចំពោះស្មារតីស្រឡាញ់ និងលើកស្ទួយអក្សរសាស្ត្រជាតិ និងសីលធម៌ពុទ្ធសាសនា ហើយជាពិសេស ចំពោះស្មារតីបង្រួបបង្រួមជាតិ ដើម្បីសុខសន្តិភាពដ៏ស្ថិតស្ថេរ នៅកម្ពុជា ។

សូមជនានុជនក្នុងកម្ពុជរដ្ឋ បានចំរើនលូតលាស់ដុះដាលដោយវិជ្ជា និងវិបុលសុខគ្រប់ប្រការ ហើយរួបរួមគ្នាកសាងប្រទេស និងលើកស្ទួយអក្សរសាស្ត្រ និងព្រះពុទ្ធសាសនា ឱ្យបានរីកចំរើនជាភិយ្យោភាព តរៀងទៅ !

សូមថ្លែងអំណរគុណ ប្រកបកតញ្ញូតាធមិយ៉ាងជ្រាលជ្រៅបំផុត ចំពោះក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព នៃប្រទេសជប៉ុន (WCRP/Japan) និងអង្គការសន្តិស័គ្រចិត្តកម្ពុជា (SVA Cambodia) ដែលបានជួយឧបត្ថម្ភដល់ការបោះពុម្ពសៀវភៅនេះ ។

ភ្នំពេញ , ខែ កក្កដា ឆ្នាំ ២០០១
ក្រសួងធម្មការ និងសាសនា

## ごあいさつ

この本は、世界宗教者平和会議日本委員会と社団法人シャンティ国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本とカンボジアの人々との友情のきずなとなり、カンボジアの文化発展に貢献できれば幸いです。

## និវេទនកថា

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងជាពិសេសទុកដូចជាគម្រោងការងាររបស់គណៈកម្មាធិការជប៉ុន នៃក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព (WCRP/Japan) និងអង្គការសន្តិស្ស័គ្រចិត្តកម្ពុជា (SVA Cambodia) ។

យើងខ្ញុំអធិដ្ឋាន សូមឱ្យសៀវភៅនេះបានជាវិភាគទានដល់ការពង្រឹងមិត្តភាពរវាងប្រជាជនកម្ពុជា ជាមួយប្រជាជនជប៉ុនដែលកាន់សាសនាផ្សេងៗ និងដល់ការថែរក្សាសម្បត្តិវប្បធម៌ និងសម្បត្តិសាសនា របស់ប្រជាជនកម្ពុជា ។

## ACKNOWLEDGEMENT

This book is especially reprinted as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP/Japan) and Shanti Volunteer Association (SVA Cambodia).

We pray that this book would contribute to the promotion of the friendship between Cambodian people and Japanese religious people and to the preservation of the Cambodian cultural and religious heritage.

# អារម្ភកថា

សង្ខិត្តកថា នេះជាសៀវភៅមួយសំដែងអំពីការផ្ទៀងផ្ទាត់ធម៌វិន័យក្នុងព្រះត្រៃបិដក ឲ្យមានពួកក្រុម មិនឲ្យប្រឡូកប្រឡំគ្នា ដែលហៅថា សង្គាយនា ជាឧត្តមកិច្ចដែលព្រះថេរៈទាំងឡាយ មានព្រះមហាកស្សបត្ថេរជាដើមចាត់ធ្វើឡើង ដើម្បីសេចក្ដីចំរើន-គង់វង់-រុងរឿង-រីកធំទូលំទូលាយនៃព្រះពុទ្ធសាសនា ដែលជាមត៌កដ៏មានដំឡៃបំផុតរបស់ព្រះអគ្គមុនីនាថទ្រង់ប្រទានដល់ពុទ្ធបរិស័ទ ។ រឿងសង្គាយនាជាប្រទីបមួយដែលត្រោលបំភ្លឺពុទ្ធបរិស័ទ ឲ្យយល់ច្បាស់នូវប្រវត្តិការណ៍នៃពុទ្ធសាសនា ហើយជាទីនាំមកនូវសេចក្ដីជ្រះថ្លាក្នុងពុទ្ធសាសនាយ៉ាងភិយ្យោភាព ។

ហេតុនេះ ខ្ញុំទើបរៀបរៀងសង្ខិត្តកថានេះឡើង ដើម្បីជាជំនួយដល់សិក្ខាកាមកុលបុត្រ អ្នកសិក្សាធម្មវិន័យថ្នាក់ទោ នឹងពុទ្ធបរិស័ទទូទៅ ដែលត្រូវការចេះដឹង ។ ដោយវីរិយៈភាព របស់ខ្ញុំនេះ៖

សូមសាសនា ព្រះសាស្តា ជាវរៈនៅ!
សូមប្រជា - ការទួនៅ នៅក្នុងលោក
សុខក្សេមក្សាន្ត មានសេរី ជីពជ័យជោគ!
ប្រាសចាកភេទ ភ័យចង្រៃ គ្រប់យ៉ាងអើយ !!!

ថ្ងៃទី ៣ កញ្ញា ព.ស. ២៤៩៧ / គ.ស. ១៩៥៤

បណ្ឌិត ឌុម.ណាគ្រី

ឃុំស្វាយជៅ ស្រុកសង្កែ ខេត្តបាត់ដំបង

# សង្គីតិកថា

## សង្គីតិ

ពាក្យថា "សង្គីតិ" ប្រែថា "ដោតក្រង" ក្នុងទីនេះសំដៅយក ការដោតក្រងនូវកម្រងធម៌វិន័យ គឺរៀបរៀងផ្ទៀងផ្ទាត់ធម៌វិន័យ ឲ្យមានរបៀប រៀបជាពួក ជាក្រុម ជាបែបផែន ឬការប្រជុំផ្ទៀងព្រះត្រៃបិដក ពុទ្ធវចនៈឲ្យត្រឹមត្រូវត្រង់មិនឲ្យល្អៀងឃ្លៀងឃ្លាតខុសអំពីបែបដើម ។

សង្គីតិ ទឹងហៅថា សង្គាយនា ក៏បាន ជាលំអានដែល ព្រះថេរៈទាំងឡាយលោកនិយមធ្វើជាលំដាប់លំដោយតគ្នាមក ដើម្បីជាប្រយោជន៍ដ៏ធំទូលាយដល់ព្រះពុទ្ធសាសនា ។ ព្រះថេរានុត្ថេរៈទាំងឡាយ អ្នកប្រជុំគ្នាធ្វើសង្គាយនានោះ លោកហៅថា "សង្គីតិកាចារ្យ" ឬ "សង្គាហកាចារ្យ" ។

## បឋមហេតុនៃសង្គីតិ

សង្គីតិ ឬ សង្គាយនា នេះ កាលព្រះមុនីសម្ពុទ្ធទ្រង់គង់ធរមាននៅឡើយ ព្រះសារីបុត្តត្ថេរជាអគ្គសាវកបានប្រារព្ធផ្តើមឡើងមុនដំបូងបង្អស់ ដូចមានប្រវត្តិហេតុពោលទុកថា: កាលព្រះសម្ពុទ្ធមុរកពទ្រង់ប្រថាប់ក្នុងឧត្តកកសណ្ឋាគាររបស់មល្លក្សត្រទាំងឡាយ ក្នុងទីនោះព្រះសាស្ដាទ្រង់មានព្រះតម្រាស់ត្រាស់ហៅព្រះសារីបុត្តមកឲ្យសំដែងធម៌ដល់ភិក្ខុទាំងឡាយ ។ ព្រះសារីបុត្តក៏ប្រារព្ធដល់រឿងនិគ្រន្ថនាដបុត្រជា

គណាចារ្យ ដែលធ្វើកាលកិរិយាក្ស័យជីវិតទៅ ពួកសាវ័កសិស្សដែលនៅ ឯក្រោយ ដោយអំណាចលទ្ធិទិដ្ឋិ យោបល់យល់ផ្សេងគ្នា ក៏បែកខ្ញែកគ្នាជាពួកបក្ស ព្រោះមានៈ ទិដ្ឋិរៀងខ្លួន; ហើយព្រះសារីបុត្រលោកក៏សំដែងសង្គីតិសូត្ររៀបរៀងព្រះធម៌វិន័យឲ្យមានពួកក្រុម វគ្គ ឃ្លា ឲ្យភិក្ខុទាំងឡាយស្តាប់ ។ ព្រះសាស្តាចារ្យ ទ្រង់ត្រាស់សរសើរ ព្រមទាំងទ្រង់យល់ស្របតាមជាមួយផង តែព្រះសារីបុត្តៈលោកមិនទាន់បានរៀបចំចាត់ចែងធ្វើនៅឡើយ លោកក៏បរិនិព្វានមុនព្រះសាស្តាទៅ ។ ដំណមកខាងក្រោយ ដំណើរការណ៍នោះ ក៏បានជាគម្រោងដល់ព្រះថេរៈទាំងឡាយ មានព្រះមហាកស្សបជាដើម ដែលបានរៀបចំចាត់ចែងធ្វើបឋមសង្គាយនា ក្នុងគ្រាអបរកាលនៃពុទ្ធបរិនិព្វាន ព្រមទាំងបានជាបែបយ៉ាង ដល់បច្ឆាជនតាជន ជំនាន់ក្រោយតៗមក ។

## សង្គីតិការណ៍

ហេតុដែលនាំបណ្តាលឲ្យព្រះថេរានុត្ថេរៈទាំងឡាយ ប្រជុំគ្នាធ្វើសង្គាយនា ពល់លើកពល់គ្រា មិនមែនជាការធ្វើដោយឥតហេតុការណ៍កើតឡើងនោះទេ គឺគាល់តែមានហេតុការណ៍ណាមួយ កើតឡើងជាទំនងនាំឲ្យព្រះពុទ្ធសាសនា វៀវពេយ ទើបធ្វើឡើង ។

ហេតុដែលនាំឲ្យធ្វើសង្គាយនានោះ បើរួមមកមាន ៣ យ៉ាង គឺ:

១- ព្រោះអលជ្ជីបុគ្គលពោលពាក្យចំរូងចំកសប្តុល្មើសចំពោះធម៌វិន័យ

២- ព្រោះសេចក្ដីចូលចិត្តខុស យល់ឃើញខុស ប្រតិបត្តិខុស ចំពោះព្រះធម៌វិន័យ ។

៣- ព្រោះមានបំណងនឹងឲ្យព្រះពុទ្ធសាសនាឋិតថេរ រុងរឿងជានិច្ចអស់កាលយូរអង្វែង ។

កាលបើមានការធ្វើសង្គាយនារួចស្រេចហើយ អាចហុចប្រយោជន៍ឲ្យដល់ពួកគណៈ ពុទ្ធិកជននឹងព្រះពុទ្ធសាសនាតាមសមគួរ ។

ឯផលប្រយោជន៍នៃការធ្វើសង្គាយនានោះ មាន ៣ យ៉ាងប្រហែលគ្នានឹងហេតុដែលនាំឲ្យធ្វើសង្គាយនាដែរគឺ

១- កំចាត់បំបាត់បុគ្គលការពារកំណែកអលជ្ជីបុគ្គលបាន ។

២- ធ្វើសេចក្ដីយល់ឃើញឲ្យត្រូវគ្នា នឹងប្រតិបត្តិឲ្យបានត្រឹមត្រូវតាមព្រះធម៌វិន័យ ។

៣- ធ្វើព្រះពុទ្ធសាសនាឲ្យឋិតថេរបរកាលរុងរឿងតទៅអស់កាលយូរ ឬអាចញ៉ាំងព្រះពុទ្ធសាសនាឲ្យរីកទូលាយសាយចេញទៅគ្រប់ដំបន់បាន ។

ការប្រជុំធ្វើសង្គាយនា អាចឲ្យផលប្រយោជន៍យ៉ាងដូច្នេះ បានជាព្រះថេរៈទាំងឡាយ លោកនិយមធ្វើរៀងរាបតៗ គ្នាមកតាមកាលសម័យ ។

តាំងសម័យមុន ។ មក ភិក្ខុទាំងឡាយក្នុងព្រះពុទ្ធសាសនមណ្ឌលនេះ បានសិក្សារៀនសូត្រព្រះពុទ្ធវចនៈទ្រទ្រង់ចាំទុកមកដោយមាត់ កាល

បើបែកខ្ញែកគ្នា ទៅនៅតាមខេត្ត ឃុំ និគម ជនបទ ឆ្ងាយៗ ពីគ្នា យូរៗ ទៅអាចនឹងមានល្អៀងឃ្លៀងឃ្លាតរវាតពីគ្នាបាន ក៏ដោយហេតុដែលនៅក្នុងពួកបក្ស គណៈ និកាយ ផ្សេងៗគ្នា រមែងមានសេចក្ដីយល់ឃើញ សេចក្ដីចូលចិត្តខុស នឹងការប្រតិបត្តិក៏ទីទៃ ផ្សេងដោយឡែកពីគ្នាទៅ ឬពុំនោះសោតទេក៏មានពួកអលជ្ជីបុគ្គល គ្មានសេចក្ដីអៀនខ្មាស ប្រព្រឹត្តផ្ដេសផ្ដាស បង្កើតលទ្ធិថ្មីឡើង ។ កាលបើមានយោបល់យល់ខុសគ្នា ជាហេតុឲ្យប្រតិបត្តិខុសគ្នា កាលបើប្រតិបត្តិខុសគ្នា ជាហេតុធ្វើឲ្យព្រះពុទ្ធសាសនា ធាប់ទៀវពេយ ខ្សោយកំឡាំង សាបសោបសូន្យវិនាសទៅ ។ ដើម្បីកែប្រែប្រាប់ប្រែងឲ្យចុះសំរុង ត្រូវរបៀបគ្នាជាបែបមួយ លោកទើបប្រជុំគ្នា សាកសួរទៅវិញទៅមក បើប៉ែកខាងណាចុះរបៀបគ្នាច្រើនជាង ក៏ប្រកាន់យកជាត្រឹមត្រូវ ហើយស្រុះស្រួលបបួលគ្នាទ្រទ្រង់ទុកប្រតិបត្តិតទៅទៀត ព្រោះហេតុដូច្នោះ សង្គីតិ នេះ ទើបលោកប្រែម្យ៉ាងទៀតថា “បណ្ណញ” ដោយសេចក្ដីក៏គឺការប្រជុំគ្នាសូត្រសួរទៅវិញទៅមក ប៉ែកខាងណាបានសូត្រទៅហើយ ខុសពីក្រុមជំនុំច្រើន ក៏ត្រូវចូលចិត្តថាខាងនោះខុស មិនត្រូវប្រកាន់យកជាការត្រឹមត្រូវប្រតិបត្តិតទៅទៀតឡើយ ត្រូវបដិសេធចោល ព្រោះបានចាំទុកមកដោយការល្អៀងឃ្លៀងឃ្លាតអំពីបែបដើម ។

# បឋមសង្គីតិការណ៍

(ហេតុដែលនាំឲ្យធ្វើបឋមសង្គាយនា)

និង

## បឋមសង្គីតិ

កាលព្រះមុនិន្ទសម្ពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ព្រះអង្គបានទេសនាព្រះធម្មចក្កប្បវត្តនសូត្រ ប្រោសបញ្ចវគ្គិយភិក្ខុហើយ ទ្រង់យាងទៅកាន់ចារិកក្នុងនិគមជនបទរាជធានីផ្សេង ៗ ប្រកាសពុទ្ធសាសនធម៌ប្រោសវេនេយ្យនិករទាំងឡាយ តាមសមគួរដល់ព្រះពុទ្ធអធ្យាស្រ័យដរាបដល់ព្រះជន្មាយុគំរប់ ៨០ ព្រះវស្សា; ក្នុងបច្ឆិមពោធិកាល ទ្រង់ទូន្មានសុភទ្ទបរិព្វាជក ដែលជាបច្ឆិមវេនេយ្យពុទ្ធសាវ័កឲ្យមានសទ្ធាជ្រះថ្លា រួចទ្រង់ប្រទានបព្វជ្ជានិងឧបសម្បទាជាឯហិភិក្ខុស្រេចហើយ ស្តេចក៏រំលត់ខន្ធបរិនិព្វានទៅ នៅក្នុងចន្លោះសាលព្រឹក្សទាំងគូ ក្នុងសាលវនោទ្យានរបស់មល្លក្សត្រទាំងឡាយ ជិតក្រុងកុសិនារាជធានី នាឆ្នាំម្សាញ់នព្វស័ក នៅក្នុងគិម្ហរដូវ ថ្ងៃអង្គារពេញបូណ៌មីខែពិសាខ វេលាទៀបភ្លឺស្វាង ។ វេលានោះមានព្រះអនុរុទ្ធត្ថេរជាប្រធានក្នុងទីនោះ ។ សម័យនោះ ព្រះមហាកស្សបត្ថេរ ជាថេរៈមានវស្សាយុកាលចាស់ជាងព្រះសង្ឃទាំងពួងប្រមាណ ៧ សែនអង្គ បណ្ដាដែលមកប្រជុំគ្នា; តែក្នុងវេលាដែលស្ដេចរំលត់ខន្ធបរិនិព្វាននោះ ព្រះមហាកស្សប-

គេរពុំបានមកប្រជុំក្នុងទីនោះទេ លោកកំពុងនិមន្តតាមផ្លូវ មកអំពីនគរបាវា ជាមួយនឹងភិក្ខុសង្ឃជាបរិវារ ប្រមាណ ៥០០ រូប បំណងនឹងទៅគាល់ព្រះដ៏មានព្រះភាគ ។ កាលលោកនិមន្តមកដល់ពាក់កណ្តាលផ្លូវ បានចូលឈប់សំរាកនៅក្រោមម្លប់ព្រឹក្សមួយដើម ក៏ជួបនឹងអាជីវកម្នាក់ កំពុងដើរដំណើរមកអំពីក្រុងកុសិនារា លោកក៏សាកសួរពត៌មានអំពីព្រះបរមគ្រូ; លុះបានជ្រាបថា ស្តេចរំលត់ខន្ធបរិនិព្វានកន្លង ៧ ថ្ងៃទៅហើយរាប់ពីថ្ងៃនេះទៅ, បណ្តាពួកភិក្ខុដែលមាននៅក្នុងទីនោះ អង្គណាដែលមិនទាន់ប្រាសចាករាគៈនៅឡើយ ក៏សោកសៅបរិទេវនាការអាឡោះអា·ល័យចំពោះព្រះភគវា អង្គណាដែលប្រាសចាករាគៈហើយក៏អត់សង្កត់ទៅបាន ដោយការពិចារណាធម្មតាលោកថាសង្ខារទាំងពួងមិនទៀងទេ ។ ក្នុងខណៈនោះ មានភិក្ខុមួយរូបឈ្មោះសុភទ្ទៈ បួសឯតាស់ ដែលធ្លាប់ព្ទនាមមកថា សុភទ្ទវុឌ្ឍបព្វជិតនៅក្នុងចំណោមនោះដែរ បាននិយាយទៅរកភិក្ខុទាំងនោះថា "លោកដ៏មានអាយុទាំងឡាយ! លោកទាំងឡាយកុំសោកស្តាយព្រះមហាសមណគោតមនោះឡើយ ព្រះអង្គបរិនិព្វានទៅស្រួលហើយ, ពេលនេះយើងទាំងអស់គ្នា ឈ្មោះថាផុតស្រឡះហើយអំពីសមណគោតមនោះ កាលព្រះអង្គគង់ព្រះជន្មនៅ ប្រើនតែចាំបៀតបៀនស្តីពោលបន្ទោសយើងរាល់គ្នាថា របស់នេះគួរ របស់នេះមិនគួរ, ចេះតែហាមប្រាមបញ្ញត្តច្បាប់ បែបនេះ បែបនោះ មិនឈប់ឈរសោះ; ចាប់

តាំងពីថ្ងៃនេះទៅ យើងតាំងឡាយមុខជាបានសេចក្ដីសុខហើយ, យើងប្រាថ្នានឹងធ្វើនូវអំពើណា យើងក៏នឹងអាចធ្វើនូវអំពើនោះបាន គ្មាននរណាហាមឃាត់ទៀតទេ" ។ ព្រះមហាកស្សបត្ថេរទ្រង់បានព្ទនូវពាក្យអស់នេះហើយ ក៏កើតសេចក្ដីសង្វេគស្លុតព្រះទ័យថា "ឱ! ព្រះបរមសាស្ដាដ៏ទ្រទ្រង់នូវព្រះមហាគុណ! ស្ដេចរំលត់ខន្ធបរិនិព្វានទៅ មិនទាន់បានយូរប៉ុន្មាន អស់រយៈកាលត្រឹម ៧ ថ្ងៃប៉ុណ្ណោះមកមានអលជ្ជីបាបជនពោលចំរូងចំរាស ចំពោះព្រះធម៌វិន័យបានយ៉ាងដូច្នេះទៅហើយ" តែលោកនឹងលើកឡើងនិយាយក្នុងពេលនោះ ក៏ឃើញថាមិនសមគួរ, ទើបលោកទាំគិតុសង្វេជាបរិកេរទាំងនោះ ទៅថ្វាយបង្គំព្រះពុទ្ធសរីរៈព្រមទាំងថ្វាយព្រះភ្លើងផង ។ កាលរួចកិច្ចថ្វាយព្រះភ្លើងព្រះពុទ្ធសរីរៈហើយ ទើបលោកប្រារព្ធនូវការធ្វើសង្គាយនា ដោយអាស្រ័យហេតុ ២ ប្រការ (ពោលចំពោះតែរឿងសំខាន់ៗ) គឺ៖

១- រលឹកដល់ពាក្យរបស់សុភទ្ទវុឌ្ឍបព្វជិត ដែលពោលពាក្យចំរូងចំរាសចំពោះព្រះធម៌វិន័យ បើបណ្ដែតបណ្ដោយយូរទៅ ព្រះសទ្ធម្មមុខជាអន្តរធាន, កាលបើព្រះសទ្ធម្មតាំងនៅហើយ ក៏ដូចជាតួអង្គព្រះបរមគ្រូគង់ព្រះជន្មនៅដែរ ។

២- រលឹកដល់ឧបការគុណរបស់ព្រះដ៏មានបុណ្យ ដែលមានលើខ្លួនលោក ដូចទ្រង់បានប្រទានសំពត់សង្ឃាដិរបស់ព្រះអង្គដល់លោក,

ព្រមទាំងបានលើកដំកើងលោកទុក្កង់ហានៈ ថាជាអ្នកមានធម៌ជាគ្រឿងនៅស្មើដោយព្រះអង្គជាដើម ។

កាលប្រារព្ធហេតុទាំងនេះឡើងហើយ ទើបប្រកាសសេចក្តីត្រិះរិះរបស់លោក ព្រមទាំងពណ៌នារឿងរ៉ាវតាំងតែពីដើម ឲ្យភិក្ខុទាំងឡាយបានជ្រាប ហើយណែនាំព្រះសង្ឃឲ្យមានសេចក្តីឧស្សាហ៍ខ្មីឃ្មាត ក្នុងកិច្ចធ្វើសង្គាយនាថែមទៀត ។ ភិក្ខុទាំងឡាយក៏ទទួលតាម ទើបអារាធនាសុំឲ្យព្រះថេរៈជ្រើសរើសព្រះសង្ឃ ដែលនឹងត្រូវចូលទៅប្រជុំធ្វើសង្គាយនា ។ ព្រះមហាកស្សបត្ថេរក៏ជ្រើសយកព្រះសង្ឃ សុទ្ធតែព្រះអរហន្តខីណាស្រពដែលទ្រទ្រង់នូវបដិសម្ភិទា ៤ និងអភិញ្ញា ៦ ជាភិក្ខុសង្ឃបានទទួលនូវឯតទគ្គដ្ឋាន អំពីសំណាក់ព្រះសាស្តា បានចំនួន ៤៩៩ អង្គ មិនទាន់បានបង្គ្រប់ជា ៥០០ អង្គ ដ្បិតនៅចន្លោះ ១ អង្គដើម្បីទុកឱកាសដល់ព្រះអានន្ទ ។ ឯការណ៍ដែលមិនជ្រើសព្រះអានន្ទបង្គ្រប់ចំនួនក្នុងវេលានោះ ក៏ព្រោះអាស្រ័យហេតុ ២ ប្រការ គឺៈ

១– ដើម្បីការពារបរប្បវាទថា ជ្រើសយកដោយយល់មុខ ព្រោះព្រះអានន្ទជាព្រះអនុជ ហើយជាឧបដ្ឋាកជិតរបស់ព្រះសាស្តា ទាំងនៅជាសេក្ខបុគ្គលទៀតផង ។

២– ដើម្បីទុកឲ្យសង្ឃជ្រើសយក ទោះជាយ៉ាងណា ក៏ពោលព្រះអានន្ទមិនបាន ព្រោះព្រះអានន្ទប្រាកដថា លោកជាឃ្លាំងនៃព្រះសទ្ធម្ម

បេះចាំនូវពុទ្ធវចនៈច្រើន ហេតុដល់បានទទួលនូវឯតទគ្គដ្ឋាន អំពីសំណាក់ព្រះសាស្ដា បើវៀរព្រះអានន្ទចេញហើយ ការសង្គាយនាក៏នឹងសំរេចទៅពុំបាន ។

កាលបើព្រះមហាកស្សបមិនជ្រើសព្រះអានន្ទដូច្នេះ ព្រះសង្ឃក៏អា-រាធនាសុំឲ្យលោកជ្រើសព្រះអានន្ទបញ្ចូលជាមួយផង ។ កាលបានឱកាសដូច្នេះហើយ ទើបព្រះមហាកស្សបជ្រើសព្រះអានន្ទបញ្ចូលបង្គ្រប់ជាចំនួន ៥០០ អង្គបរិបូណ៌ ។ លុះជ្រើសព្រះសង្ឃរួចស្រេចហើយ ក៏ប្រឹក្សាគ្នារកទីកន្លែងធ្វើសង្គាយនា; ទីបំផុតបានមូលមតិគ្នាថានឹងទៅធ្វើក្នុងក្រុងរាជគ្រឹះ ព្រោះក្រុងនោះ ជាទីបរិបូណ៌ដោយសេនាសនៈ នឹងគោចរគ្រាម ការសង្គាយនានឹងប្រព្រឹត្តទៅបានស្រួល ។ លំដាប់នោះ ព្រះមហាកស្សបសូត្រអនុសាវនៈ ដោយញត្តិទុតិយកម្មវាចា ហាមភិក្ខុសង្ឃក្រៅអំពីដែលទៅធ្វើសង្គាយនានេះ មិនឲ្យចូលទៅគង់ចាំវស្សាក្នុងក្រុងរាជគ្រឹះឡើយ, ព្រោះសង្គាយនានេះជាថាវរកម្ម ក្រែងនឹងមានវិសភាគបុគ្គលចូលចំនាស់ នាំមិនឲ្យសំរេចទៅបាន ។ កាលនៅតែកន្លះខែទៀតនឹងដល់ថ្ងៃចូលព្រះវស្សា, ភិក្ខុសង្ឃទាំងអស់ក៏និមន្តចេញទៅក្រុងរាជគ្រឹះ បំបែកគ្នាជាពីរផ្លូវ គឺព្រះមហាកស្សប នាំព្រះសង្ឃ ២៥០ អង្គ ទៅតាមផ្លូវមួយ, ព្រះអនុរុទ្ធនាំ ២៤៩ អង្គ ទៅតាមផ្លូវមួយ ។

ដំណាលពីព្រះអានន្ទ, កាលស្រេចពីថ្វាយព្រះភ្លើងព្រះពុទ្ធសរីរៈ ហើយ លោកក៏នាំយកបាត្រនិងចីវររបស់ព្រះដ៏មានព្រះភាគ ព្រមដោយភិក្ខុសង្ឃជាបរិវារនិមន្តទៅកាន់វត្តជេតពន ក្រុងសាវត្ថី ដែលជាទីគង់នៅនៃព្រះដ៏មានព្រះភាគក្នុងកាលមុន ៗ នៅវេលាដែលនិមន្តទៅនោះ ព្រះអានន្ទទៅជាវត្តមួយជាទីសោកសៅរបស់មហាជន ដែលនៅតាមផ្លូវសងខាងនៃមគ្គាជាលំដាប់ដល់ក្រុងសាវត្ថី, លោកនិមន្តទៅដល់ទីណា សព្ទសូរសំឡេងទន្គឹះខ្សឹកខ្សួលរំជួលចិត្តនៃមហាជន ដែលសោកស្តាយអាឡោះអាល័យព្រះដ៏មានបុណ្យ ក៏លាន់ឮកងរំពងឡើងក្នុងទីនោះដូចជាក្នុងថ្ងៃដែលស្តេចរំលត់ខន្ធបរិនិព្វាននោះឯង, ព្រោះមហាជនទាំងនោះ ទើបនឹងបានដឹងដំណឹង ព្រះដ៏មានបុណ្យអំពីព្រះអានន្ទ ៗ ព្រះអានន្ទក៏លួងលោមមហាជនទាំងនោះ ឲ្យបានស្ងប់ស្ងាត់ទៅវិញដោយមធុរៈធម្មកថាដែលប្រកបដោយត្រៃលក្ខណ៍ គឺ អនិច្ចំ ទុក្ខំ អនត្តា ៗ កាលលោកនិមន្តដល់វត្តជេតពនហើយ ក៏បោសប្រាសសំអាត ព្រះគន្ធកុដិពុទ្ធសយ-ដ្ឋានប្រតិបត្តិកិច្ចវត្តសព្វយ៉ាងឲ្យដូចជាកាលដែលព្រះអង្គគង់ព្រះជន្មនៅ ៗ ដោយហេតុថា តាំងពីកាលដែលព្រះសយម្ពូញាណបរិនិព្វានទៅ លោកឈរនឹងអង្គុយហួសកំរិតពេក ក៏បណ្តាលឲ្យកើតអាពាធ ព្រឹកឡើងថ្ងៃជាគំរប់ពីរ លោកឆាន់ថ្នាំបញ្ចុះ ធ្វើកាយឲ្យបានសុខសប្បាយស្រួលទៅវិញ ៗ ក្នុងថ្ងៃជាគំរប់បី លោកបានចូលទៅកាន់ទីនិមន្តរបស់សុភមាណព

មានព្រះចេតកត្ថេរជាបច្ឆាសមណៈ បានសំដែងសុភសូត្រក្នុងគម្ពីរទីឃនិកាយប្រោសសុភមាណព ហើយសូមហត្ថកម្មក្នុងការជួសជុលព្រះវិហារជេតពនពីសុភមាណពនោះ ស្រេចហើយលោកក៏ត្រឡប់មកវត្តជេតពនវិញ; លុះដល់ថ្ងៃជិតចូលព្រះវស្សា ព្រះថេរក៏និមន្តទៅកាន់ក្រុងរាជគ្រឹះ ។

កាលទៅជួបជុំគ្រប់អង្គ ក្នុងក្រុងរាជគ្រឹះនោះហើយក៏ចូលទៅថ្វាយព្រះពរសុំហត្ថកម្មនឹងព្រះចៅអជាតសត្តុរាជ ក្នុងការជួសជុលនូវព្រះមហាវិហារទាំង ១៨ កន្លែងដែលបាក់បែកធ្លុះធ្លាយ ។ បានសំរេចកិច្ចនេះ នៅក្នុងខែជាបឋម (អាសាឍ) នៃអន្ទោវស្សកាល (កាលចូលវស្សា) ដល់ខែជាគំរប់ពីរ (ស្រាពណ៍) ទើបព្រះថេរៈទាំងនោះនិមន្តទៅថ្វាយព្រះពរសុំទីប្រជុំធ្វើសង្គាយនាឰដ៏ទ្វារសត្តបណ្ណគុហា ខាងវេភារបព៌ត ។ ព្រះបាទអជាតសត្តុរាជ ក៏ទ្រង់ប្រើវិស្វករយ៉ាងចំណានឲ្យទៅចាត់ការកសាងមហាមណ្ឌបមួយយ៉ាងល្អល្អះ ត្រចះពណ្ណរាយ មានគ្រប់ទាំងគ្រឿងប្រដាប់ផ្សេងៗ ដូចធម្មាសនៈជាដើមរួចស្រេចហើយ ក៏វេរថ្វាយព្រះសង្ឃតាមសេចក្តីត្រូវការ ។ នៅតែ១ថ្ងៃទៀត (ថ្ងៃ ១៤ កើតខែស្រាពណ៍) នឹងដល់ថ្ងៃដែលសង្ឃត្រូវប្រជុំធ្វើសង្គាយនា ។ គ្រានោះព្រះសង្ឃទាំងអស់គៀងខំរលឹកព្រះអានន្ទថា ម្នាលអាវុសោ! ស្អែកនេះជាថ្ងៃដែលសង្ឃត្រូវប្រជុំគ្នាធ្វើសង្គាយនាហើយ ឯខ្លួនលោកនៅជាសេខបុគ្គល មិនសមគួរនឹងទៅកាន់ទីប្រជុំនោះឡើយ បើដូច្នេះលោកកុំប្រមាទ ត្រូវខំប្រឹងប្រែង

ធ្វើសមណធម៌ទៀត ៗ ព្រះអានន្ទក៏ទទួលធ្វើតាម ក្នុងវេលាសន្ធ្យាព្រែ
នោះ, ព្រះអានន្ទប្រឹងផ្ចង់កម្រង់ស្មារតីដោយកាយគតាសតិកម្មដ្ឋានប្រារព្ធ
នូវសេចក្ដីព្យាយាមដ៏ខ្លាំងក្លា ដរាបដល់វេលាកន្លងផុតមជ្ឈិមយាមទៅ
ហើយ ក៏នៅតែមិនបានសំរេចធម៌ពិសេស, ទើបបានមកសញ្ជឹងទឹកដល់
ព្រះពុទ្ធដីកាដែលព្រះសាស្ដាបានត្រាស់ទំនាយទុកថា អាត្មាអញនឹងបាន
សំរេចធម៌ពិសេសក្នុងថ្ងៃដែលព្រះសង្ឃប្រជុំធ្វើសង្គាយនា ឯឈ្មោះថា
ព្រះវាចានៃព្រះពុទ្ធទាំងឡាយពុំមែនជាមានទោសទេ ក៏សេចក្ដីព្យាយាម
ដែលអាត្មាអញប្រារព្ធហើយនេះ ជ្រុលហួសពេក ទើបបានជាចិត្តរបស់
អាត្មាអញរាយមាយយ៉ាងដូច្នេះ ៗ កាលនឹកយ៉ាងនេះហើយក៏ចុះចាក
ចង្រ្កម លាងព្រះបាទរួចចូលទៅកាន់ទីលំនៅ ប្រារព្ធនឹងសិងសំរាកបន្ទិច
ប្រាសកាយទៅលើគ្រែ ព្រះបាទទាំងគូទើបនឹងលើកឡើងផុតពីផែនដីព្រះ
សិរមិនទាន់ដល់ខ្នើយនៅឡើយ ក៏បានសម្រេចព្រះអរហត្តក្នុងចន្លោះនេះ
ទៅ នៅក្នុងវេលាបច្ចូសសម័យ (ជិតភ្លឺ) ៗ ព្រឹកឡើងជាថ្ងៃដែលព្រះ
សង្ឃចាប់ផ្ដើមធ្វើបឋមសង្គាយនា គឺថ្ងៃ ១ កេចខែស្រាពណ៍ រាប់អំពីពុទ្ធ-
បរិនិព្វានកន្លងមកបាន ៤ ខែ បើរាប់យកតែចំនួនថ្ងៃបានត្រឹមតែ ៣ ខែគត់;
ព្រះអានន្ទក៏បាននិមន្តចូលទៅកាន់ទីប្រជុំ ៗ លុះប្រជុំព្រមគ្រប់ព្រះអង្គ
ហើយទើបប្រឹក្សាសង្ឃរកអ្នកដែលសមគួរនឹងទទួលធុរៈក្នុងការសង្គាយនា
ហើយជាគួរនឹងសង្គាយនាបិដកណាមុនក្នុងបណ្ដាបិដកទាំងបី, ទីបំផុតក៏

បានអនុម័តិដោយឯកច្ឆន្ទថា ព្រះមហាកស្សប, ព្រះឧបាលិ នឹងព្រះអានន្ទ ទាំងបីព្រះអង្គនេះ ជាព្រះថេរៈត្រូវទទួលធុរៈក្នុងមុខការសង្គាយនា ហើយថាគួរនឹងសង្គាយនាវិន័យបិដកមុន ព្រោះព្រះវិន័យជាឫសគល់ឬជាអាយុព្រះពុទ្ធសាសនា, បើព្រះវិន័យឋិតនៅដរាបណា ព្រះសាសនាក៏អាចឋិតនៅរុងរឿងដរាបនោះ, ទើបចាត់របៀបសង្គាយនា ដោយវិធីបុច្ឆាវិស្សជ្ជនា ដូចតទៅនេះ៖

ក– ព្រះមហាកស្សប ជាអ្នកបុច្ឆាព្រះវិន័យ, ព្រះសូត្រ, ព្រះបរមត្ថ ។

ខ- ព្រះឧបាលិ ជាអ្នកវិស្សជ្ជនាព្រះវិន័យ ។

គ– ព្រះអានន្ទ ជាអ្នកវិស្សជ្ជនាព្រះសូត្រ, ព្រះបរមត្ថ ។

គ្រានោះ ព្រះមហាកស្សបដ៏មានអាយុបានប្រកាសឲ្យសង្ឃដឹងថា សុណាតុ មេ អាវុសោ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ ឧបាលឹ វិនយំ បុច្ឆេយ្យំ "ម្នាលអាវុសោ! សង្ឃប្រស្តាប់ខ្ញុំ បើសង្ឃកម្មនេះ មានកាលគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរព្រះវិន័យនឹងព្រះឧបាលិ" ។ ឯព្រះឧបាលិប្រកាសថា សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អាយស្មតា មហាកស្សបេន វិនយំ បុដ្ឋោ វិស្សជ្ជេយ្យំ

"បពិត្រព្រះសង្ឃដ៏ចំរើន ! សូមសង្ឃស្ដាប់ខ្ញុំ បើសង្ឃគឺកម្មនេះមានកាលគួរដល់សង្ឃហើយព្រះមហាកស្សបដ៏មានអាយុ សួរព្រះវិន័យចំពោះខ្ញុំ ៗ ក៏ត្រូវដោះស្រាយ (ក្នុងកាលឥឡូវនេះ)" ។

ប្រកាសស្រេចហើយ ព្រះមហាកស្សប ក៏ផ្ដើមបុច្ឆាព្រះវិន័យ នឹងព្រះឧបាលិ ៗ ក៏វិស្សជ្ជនាដាល់ដាប់ហូរហៀរទៅ ។ ការបុច្ឆាវិស្សជ្ជនានេះបានសួរទឹងឆ្លើយកែដល់ វត្ថុ គឺរឿង និទាន គឺហេតុនៃរឿង, បុគ្គល គឺអ្នកដែលជាដើមហេតុ, បញ្ញត្តិ គឺ បញ្ញត្តិដែលទ្រង់តាំងទុកមុនដំបូង; អនុបញ្ញត្តិ គឺបញ្ញត្តិដែលទ្រង់តាំងបន្ថែមទៀងខាងក្រោយ អាបត្តិ គឺទោសដែលប្រព្រឹត្តល្មើសចំពោះបញ្ញត្តិ អនាបត្តិ គឺមិនមានទោស ។

## ព្រះវិន័យបែងចែកជា ២ វិភង្គ គឺ

១ - ភិក្ខុវិភង្គ បានដល់វិន័យរបស់ភិក្ខុ ។

២ - ភិក្ខុនីវិភង្គ បានដល់វិន័យរបស់ភិក្ខុនី ។

ការបុច្ឆា-វិស្សជ្ជនានោះ បានលើកយកវិន័យរបស់ភិក្ខុមកសំដែងមុនលុះចប់ហើយ ទើបបុច្ឆា-វិស្សជ្ជនាវិន័យរបស់ភិក្ខុនីតទៅទៀត ។ កាលព្រះឧបាលិ វិស្សជ្ជនាព្រះវិន័យចប់ហើយ លោកប្រជុំចាត់ជាកណ្ឌ ៗ ដូចតទៅនេះ ៖

## ភិក្ខុវិភង្គមាន ៨ កណ្ឌ

១- បារាជិក ៤ សិក្ខាបទ ឈ្មោះថាបារាជិកកណ្ឌ ។

២- សង្ឃាទិសេស ១៣ សិក្ខាបទ ឈ្មោះថាតេរសកណ្ឌ ។

៣- អនិយត ២ សិក្ខាបទ ឈ្មោះអនិយតកណ្ឌ ។

៤- និស្សគ្គិយបាចិត្តិយ ៣០ សិក្ខាបទ ឈ្មោះនិស្សគ្គិយកណ្ឌ ។

៥- សុទ្ធិកបាចិត្តិយ ៩២ សិក្ខាបទ ឈ្មោះបាចិត្តិយកណ្ឌ ។

៦- បាដិទេសនីយ ៤ សិក្ខាបទ ឈ្មោះបាដិទេសនីយកណ្ឌ ។

៧- សេខិយវត្ត ៧៥ សិក្ខាបទ ឈ្មោះសេខិយកណ្ឌ ។

៨- អធិករណសមថៈ ៧ សិក្ខាបទ ឈ្មោះអធិករណសមថកណ្ឌ ។

រួមភិក្ខុវិភង្គ មាន ២២៧ សិក្ខាបទ ជាវិន័យរបស់ភិក្ខុ ។

## ភិក្ខុនីវិភង្គ មាន ៧ កណ្ឌ

១- បារាជិក ៨ សិក្ខាបទ ឈ្មោះបារាជិកកណ្ឌ ។

២- សង្ឃាទិសេស ១៧ សិក្ខាបទ ឈ្មោះសត្តរសកណ្ឌ ។

៣- និស្សគ្គិយបាចិត្តិយ ៣០ សិក្ខាបទ ឈ្មោះនិស្សគ្គិយកណ្ឌ ។

៤- សុទ្ធិកបាចិត្តិយ ១៦៦ សិក្ខាបទ ឈ្មោះបាចិត្តិយកណ្ឌ ។

៥- បាដិទេសនីយ ៧ សិក្ខាបទ ឈ្មោះបាដិទេសនីយកណ្ឌ ។

៦- សេខិយវត្ត ៧៥ សិក្ខាបទ ឈ្មោះសេខិយកណ្ឌ ។

៧- អធិករណសមថៈ ៧ សិក្ខាបទ ឈ្មោះអធិករណសមថកណ្ឌ ។

រួមភិក្ខុនីវិភង្គ មាន ៣៣១ សិក្ខាបទ ជាវិន័យរបស់ភិក្ខុនី ។

វិភង្គទាំងពីរនេះ ហៅរួមថា "ឧភតោវិភង្គ" ដូច្នេះក៏បាន ។

លំដាប់តទៅ លោកសង្គាយនា ខន្ធវគ្គនឹងបរិវារវគ្គ, លុះចប់ហើយ ទើបរួបរួមជាគម្ពីរ មាន ៥ គម្ពីរគឺ ១- គម្ពីរអាទិកម្ម, ២- គម្ពីរបាចិត្តិយ, ៣. គម្ពីរមហាវគ្គ, ៤- គម្ពីរចុល្លវគ្គ, ៥. គម្ពីរបរិវារ ។

គម្ពីរទាំង ៥ នេះសរសេរជាអក្សរបំព្រួញគឺ អា., បា., ម., ចុ., ប., ។

គម្ពីរទាំង ៥ នេះ ជាព្រះពុទ្ធប្បញ្ញត្តិ គឺព្រះបរមគ្រូទ្រង់បញ្ញត្តឡើង តមកខាងក្រោយ មានលោកអ្នកប្រាជ្ញជ្រៅជ្រះបានធ្វើអត្ថាធិប្បាយពង្រីក ថែមឡើងទៀត ដើម្បីឲ្យសិក្ខាកាមកុលបុត្រក្នុងសាសនមណ្ឌលនេះ សិក្សា ឆាប់យល់ នឹងបានស្រួលដល់ការសិក្សាប្រតិបត្តិ; ឯសេចក្តីដែលលោកបាន អធិប្បាយទុកមកទាំងនោះ ឈ្មោះថាអដ្ឋកថា មានសំរាប់គម្ពីរ ៥ ដូច្នេះ៖

គម្ពីរអាទិកម្ម មានអដ្ឋកថាឈ្មោះ បឋមសមន្តប្បា-សាទិកា ។

គម្ពីរបាចិត្តិយ មានអដ្ឋកថាឈ្មោះ ទុតិយសមន្តប្បា-សាទិកា ។

គម្ពីរមហាវគ្គ មានអដ្ឋកថាឈ្មោះ តតិយសមន្ត សាទិកា ។

គម្ពីរចុល្លវគ្គ មានអដ្ឋកថាឈ្មោះ ចតុត្ថសមន្តប្បាសាទិកា ។

គម្ពីរបរិវារ មានអដ្ឋកថាឈ្មោះ បញ្ចមសមន្តប្បាសាទិកា ។

ព្រះវិន័យ ៥ គម្ពីរនេះ ចាត់ជាបិដកមួយឈ្មោះវិន័យបិដកចែកជាធម្មក្ខន្ធ មាន ២១.០០០ ព្រះធម្មក្ខន្ធ ។

## ព្រះវិន័យទាំងអស់មានអត្ថ ៣ ប្រការគឺ

១- វិវិធនយត្តា ព្រោះអត្ថថា មានន័យផ្សេងៗ ។

២- វិសេសនយត្តា ព្រោះអត្ថថាមានន័យដ៏វិសេស ។

៣- កាយវាចានំ វិនយតោ ព្រោះអត្ថថា ជាគ្រឿងកាត់ឬខ្នាននូវកាយនឹងវាចា ។

## អំណាចប្រយោជន៍នៃការបញ្ញត្តិវិន័យ

ព្រះវិន័យ ដែលព្រះបរមសាស្តាទ្រង់បញ្ញត្តឡើង ព្រោះទ្រង់មានព្រះពុទ្ធបំណងឲ្យបានទទួលនូវប្រយោជន៍ ១០ ប្រការគឺ

១- សង្ឃសុដ្ឋុតាយ ដើម្បីសេចក្តីល្អដល់សង្ឃ ។

២- សង្ឃផាសុតាយ ដើម្បីការនៅជាសុខស្រួលនៃសង្ឃ ។

៣- ទុម្មង្កូនំ ភិក្ខូនំ និគ្គហាយ ដើម្បីញាំញីឬផ្ចាញ់ផ្ចាល់ពួកភិក្ខុដែលទ្រុស្តសីល ( ឬបុគ្គលដែលគេប្រដៅក្រ ) ។

៤- បេសលានំ ភិក្ខូនំ ផាសុវិហារាយ ដើម្បីការនៅជាសុខដល់ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ ។

៥- ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ ដើម្បីឃាត់ឃាំងនូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ។

៦- សម្បរាយិកានំ អាសវានំ បដិឃាតាយ ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ។

៧- អប្បសន្នានំ បសាទាយ ដើម្បីញុំាងពួកជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ។

៨- បសន្នានំ ភិយ្យោភាវាយ ដើម្បីញុំាងពួកជនទាំងឡាយដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង ។

៩- សទ្ធម្មដ្ឋិតិយា ដើម្បីញុំាងព្រះសទ្ធម្មឲ្យឋិតថេរអស់កាលដ៏យូរ ។

១០- វិនយានុគ្គហាយ ដើម្បីអនុគ្រោះដល់ព្រះវិន័យ (៤យ៉ាង គឺសំវរវិន័យ, បហានវិន័យ, សមថវិន័យ, និងបញ្ញត្តិវិន័យ, ។

លុះចប់ការសង្គាយនាព្រះវិន័យហើយ ព្រះឧបាលិក៏និមន្តចុះចាកធម្មាសនៈ ថ្វាយបង្គំវុឌ្ឍភិក្ខុទាំងឡាយ ហើយគង់នៅលើអាសនៈរបស់ខ្លួន ។ លំដាប់នោះ ព្រះមហាកស្សបដ៏មានអាយុ ប្រកាសឲ្យសង្ឃដឹងថា:

សុណាតុ មេ អាវុសោ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អានន្ទំ ធម្មំ បុច្ឆេយ្យំ "ម្នាលអាវុសោ! សង្ឃចូរស្ដាប់ខ្ញុំ បើសង្គីតិកម្មនេះមានកាលគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរព្រះធម៌ចំពោះព្រះអានន្ទ" ។

ឯព្រះអានន្ទដ៏មានអាយុក៏ប្រកាសសន្មតិខ្លួនថា:

សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អាយស្មតា មហាកស្សបេន ធម្មំ បុដ្ឋោ វិស្សជ្ជេយ្យំ "បពិត្រព្រះសង្ឃដ៏ចំរើន! សូមព្រះសង្ឃស្ដាប់ខ្ញុំ បើសង្គីតិកម្មនេះ មានកាលគួរដល់ព្រះសង្ឃហើយ ព្រះមហាកស្សបៈដ៏មានអាយុសួរព្រះធម៌ចំពោះខ្ញុំ គប្បីដោះស្រាយ (ក្នុងកាលឥឡូវនេះ) ។

លុះប្រកាសយ៉ាងនេះរួចហើយ, ព្រះអានន្ទក៏ទ្រង់ក្រោកចាកអាសនៈ ធ្វើនូវឧត្តរាសង្គៈឆៀងស្មាម្ខាង, ថ្វាយបង្គំនូវភិក្ខុជាថេរៈទាំងឡាយ ហើយឡើងគង់លើធម្មាសនៈព្រះហត្ថាចាប់យកនូវវិជនីដ៏វិចិត្រ វេចនាដោយដងជាវិការនៃភ្លុកដ៏សស្អាត; ទើបព្រះមហាកស្សបៈបុច្ឆាសង្គាយនានូវព្រះធម៌ ព្រះអានន្ទក៏វិស្សជ្ជនាជាលំដាប់ហូរហែទៅ ។ ព្រះសូត្រដែលលោកលើកឡើងសំដែងតាមដែលមានក្នុងសង្គីតិកថា មាន ២ សូត្រគឺព្រហ្មជាលសូត្រនឹងសាមញ្ញផលសូត្រ; សង្គាយនាព្រហ្មជាលសូត្រមុន ។

ព្រហ្មជាលសូត្រនោះ ព្រះបរមគ្រូ ទ្រង់សំដែងនៅព្រះរាជដំណាក់នាមឧយ្យានឈ្មោះអម្ពលដ្ឋិកា ជាចន្លោះក្រុងរាជគ្រឹះនឹងនាលន្ទគ្រាម, ទ្រង់ប្រារព្ធនូវសុប្បិយបរិព្វាជកជាអាចារ្យនឹង ព្រហ្មទត្តមាណពជាសិស្សទាស់គ្នា គឺសុប្បិយបរិព្វាជកនិន្ទាព្រះរតនៈត្រៃ ឯព្រហ្មទត្តមាណពប្រឹងសរសើរព្រះរតនៈត្រ័យ ។ ធម៌ក្នុងព្រហ្មជាលសូត្រនោះ ទ្រង់សំដែងអំពីចុល្លសីល, មជ្ឈិមសីល, មហាសីល នឹងទិដ្ឋិ ៦២ ប្រការ ។

## ចុល្លសីលមាន ២៦

១. បាណាតិបាតា បដិវិរតោ សព្វភូតហិតានុកម្បី វៀរស្រឡះចាកបាណាតិបាត អនុគ្រោះដោយប្រយោជន៍ដល់សត្វមានជីវិតទាំងពួង ។

២. អទិន្នាទានា បដិវិរតោ ទិន្នាទាយី វៀរស្រឡះចាកអទិន្នាទាន កាន់យកតែវត្ថុដែលម្ចាស់គេបានឲ្យ ។

៣. អព្រហ្មចរិយំ បហាយ ព្រហ្មចារី លះបង់នូវការប្រព្រឹត្តិធម៌មិនប្រសើរ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ។

៤– មុសាវាទា បដិវិរតោ សច្ចវាទី វៀរស្រឡះចាកការនិយាយកុហក និយាយតែពាក្យពិតមែន ។

៥– បិសុណាយ វាចាយ បដិវិរតោ សមគ្គនន្ទី វៀរ

ស្រឡះចាកសំដីសិកសៀតញុះញង់ ពេញចិត្តនិយាយតែពាក្យដែលនាំឲ្យមានសាមគ្គី ។

៦- ផរុសាយ វាចាយ បដិវិរតោ បេមនិយា វៀរស្រឡះចាកសំដីអាក្រក់គ្រោតគ្រាត និយាយតែសំដីផ្អែមល្ហែមគួរឲ្យជាប់ចិត្តនៃអ្នកផង ។

៧- សម្ផប្បលាបា បដិវិរតោ ធម្មវាទី វៀរស្រឡះចាកសំដីរោយរាយ ឥតផលប្រយោជន៍ និយាយតែអំពីធម៌វិន័យ ។

៨- ពីជគាមភូតគាមសមារម្ភា បដិវិរតោ វៀរស្រឡះចាកការធ្វើពីជគាមនិងភូតគាមឲ្យវិនាស ។

៩- វិរតោ វិកាលភោជនា វៀរចាកការបរិភោគអាហារក្នុងវេលាវិកាល ។

១០- នច្ចគីតវាទិតវិសូកទស្សនា បដិវិរតោ វៀរស្រឡះចាកការមើលនូវរបាំ ស្តាប់នូវចម្រៀងនិងភ្លេងស្រគំស្រួចស្រទ្រី ដែលជាសត្រូវដល់កុសលធម៌ ។

១១- មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតោ វៀរស្រឡះចាកការទ្រទ្រង់ និងប្រដាប់ស្អិតស្អាងកនកាយ ដោយផ្កាកម្រងនិងគ្រឿងក្រអូបនិងគ្រឿងលាបផ្សេង ៗ ។

១២- ឧច្ចាសយនមហាសយនា បដិវិរតោ វៀរស្រ-

ឡះចាកទីដេកទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ប្រសើរ ។

១៣- ជាតរូបរជតប្បដិគ្គហណា បដិវិរតោ វៀរស្រឡះចាកការទទួលនូវមាសនិងប្រាក់ ។

១៤- អាមកធញ្ញប្បដិគ្គហណា បដិវិរតោ វៀរស្រឡះចាកការទទួលនូវធញ្ញជាតិឆៅ ។

១៥- អាមកមំសប្បដិគ្គហណា បដិវិរតោ វៀរស្រឡះចាកការទទួលនូវសាច់ឆៅ ។

១៦- ឥត្ថីកុមារិកប្បដិគ្គហណា បដិវិរតោ វៀរស្រឡះចាកការទទួលនូវស្រីនិងកុមារី ។

១៧- ទាសីទាសប្បដិគ្គហណា បដិវិរតោ វៀរស្រឡះចាកការទទួលនូវខ្ញុំស្រីនិងខ្ញុំប្រុស ។

១៨- អជេឡកប្បដិគ្គហណា បដិវិរតោ វៀរស្រឡះចាកការទទួលនូវពពែនិងចៀម ។

១៩- កុក្កុដសូករប្បដិគ្គហណា បដិវិរតោ វៀរស្រឡះចាកការទទួលនូវមាន់និងជ្រូក ។

២០- ហត្ថិគវស្សវឡវប្បដិគ្គហណា បដិវិរតោ វៀរស្រឡះចាកការទទួលនូវដំរី,គោ,សេះឈ្មោល-ញី ។

២១- ខេត្តវត្ថុប្បដិគ្គហណា បដិវិរតោ វៀរស្រឡះចាកការទទួលនូវស្រែនិងចំការ ។

២២- ទូតេយ្យប្បហិណគមនានុយោគា បដិវិរតោ វៀរស្រឡះចាកការប្រកបនូវទូតកម្ម គឺនាំសំបុត្រឬពាក្យបណ្ដាំដល់គ្រ-ហស្ថនឹងទៅដោយគេប្រើ អំពីផ្ទះមួយទៅផ្ទះមួយ ។

២៣-កយវិក្កយា បដិវិរតោ វៀរស្រឡះចាកការទិញនឹងលក់ទៅវិញ (ដោយបំណងចំណេញបែបជំនួញ) ។

២៤-តុលាកូដកំសកូដមានកូដា បដិវិរតោ វៀរស្រឡះចាកការកោង ឬបន្លំដោយជញ្ជីង នឹងកោងដោយភាជនៈគ្រឿងមាស (ជាដើម) នឹងកោងដោយរង្វាស់រង្វាល់ ។

២៥-ឧក្កោដនវញ្ចននិកតិសាចិយោគា បដិវិរតោ វៀរស្រឡះចាកការប្រកបនូវអំពើវៀច គឺបន្លុសបំភ័ន្ត នឹងបញ្ឆោតបោកប្រាស នឹងបន្លំដោយរបស់ក្លែង ។

២៦- ឆេទនវធពន្ធនវិបរាមោសអាលោបសហសាការា បដិវិរតោ វៀរស្រឡះចាកការកាត់ (នូវអវយវៈមានដៃជាដើម) នឹងសំឡាប់នឹងចង នឹងលាក់ខ្លួនពួនចាំធ្វើអំពើអាក្រក់ នឹងប្លន់ នឹងកំហែងយកទ្រព្យ ។

## មជ្ឈិមសីលមាន ១០

១- ពីជគាមភូតគាមសមារម្ភា បដិវិរតោ វៀរស្រឡះចាកការធ្វើនូវពីជគាម នឹងភូតគាមឲ្យវិនាស ។

២-សន្និធិការបរិភោគា បដិវិរតោ វៀរស្រឡះចាកការបរិភោគនូវវត្ថុដែលសន្សំទុក ។

៣-វិសូកទស្សនា បដិវិរតោ វៀរស្រឡះចាកការមើលនឹងការស្តាប់នូវល្បែងដែលជាសត្រូវដល់កុសលធម៌ ។

៤- ជូតប្បមាទដ្ឋានានុយោគា បដិវិរតោ វៀរស្រឡះចាកការប្រកបនូវល្បែងបាស្កា ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ ។

៥. ឧច្ចាសយនមហាសយនា បដិវិរតោ វៀរស្រឡះចាកទីដេកទីអង្គុយដ៏ខ្ពស់នឹងទីដេកទីអង្គុយដ៏ប្រសើរ ។

៦. មណ្ឌនវិភូសនដ្ឋានានុយោគា បដិវិរតោ វៀរស្រឡះចាកការប្រកបរឿយ ៗ នូវវត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងកាយ ។

៧. តិរច្ឆានកថាយ បដិវិរតោ វៀរស្រឡះចាកការនិយាយតិរច្ឆានកថា ។

៨-វិគ្គាហិកកថាយ បដិវិរតោ វៀរស្រឡះចាកការនិយាយពាក្យប្រណាំងប្រជែង ។

៩. ទូតេយ្យបហិណគមនានុយោគា បដិវិរតោ វៀរស្រឡះចាកការប្រកបរឿយ ៗ នូវទូតកម្ម គឺនាំសំបុត្រឬពាក្យបណ្តាំដល់គ្រហស្ថ នឹងទៅដោយគេបញ្ជូនពីផ្ទះមួយទៅផ្ទះមួយ ។

១០. កុហនលបនា បដិវិរតោ វៀរស្រឡះចាកការនិយាយកុហកលលងផ្សេង ៗ ។

## មហាសីលមាន ៧

១- តិរច្ឆានវិជ្ជាយ មិច្ឆាជីវ បដិវិរតោ វៀរស្រឡះចាកការចិញ្ចឹមជីវិតខុស ដោយតិរច្ឆានវិជ្ជា មានការទាយនូវអវយវៈជាដើម ។

២. វៀរស្រឡះចាកការចិញ្ចឹមជីវិតខុស ដោយតិរច្ឆានវិជ្ជាមានការទាយនូវលក្ខណៈផ្សេង ៗ មានលក្ខណៈនៃកែវមណីជាដើម ។

៣. វៀរស្រឡះចាកការចិញ្ចឹមជីវិតខុស ដោយតិរច្ឆានវិជ្ជាមានការមើលឫក្សយាមជាដើម ។

៤. វៀរស្រឡះចាកការចិញ្ចឹមជីវិតខុស ដោយតិរច្ឆានវិជ្ជា មានទាយចន្ទគ្រោះនឹងសូរ្យគ្រោះជាដើម ។

៥- វៀរស្រឡះចាកការចិញ្ចឹមជីវិតខុស ដោយតិរច្ឆានវិជ្ជាមានការទាយនូវភ្លៀងស្រួល នឹងភ្លៀងមិនស្រួលជាដើម ។

៦- វៀរស្រឡះចាកការចិញ្ចឹមជីវិតខុស ដោយតិរច្ឆានវិជ្ជាមានការទាយនូវពិធីរៀបអាវាហមង្គល នឹងវិវាហមង្គលជាដើម ។

៧- វៀរស្រឡះចាកការចិញ្ចឹមជីវិតខុស ដោយតិរច្ឆានវិជ្ជាមានការបន់ទេវតា នឹងបន់ខ្មោចបិសាចជាដើម ។

### ទិដ្ឋិ ៦២

មានសមណព្រាហ្មណ៍ ១ ពួក ជាអ្នកប្រកបដោយ

បុព្វន្តកប្បទិដ្ឋិ ជាអ្នកយល់ឃើញនូវចំណែកនៃខន្ធខាងដើម (ខន្ធក្នុងអតីតកាល) ប្រារព្ធនូវចំណែកនៃខន្ធខាងដើម ហើយពោលនូវចំណែកនៃទិដ្ឋិច្រើនប្រការ ដោយហេតុ ១៨ យ៉ាង ។ ក្នុងហេតុ១៨ យ៉ាងនោះ មានពួកសមណព្រាហ្មណ៍ដែលជាអ្នកបញ្ញត្ត៤ ពួកគឺ

ក) ពួកសមណព្រាហ្មណ៍ជា សស្សតវាទ (អ្នកពោលប្រកាន់ជាទៀង ដោយហេតុ៤យ៉ាងគឺ

១- ព្រោះអាស្រ័យសេចក្តីព្យាយាម ហើយបានដល់នូវចេតោសមាធិ កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏រឭកជាតិរបស់ខ្លួនឯងបាន តាំងអំពី១ជាតិ ២ជាតិ រហូតដល់ ១សែនជាតិ ទើបបញ្ញត្តខ្លួននិងលោកជាទៀង ។

២- ព្រោះអាស្រ័យសេចក្តីព្យាយាម ហើយបាននូវចេតោសមាធិ កាលបើចិត្តតាំងខ្ជាប់ខ្ជួនហើយ ក៏រឭកជាតិរបស់ខ្លួនឯងបានតាំងអំពី ១ សំវដ្តវិវដ្តកប្ប រហូតដល់ ១០ សំវដ្តវិវដ្តកប្ប ទើបបញ្ញត្តខ្លួននិងលោកជាទៀង ។

៣- ព្រោះអាស្រ័យសេចក្តីព្យាយាម ហើយបាននូវចេតោសមាធិ កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏រលឹកជាតិរបស់ខ្លួនឯងបានតាំងអំពី ១០ សំវដ្តវិវដ្តកប្ប រហូតដល់ ៤០ សំវដ្តវិវដ្តកប្ប ទើបបញ្ញត្តខ្លួននិងលោកជាទៀង ។

៤– ព្រោះអាស្រ័យសេចក្ដីត្រិះរិះពិចារណា ស្ទាបស្ទង់មើលដោយបញ្ញារបស់ខ្លួនឯង ហើយសំដែងថាខ្លួននឹងលោកជាសស្សតៈទៀង សស្សតៈ ផុតពូជ តាំងនៅនឹងថ្កល់ដូចជាកំពូលភ្នំ ឬដូចជាសសរគោល ឯសត្វទាំងនោះ តែងអន្ទោលទៅមក តែងច្យុត តែងកើតវិញ ។

១) ពួកសមណព្រាហ្មណ៍ ជាអ្នកប្រកបដោយ ឯកច្ចសស្សត ឯកច្ចអសស្សតទិដ្ឋិ គឺយល់ថាពួកលោកខ្លះទៀង ពួកខ្លះមិនទៀង តែងបញ្ញត្តខ្លួននឹងលោកថាទៀងខ្លះ មិនទៀងខ្លះ ដោយហេតុ ៤ យ៉ាងគឺ

៥– ព្រោះរលឹកបានត្រឹមតែជាតិ ដែលខ្លួនធ្លាប់កើតជាមហាព្រហ្ម ហើយច្យុតមកកាន់អត្តភាពជាមនុស្សប៉ុណ្ណោះ មិនអាចរលឹកនូវជាតិឲ្យហួសអំពីនោះទៅទៀតបាន ទើបបញ្ញត្តខ្លួននឹងលោកថាទៀងខ្លះ មិនទៀងខ្លះ ។

៦– ព្រោះរឭកបានត្រឹមតែជាតិដែលខ្លួនធ្លាប់កើតជាទេវតា ឈ្មោះ ខិឌ្ឌាបទោសិកា ( អ្នកវិនាសខ្លួនព្រោះល្បែង ) គឺទេពតាដែលជាប់ចិត្តតែនឹងល្បែងភ្លេចបរិភោគអាហារ ហើយច្យុតមកកាន់អត្តភាពជាមនុស្សប៉ុណ្ណោះមិនអាចរឭកនូវជាតិឲ្យហួសអំពីនោះទៅទៀតបាន ទើបបញ្ញត្តខ្លួននឹងលោកថាទៀងខ្លះ មិនទៀងខ្លះ ។

៧- ព្រោះរឭកបានត្រឹមតែជាតិដែលខ្លួនធ្លាប់កើតជាទេវតាឈ្មោះ មនោបទោសិកា (អ្នកវិនាសខ្លួនព្រោះចិត្តប្រទូស្ត) គឺទេវតាអ្នកធ្វើចិត្តឲ្យ

ប្រទុស្តដល់គ្នានឹងគ្នាហួសវេលា ហើយច្យុតមកកាន់អត្តភាពជាមនុស្ស ប៉ុណ្ណោះមិនអាចនឹងរឭកឲ្យហួសអំពីនោះទៅទៀតបាន ទើបបញ្ញត្តខ្លួននឹងលោកថាទៀងខ្លះ មិនទៀងខ្លះ ។

៨– ព្រោះអាស្រ័យសេចក្តីត្រិះរិះពិចារណាស្ទាបស្ទង់មើល ដោយប្រាជ្ញារបស់ខ្លួនឯងហើយសំដែងថា ធម្មជាតិដែលហៅថា ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ជាសភាវៈមិនទៀងតែមិនស្ថិតស្ថេរ តែងប្រែប្រួលទៅវិញជាធម្មតា ចំណែកខាងធម្មជាតិដែលហៅថា ចិត្ត មនោឬវិញ្ញាណ នេះជាសភាវៈទៀងទាត់ឋិតថេរមិនប្រែប្រួលទៅវិញជាធម្មតា ។

គ) ពួកសមណព្រាហ្មណ៍ជាអ្នកប្រកបដោយ អន្តានន្តទិដ្ឋិ បញ្ញត្តថា លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ដោយហេតុ ៤ យ៉ាងគឺ

៩– ព្រោះអាស្រ័យសេចក្តីព្យាយាម ហើយបាននូវចេតោសមាធិ កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏មានសេចក្តីសំគាល់ថា លោកមានទីបំផុត ទើបបញ្ញត្តថា លោកមានទីបំផុត មានផ្លូវជុំវិញ គឺមូលជុំវិញ ។

១០– ព្រោះអាស្រ័យសេចក្តីព្យាយាម ហើយបាននូវចេតោសមាធិ កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏មានសេចក្តីសំគាល់ថា លោកមិនមានទីបំផុត ទើបបញ្ញត្តថា លោកមិនមានទីបំផុត ។

១១- ព្រោះអាស្រ័យនូវសេចក្ដីព្យាយាម ហើយបាននូវចេតោសមាធិ កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏មានសេចក្ដីសំគាល់ថា លោកមានទីបំផុតក្នុងទិសខាងលើ និងទិសខាងក្រោម លោកមិនមានទីបំផុតក្នុងទិសទទឹង គឺទិសតូច ៗ ទើបបញ្ញត្តថា លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ។

១២- ព្រោះអាស្រ័យសេចក្ដីត្រិះរិះពិចារណា ស្ទាបស្ទង់មើល ដោយបញ្ញារបស់ខ្លួនឯង ហើយសំដែងថាលោកនេះមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន ។

ឃ) ពួកសមណព្រាហ្មណ៍ជាអ្នកប្រកបដោយ អមរាវិក្ខេបទិដ្ឋិ គឺអ្នកនិយាយពោះសំដីមិនឲ្យស្លាប់ខ្លួន កាលបើមាននរណាមួយសាកសួរ ប្រស្នាក្នុងកុសលនិងអកុសលនោះ ៗ ក៏ដល់នូវការពោះវាចា ពោះសំដីមិនឲ្យស្លាប់ពាក្យ ដោយហេតុ ៤ យ៉ាងគឺ

១៣- ព្រោះខ្លាចមុសាវាទ ខ្ពើមមុសាវាទ កាលបើមានអ្នកណាមួយសាកសួរប្រស្នាក្នុងកុសលនិងអកុសលនោះ ៗ ក៏ដល់នូវការពោះវាចាពោះសំដីមិនឲ្យស្លាប់ពាក្យថា សេចក្ដីយល់ឃើញរបស់ខ្ញុំថា យ៉ាងនេះក៏មិនមែន ថាយ៉ាងនោះក៏មិនមែន ថាយ៉ាងដទៃក៏មិនមែន ថាមិនមែនក៏ទេ ថាមិនមែនទេ ក៏មិនមែនដែរ ៗ

១៤– ព្រោះខ្លាចឧបាទាន ខ្ពើមឧបាទាន កាលបើមាននរណាមួយសាកសួរប្រស្នាកុសលនិងអកុសលនោះៗ ក៏ដល់នូវការបោះវាចាបោះសំដីមិនឲ្យស្លាប់ពាក្យថា សេចក្ដីយល់ឃើញរបស់ខ្ញុំថា យ៉ាងនេះក៏មិនមែន ថាយ៉ាងនោះក៏មិនមែន ថាយ៉ាងដទៃក៏មិនមែន ថាមិនមែនក៏ទេ ថាមិនមែនទេ ក៏មិនមែនដែរ ។

១៥– ព្រោះខ្លាចពាក្យសួរដេញដោល ព្រោះធុញថប់នឹងពាក្យសួរដេញដោល កាលបើមានអ្នកណាមួយមកសួរប្រស្នាកុសលនិងអកុសលនោះៗ ក៏ដល់នូវការបោះវាចាបោះសំដីមិនឲ្យស្លាប់ពាក្យថាសេចក្ដីយល់ឃើញរបស់ខ្ញុំ ថាយ៉ាងនេះក៏មិនមែន ថាយ៉ាងនោះក៏មិនមែនថាយ៉ាងដទៃក៏មិនមែន ថាមិនមែនក៏ទេ ថាមិនមែនទេ ក៏មិនមែនដែរ ។

១៦– ព្រោះហេតុតែខ្លួនមានបញ្ញាទន់ ហេតុតែខ្លួនល្ងង់ខ្លៅ កាលបើមានអ្នកណាមួយសាកសួរប្រស្នាអកុសលនិងកុសលនោះៗ ក៏ដល់នូវការបោះវាចាបោះសំដីមិនឲ្យស្លាប់ខ្លួនថា សេចក្ដីយល់ឃើញរបស់ខ្ញុំថា យ៉ាងនេះក៏មិនមែន ថាយ៉ាងដទៃក៏មិនមែន ថាមិនមែនក៏ទេ ថាមិនមែនទេ ក៏មិនមែនដែរ ។

ង) ពួកសមណព្រាហ្មណ៍ជាអ្នកប្រកបដោយ អធិច្ចសមុប្បន្នទិដ្ឋិ គឺអ្នកបញ្ញត្តខ្លួននិងលោកថាកើតឡើងដោយឥតហេតុ ដោយហេតុ ២ យ៉ាងគឺ

១៧– ព្រោះរលឹកបានត្រឹមតែជាតិដែលខ្លួនធ្លាប់កើតជាទេវតាឈ្មោះ អសញ្ញីសត្វ គឺសត្វមិនមានសញ្ញា ហើយក៏ច្យុតមកកាន់អត្តភាពជាមនុ-ស្សត្រឡប់ជាមានសញ្ញាកើតឡើងវិញ មិនបានរឭកឲ្យហួសអំពីនោះទៅទៀតបានឡើយ ទើបបញ្ញត្តខ្លួននិងលោកថាកើតឡើងដោយឥតហេតុ ។

១៨– ព្រោះអាស្រ័យសេចក្តីត្រិះរិះពិចារណា ស្ទាបស្ទង់មើលដោយប្រាជ្ញារបស់ខ្លួនឯង ហើយពោលយ៉ាងនេះថា ខ្លួននិងលោកកើតឡើងដោយឥតហេតុ ។

មានសមណព្រាហ្មណ៍១ពួក ជាអ្នកប្រកបដោយ អបរន្តកប្ប ទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញនូវចំណែកនៃខន្ធខាងមុខ គឺខន្ធក្នុងអនាគតកាល ហើយសំដែងនូវចំណែកនៃទិដ្ឋិច្រើនប្រការ ដោយហេតុ ៤៤ ។ ក្នុងហេតុទាំង៤៤នោះ មានពួកសមណព្រាហ្មណ៍ដែលជាអ្នកបញ្ញត្ត៥ពួកគឺ

ក) ពួកសមណព្រាហ្មណ៍ដែលជាអ្នកប្រកបដោយ ឧទ្ធមាឃត-នទិដ្ឋិ ជាសញ្ញីវាទ (ប្រកាន់ថាខ្លួនកាលស្លាប់ទៅមានសញ្ញា) បញ្ញត្តនូវខ្លួនថាមានសញ្ញាខាងមុខអំពីសេចក្តីស្លាប់ ដោយហេតុ១៦យ៉ាងគឺ

១៩– បញ្ញត្តថា ខ្លួនមានរូប ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២០– បញ្ញត្តថា ខ្លួនមិនមានរូប ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២១– បញ្ញត្តថា ខ្លួនមានរូបខ្លះ មិនមានរូបខ្លះ ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២២– បញ្ញត្តថា ខ្លួនមានរូបក៏មិនមែន មិនមានរូបក៏មិនមែន ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២៣– បញ្ញត្តថា ខ្លួនមានទីបំផុត ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២៤– បញ្ញត្តថា ខ្លួនមិនមានទីបំផុត ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២៥– បញ្ញត្តថា ខ្លួនមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២៦– បញ្ញត្តថា ខ្លួនមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២៧– បញ្ញត្តថា ខ្លួនមានសញ្ញាដូចគ្នា ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២៨– បញ្ញត្តថា ខ្លួនមានសញ្ញាផ្សេងគ្នា ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

២៩- បញ្ញត្តថា ខ្លួនមានសញ្ញាតិច ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

៣០- បញ្ញត្តថា ខ្លួនមានសញ្ញាច្រើន ឥតប្រមាណមិនបាន ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

៣១- បញ្ញត្តថា ខ្លួនមានសុខតែម្យ៉ាង ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

៣២- បញ្ញត្តថា ខ្លួនមានទុក្ខតែម្យ៉ាង ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

៣៣- បញ្ញត្តថា ខ្លួនមានទាំងសុខទាំងទុក្ខ ជាអត្តភាពមិនមាន រោគ ស្លាប់ហើយជាសត្វមានសញ្ញា ។

៣៤- បញ្ញត្តថា ខ្លួនមិនមានទុក្ខមិនមានសុខ ជាអត្តភាពមិនមាន រោគស្លាប់ហើយជាសត្វមានសញ្ញា ។

១) ពួកសមណព្រាហ្មណ៍ ជាអ្នកប្រកបដោយ ឧទ្ធមាឃ-តនិកទិដ្ឋិ ជាអសញ្ញីវាទ (ប្រកាន់ថា ខ្លួនកាលស្លាប់ទៅមិនមានសញ្ញា) បញ្ញត្តខ្លួនថាមិនមានសញ្ញាខាងមុខអំពីសេចក្តីស្លាប់ ដោយហេតុ ៨ យ៉ាងគឺ

៣៥- បញ្ញត្តថាខ្លួនមានរូប ជាអត្តភាពមិនមានរោគ ស្លាប់ហើយ ជាសត្វមិនមានសញ្ញា ។

៣៦- បញ្ញត្តថា ខ្លួនមិនមានរូប ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមិនមានសញ្ញា ។

៣៧- បញ្ញត្តថា ខ្លួនមានរូបខ្លះ មិនមានរូបខ្លះ ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមិនមានសញ្ញា ។

៣៨- បញ្ញត្តថា ខ្លួនមានរូបក៏មិនមែន មិនមានរូបក៏មិនមែន ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមិនមានសញ្ញា ។

៣៩. បញ្ញត្តថា ខ្លួនមានទីបំផុត ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមិនមានសញ្ញា ។

៤០- បញ្ញត្តថា ខ្លួនមិនមានទីបំផុត ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមិនមានសញ្ញា ។

៤១- បញ្ញត្តថា ខ្លួនមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមិនមានសញ្ញា ។

៤២- បញ្ញត្តថា ខ្លួនមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមិនមានសញ្ញា ។

គ) ពួកសមណព្រាហ្មណ៍ ជាអ្នកប្រកបដោយ ឧទ្ធមាឃតនិកទិដ្ឋិ ជា នេវសញ្ញីនាសញ្ញីវាទ បញ្ញត្តនូវខ្លួនថាមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន (មានសញ្ញាដូចជាគ្មានសញ្ញា គឺមានសញ្ញាដ៏ល្អិត) ខាងមុខអំពីសេចក្ដីស្លាប់ ដោយហេតុ ៨ យ៉ាងគឺ

៤៣- បញ្ញត្តថា ខ្លួនមានរូប ជាអត្តភាពមិនមានរោគ ស្លាប់ហើយ ជាសត្វមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

៤៤- បញ្ញត្តថា ខ្លួនមិនមានរូប ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

៤៥- បញ្ញត្តថា ខ្លួនមានរូបខ្លះ មិនមានរូបខ្លះ ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

៤៦- បញ្ញត្តថា ខ្លួនមានរូបក៏មិនមែន មិនមានរូបក៏មិនមែន ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

៤៧- បញ្ញត្តថា ខ្លួនមានទីបំផុត ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

៤៨- បញ្ញត្តថា ខ្លួនមិនមានទីបំផុត ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

៤៩- បញ្ញត្តថា ខ្លួនមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

៥០- បញ្ញត្តថា ខ្លួនមានទីបំផុត ក៏មិនមែន មិនមានទីបំផុតក៏មិន

មែន ជាអត្តាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញា ក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

ឃ) ពួកសមណព្រាហ្មណ៍ជា ឧច្ឆេទវាទ (អ្នកពោលថាដាច់សូន្យ) បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ដោយហេតុ ៧ យ៉ាងគឺ

៥១-បញ្ញត្តថា ខ្លួនមានរូបប្រកបដោយមហាភូតរូប ៤ កើតមកអំពីមាតាបិតា ស្លាប់ហើយរមែងដាច់សូន្យមិនកើតទៀត ។

៥២-បញ្ញត្តថា ខ្លួនមានរូបជាទិព្វ ជាកាមាវចរទេវតា (ត្រាច់ទៅក្នុងកាមភព) មានកវឡិង្កាហារជាចំណី ស្លាប់ហើយរមែងដាច់សូន្យមិនកើតទៀត ។

៥៣-បញ្ញត្តថា ខ្លួនមានរូបជាទិព្វ កើតដោយឈានចិត្ត មានអវយវៈធំតូចគ្រប់សព្វ មានឥន្ទ្រិយមិនថោកថយ ស្លាប់ហើយរមែងដាច់សូន្យមិនកើតទៀត ។

៥៤-បញ្ញត្តថា ពួកសត្វដែលចូលទៅកាន់ អាកាសានញ្ចាយតនភព ស្លាប់ហើយរមែងដាច់សូន្យមិនកើតទៀត ។

៥៥-បញ្ញត្តថា ពួកសត្វដែលចូលទៅកាន់វិញ្ញាណញ្ចាយតនភព ស្លាប់ហើយរមែងដាច់សូន្យមិនកើតទៀត ។

៥៦-បញ្ញត្តថា ពួកសត្វដែលចូលទៅកាន់អាកិញ្ចញ្ញាយតនកព ស្លាប់ហើយរមែងដាច់សូន្យ មិនកើតទៀត ។

៥៧- បញ្ញត្តថា ពួកសត្វដែលចូលទៅកាន់នេវសញ្ញានាសញ្ញាយតនកព ស្លាប់ហើយរមែងដាច់សូន្យមិនកើតទៀត ។

ង) ពួកសមណព្រាហ្មណ៍ ជា ទិដ្ឋធម្មនិព្វានវាទ (អ្នកពោលនូវនិព្វាន គឺសេចក្តីរលត់ទុក្ខក្នុងបច្ចុប្បន្ន) បញ្ញត្តព្រះនិព្វានក្នុងបច្ចុប្បន្នថា ជាគុណយ៉ាងក្រៃលែងរបស់សត្វដែលមាននៅ ដោយហេតុ ៥ យ៉ាងគឺ

៥៨- បញ្ញត្តថា ខ្លួនដែលឲ្យគេបំរើផ្គត់ផ្គង់ស្កប់ស្កល់ដោយកាមគុណ ទើបឈ្មោះថាជាអត្តភាពបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

៥៩- បញ្ញត្តថា ខ្លួនដែលបានស្ងប់ស្ងាត់ចាកកាម ស្ងប់ស្ងាត់ចាកអកុសលធម៌ ហើយបានដល់នូវបឋមជ្ឈានប្រកបដោយ វិតក្កៈ វិចារៈ បីតិនឹង សុខៈ កើតអំពីសេចក្តីស្ងប់ស្ងាត់ ទើបឈ្មោះថាជាអត្តភាព បានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

៦០- បញ្ញត្តថា ខ្លួនដែលបានរម្ងាប់ វិតក្កៈ វិចារៈអស់ហើយ បានដល់នូវទុតិយជ្ឈាន ជាធម្មជាតផ្សាយផ្សាយ្រ៉ាកដក្នុងខ្លួន មានសេចក្តីជ្រះថ្លានូវសទ្ធា ជាសភាពនៃចិត្តដ៏ខ្ពស់ឯក ជាឈានមិនមានវិតក្កៈ វិចារៈ មាន

តែបីតិនិងសុខៈ កើតអំពីសមាធិ ទើបឈ្មោះថាជាអត្តភាពបានដល់នូវ-ព្រះនិព្វានក្នុងបច្ចុប្បន្ន ។

៦១– បញ្ញត្តថា ខ្លួនដែលប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួនផង បានសោយសុខដោយនាមកាយផង ព្រោះអស់ទៅនៃបីតិ ក៏បានដល់នូវតតិយជ្ឈានជាឈានដែលប្រកបដោយឧបេក្ខា និងសុខៈ ទើបឈ្មោះថាជាអត្តភាពបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

៦២- បញ្ញត្តថា ខ្លួនដែលបានលះបង់សុខផង លះបង់ទុក្ខផង មានសោមនស្សនិងទោមនស្សអស់ហើយក្នុងកាលមុន ហើយបានដល់នូវចតុត្ថជ្ឈាន ដែលជាឈានមានអារម្មណ៍មិនមែនទុក្ខ មិនមែនសុខ គឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធកើតអំពីឧបេក្ខាវេទនា ទើបឈ្មោះថាជាអត្តភាពបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

សាមញ្ញផលសូត្រ ព្រះដ៏មានព្រះភាគទ្រង់សំដែងនៅវត្តអម្ពវ័ន (ព្រៃស្វាយ) ជារបស់ពេទ្យជីវកកោមារភច្ច ទៀបក្រុងរាជគ្រឹះ, ទ្រង់សំដែងចំពោះព្រះបាទអជាតសត្តុ ស្តេចដែនមគធៈ ជាព្រះរាជបុត្រនៃព្រះរាជទេវីព្រះនាមវេទេហី ; ធម៌ក្នុងព្រហ្មជាលសូត្រនោះទ្រង់សំដែងអំពីសាមញ្ញផល គឺផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង, ទ្រង់លើកយកមកសំដែង គឺ សីលសំវរៈ, ឥន្ទ្រិយសំវរៈ, សតិ-

សម្បជញ្ញៈ, សន្តុដ្ឋិ, នីវរណៈ ៥, រូបជ្ឈាន ៤ វិជ្ជា ៨,. វិមុត្តិ ២, កាសរៈ ៣ ។

កាលសង្គាយនាព្រះសូត្រចប់ហើយ ទើបលោកប្រមួលចាត់ជាពួក ៗ ហៅថានិកាយមាន ៥ គម្ពីរគឺ

១- ទីឃនិកាយ មាន៣៤ សូត្រ មានព្រហ្មជាលសូត្រជាដើម

២- មជ្ឈិមនិកាយ មាន ១៥២ សូត្រ មានមូលបរិយាយសូត្រជាដើម ។

៣- សំយុត្តនិកាយ មាន ៧៧៦២ សូត្រ មានឱឃតរណសូត្រជាដើម ។

៤- អង្គុត្តរនិកាយ មាន ៩៥៥៧ សូត្រ មានចិត្តបរិយាទានសូត្រជាដើម ។

៥- ខុទ្ទកនិកាយ ចែកចេញជាគម្ពីរមាន ១៥ គម្ពីរទៀតគឺ

១- ខុទ្ទកបាឋ; ២- ធម្មបទ; ៣- ឧទាន; ៤- ឥតិវុត្តកៈ; ៥- សុត្តនិបាត; ៦- វិមានវត្ថុ; ៧- បេតវត្ថុ ៨- ថេរគាថា; ៩- ថេរីគាថា; ១០- ជាតក; ១១- និទ្ទេស; ១២- បដិសម្ភិទា; ១៣- អបទាន, ១៤- ពុទ្ធវំស; ១៥- ចរិយាបិដក ។

និកាយទាំង៥នេះ សរសេរជាអក្សរបំប្រួញថា: ទី., ម., សំ., អំ., ខុ., ។

ព្រះសូត្រទាំងអស់រួមជាបិដកមួយ ហៅថា សុត្តន្តបិដកចែកជាធម្ម-ក្ខន្ធមាន ២១.០០០ ព្រះធម្មក្ខន្ធ ចែកជាសៀវភៅបោះពុម្ព៥៧ក្បាល ។

## ព្រះសូត្រទាំងអស់មានអត្ថ ៦ ប្រការគឺ

១- សូចនតោ ព្រោះសំដែងចេញនូវប្រយោជន៍ដល់សត្វដទៃដោយល្អ ។

២- សុវុត្តតោ ព្រោះសំដែងអនុលោមតាមអធ្យាស្រ័យនឹងបំរើ របស់វេនេយ្យសត្វ ។

៣- សវនតោ ព្រោះឲ្យសម្រេចប្រយោជន៍ដល់សត្វសត្វ ដូចស្រូវសន្ទូងឲ្យសម្រេចផល ។

៤- សូទនតោ ព្រោះជាទីហូរចេញនៃផល ដូចដោះមេគោដែលជាទីហូរចេញនៃទឹកដោះ ។

៥- សុត្តាណា ព្រោះរក្សាទុកនូវប្រយោជន៍ដោយល្អដល់សត្វអ្នកប្រតិបត្តិ ។

៦- សុត្តសភាគតោ ព្រោះជាមគ្គាដ៏ត្រង់បើកឲ្យសត្វអ្នកប្រតិ-បត្តិដើរឆ្ពោះទៅស្ថានព្រះនិព្វាន ដូចជាខ្សែបន្ទាត់នៃជាងឈើ ។

លុះសង្គាយនាព្រះសូត្រចប់ហើយ ទើបលោកសង្គាយនាព្រះបរ-មត្ថតទៅទៀត ។ ព្រះបរមត្ថដែលលោកលើកសំដែងនោះ បានដល់ព្រះអភិធម្មទាំង៧គម្ពីរ ។

## មូលហេតុដែលទ្រង់សំដែងព្រះអភិធម្ម

នាកាលសម្ដេចព្រះពិជិតមារជាម្ចាស់ ទ្រង់បានសំរេចនូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ ៧ ព្រះវស្សាហើយ ទ្រង់ធ្វើនូវយមកបាដិហារ្យកំចាត់បង់នូវអតិមានះ នៃពួកតិត្ថិយអន្យតិរ្ថិយសេយ្យសាសន៍ទាំងឡាយ ដែលជាគូប្រណាំងប្រជែងនឹងព្រះអង្គក្នុងសម័យនោះ នៅជិតដើមគណ្ឌាម្ពព្រឹក្ស (ដើមស្វាយដែលឧយ្យានបាលឈ្មោះគណ្ឌៈដាំ); រួចស្រេចហើយ ទើបស្ដេចឡើងទៅគង់ចាំវស្សានៅតាវត្តឹសពិភព ដើម្បីទេសនាព្រះអភិធម្មប្រោសព្រះពុទ្ធមាតា ជាបដិការកិច្ច តបស្នងព្រះគុណថ្លៃ, ទ្រង់ប្រថាប់នៅលើបណ្ឌុកម្ពលសិលាអាសន៍ ទៀបគល់នៃដើមបារិច្ឆត្តកព្រឹក្ស ។ ក្សណនោះ, ទេវតាទាំងឡាយក៏មកអង្គុយចោមរោមជុំវិញព្រះអង្គ ដើម្បីទទួលនូវរសព្រះសទ្ធម្ម, ឯសម្ដេចព្រះសហស្សន័យន៍ បានស្ដេចទៅអញ្ជើញព្រះពុទ្ធមាតាអំពីតុសិតភព មកកាន់មហាសន្និបាតក្នុងតាវត្តឹសពិភព ។ លុះព្រះពុទ្ធមាតាស្ដេចមកដល់ហើយ ទើបព្រះពុទ្ធអង្គទ្រង់សំដែងព្រះអភិធម្ម កាលចប់ព្រះអភិធម្មទេសនាហើយ ព្រះពុទ្ធមាតាបានសម្រេចសោតាបត្តិផល ។

## ព្រះអភិធម្មមាន ៧ គម្ពីរ

១- សង្គណី; ២. វិភង្គ; ៣- ធាតុកថា; ៤. បុគ្គលបញ្ញត្តិ; ៥. កថាវត្ថុ; ៦. យមក; ៧. បដ្ឋាន ។

គម្ពីរទាំង ៧ នេះសរសេរអក្សរបំប្រួញថាៈ សំ., វិ., ធា., បុ., ក., យ., ប., ។

## គម្ពីរព្រះធម្មសង្គណីចែកជា ៤ កណ្ឌគឺ

១– ចិត្តវិភត្តិកណ្ឌ ចែកចិត្តចេតសិកជាដើម ។

២– រូបវិភត្តិកណ្ឌ ចែករូបជាដើម ។

៣. និក្ខេបរាសិកណ្ឌ ចែកធម៌ក្នុងបទមាតិកានោះ ។

៤– អត្ថុទ្ធារកណ្ឌ ចែកអត្ថជាដើម ។

គម្ពីរវិភង្គ ចែកវិភង្គ ១៨ ប្រការមានខន្ធវិភង្គជាដើម ។

គម្ពីរធាតុកថា ពោលអំពីការសង្គ្រោះធម៌ ដែលចាត់ជាកង ធាតុផ្សេងៗជាដើម ។

គម្ពីរបុគ្គលបញ្ញត្តិ ពោលអំពីបញ្ញត្តិ ៦ ប្រការមានខន្ធបញ្ញត្តិ ជាដើម ។

គម្ពីរកថាវត្ថុ ចែកព្រះសូត្រជាចំណែកនៃសកវាទីនឹងបរវាទជា ដើម ។

គម្ពីរយមក ចែកធម៌ចេញជាគូៗ ដូចធម៌ជាចំណែកកុសលនឹង មូលនៃធម៌ជាចំណែកកុសលជាដើម ។

គម្ពីរមហាបដ្ឋាន ចែកធម៌ប្រកបដោយហេតុនិងបច្ច័យជាដើម ។

## ព្រះអភិធម្មមានអត្ថ ៥ ប្រការគឺ

១–វុឌ្ឍិមន្តា មានអត្ថថា ធម៌មានសេចក្ដីចំរើន ។

២- សលក្ខណា មានអត្ថថាធម៌ប្រកបដោយសេចក្ដីកំណត់ ។

៣– បូជិតា មានអត្ថថា ធម៌គួរបូជា ។

៤– បរិច្ឆិន្នា មានអត្ថថា ធម៌ជាចំណែកកាយមិនច្រឡំគ្នា ។

៥- អធិកា មានអត្ថថា ធម៌ដ៏ក្រៃលែង ។

ព្រះអភិធម្មទាំង ៧ គម្ពីរនេះរួមជាបិដកមួយហៅថាអភិធម្មបិដក ចែកជាធម្មក្ខន្ធបាន ៤២.០០០ ព្រះធម្មក្ខន្ធ, ព្រះពុទ្ធអង្គទ្រង់សំដែង ៣ ខែទើបចប់ បូករួមធម្មក្ខន្ធក្នុងបិដកទាំង ៣ ត្រូវជា ៨៤០០០ ព្រះធម្មក្ខន្ធ ចែកជាសៀវភៅបោះពុម្ព ៣០ ក្បាល ។

ក្នុងកាលជាទីបំផុតនៃការបុច្ឆាវិស្សជ្ជនា បិដកទីមួយ ១ ព្រះអរហន្តទាំង ៥០០ អង្គ បានធ្វើនូវគណៈស្វាធ្យាយ តាមន័យដែលបានសង្គាយនាមកហើយនោះឯង ។

សង្គាយនាគ្រាបឋមនេះ ចាប់ធ្វើឡើងក្នុងកាលកប់អំពីពុទ្ធបរិនិព្វាន កន្លងទៅហើយបាន ៣ ខែ, ព្រះមហាកស្សបត្ថេរជាប្រធាន ការកសង្ឃ ៥០០ អង្គ, ធ្វើ ៧ ខែទើបសម្រេច ព្រះបាទអជាតសត្រូវ ជាសាសនូបត្ថម្ភក៍ ។ ក្នុងកាលចប់បឋមសង្គាយនានោះ ហេតុអស្ចារ្យជាច្រើនបែបបានកើតប្រាកដឡើង, មហាប្រថពីដែលមានទឹកជាទីបំផុត ក៏ញាប់ញ័រ

កក្រើកខ្ទ័រខ្ទារ ហាក់ដូចជាមានចិត្តរីករាយបន្លឺនូវសព្ទសាធុការថា "សាសនាព្រះសាក្យមុនីសម្ពុទ្ធជាម្ចាស់នេះ ព្រះមហាកស្សបត្ថេរបានធ្វើឲ្យប្រតិឋិតគង់វង់រុងរឿងរហូតដល់គ្រប់ ៥០០០ ព្រះវស្សា ។

ព្រោះសង្គាយនានេះ ការកសង្ឃ ៥០០ អង្គធ្វើ ទើបហៅថា "បញ្ចសតិកាសង្គាយនា" ក៏បាន, ព្រោះការកសង្ឃទាំងនោះ សុទ្ធតែជាព្រះថេរៈអរហន្តខីណាស្រព ទើបហៅថា "ថេរិកាសង្គាយនា" ក៏បាន ។

ចប់បឋមសង្គីតិ.

# ទុតិយសង្គីតិ

យថាវុត្តក្កមេន គច្ឆន្តេសុ រត្តិន្ទិវេសុ នាកាលយប់នឹងថ្ងៃ កន្លងទៅដោយលំដាប់ រាប់អំពីពុទ្ធបរិនិព្វានមក កន្លងទៅហើយបាន ១០០ ឆ្នាំ; គ្រានោះ ពួកវជ្ជីបុត្តកភិក្ខុ (ពួកភិក្ខុជាបុត្រនៃជនដែលនៅក្នុងដែនវជ្ជី) នៅក្រុងវេសាលីមានគំនិតលាមក បានបញ្ញត្តឡើងនូវវត្ថុ ១០ ប្រការ ដែលផ្ទុយខុសនឹងព្រះវិន័យពុទ្ធប្បញ្ញត្តិ ថាជារបស់គួរមិនត្រូវអាបត្តិអ្វីឡើយ ៗ ចំណែកព្រះបាទកាលាសោក ជាព្រះរាជបុត្រនៃព្រះបាទសុសុនាគ ទ្រង់ចូលជាបក្សពួកនៃភិក្ខុទាំងឡាយនោះ ព្រោះជឿតាមពាក្យណែនាំពិតទូល ៗ ក៏សម័យនោះ ព្រះអរហន្តមួយអង្គ ប្រកបដោយឫទ្ធិ ព្រះនាម ព្រះយសត្ថេរ ជាបុត្រនៃកាកណ្ឌកព្រាហ្មណ៍ លោកត្រាច់ទៅក្នុងស្រុកវជ្ជីគ្រាម បានជ្រាបនូវវត្ថុ ១០ ប្រការនោះហើយ ក៏មានព្រះទ័យបំណងនឹងរម្ងាប់នូវអធិករណ៍, ទើបនិមន្តទៅកាន់ព្រៃមហាវ័ន ក្នុងកូដាគារសាលា ទៀបក្រុងវេសាលី ៗ ក្សណនោះ ពួកវជ្ជីបុត្តកភិក្ខុ បាននាំយកភាជនៈសំរឹទ្ធដាក់ទឹកឲ្យពេញហើយ ដំកល់ទុកក្នុងកណ្ដាលទីប្រជុំសង្ឃក្នុងថ្ងៃឧបោសថ ប្រកាសដល់ពួកឧបាសកឧបាសិកាថា ហៃអ្នកទាំងឡាយ! ចូរប្រគេនប្រាក់ដល់សង្ឃ, សង្ឃមានកិច្ចត្រូវការដោយគ្រឿងបរិក្ខារបែបនេះ ៗ ព្រះយសត្ថេរក៏ហាមឃាត់ថា "អ្នកទាំងឡាយ កុំប្រគេន ព្រោះប្រាក់ជាវត្ថុមិនសមគួរដល់សង្ឃទេ", តែពួកឧបាសកទាំងនោះមិនស្ដាប់ ចេះតែនាំគ្នាប្រគេនទៅ ៗ ព្រឹកឡើងពួកវជ្ជីបុត្តកភិក្ខុ នាំយក

ប្រាក់តាំងនោះមកបែងចែកគ្នា, បានបែងមួយចំណែក នាំយកទៅប្រគេនព្រះយសត្ថេរផង តែព្រះថេរមិនទទួល ត្រឡប់ជាពោលតិះដៀលតាំងអ្នកទទួលតាំងអ្នកប្រគេនវិញ ។ ភិក្ខុអលជ្ជីទាំងនោះ ក៏នាំគ្នាធ្វើបដិសារណីយ-កម្មដល់ព្រះយសត្ថេរ ដោយបានអាងថាលោកជេរប្រទេចឧបាសកដែលប្រគេនបច្ច័យដល់ភិក្ខុសង្ឃជាក់ទណ្ឌកម្មឲ្យលោកទៅសូមខមាទោសនឹងពួកឧបាសកវិញ ។ ព្រះយសត្ថេរថា "បើឲ្យយើងទៅសូមខមាទោសដូច្នោះចូររកភិក្ខុមួយរូបឲ្យជាអនុទូតទៅជាមួយនឹងយើងផង" ។ លុះពួកវជ្ជី-បុត្តកភិក្ខុ សន្មតិភិក្ខុជាអនុទូតឲ្យហើយ ព្រះយសត្ថេរក៏និមន្តទៅកាន់សំ-ណាក់ឧបាសក ជាមួយនឹងភិក្ខុអនុទូតនោះ, ដល់ហើយព្រះថេរៈក៏សំដែងប្រាប់ឧបាសកអំពីរឿងព្រះវិនយបញ្ញត្តិថា "ប្រាក់ទឹងមាសជារបស់មិនគួរដល់សមណៈ, ព្រះបរមគ្រូទ្រង់បញ្ញត្តហាមប្រាមមិនឲ្យភិក្ខុទទួលប្រាក់នឹងមាស ព្រះអង្គបានតាំងត្រាស់ប្រៀបធៀបការសៅហ្មងរបស់ភិក្ខុមកថា ព្រះចន្ទនឹងព្រះអាទិត្យរមែងសៅហ្មងដោយមន្ទិល ៤ ប្រការគឺៈ ពពក ១ ទឹកសន្សើម ១ ផ្សែងធូលី ១ រាហូអសុរិន្ទ១; ឯភិក្ខុក្នុងព្រះពុទ្ធសាសនានេះដែលមិនមានតបៈ, មិនរុងរឿង, មិនភ្លឺត្រចះដោយសីល ក៏ព្រោះឧបក្កិ-លេស ៤ ប្រការដែរ គឺៈ ១. ផឹកសុរាមេរ័យ, ២. សេពមេថុនធម្ម, ៣. ត្រេកអរទទួលមាសនឹងប្រាក់, ៤. ចិញ្ចឹមជីវិតមិនត្រូវតាមធម៌ មានជង្ឃ-បេសនៈ គឺទទួលខ្លួនជាអ្នកបំរើរបស់គ្រហស្ថ ទឹងធ្វើពេទ្យជាដើម ។

ពួកឧបាសកក្នុងក្រុងវេសាលី បានស្ដាប់ច្បាប់វិន័យបញ្ញត្តិដែលព្រះយសត្ថេរសំដែងដូច្នោះហើយ ក៏រីកាយជ្រះថ្លានាំគ្នាសរសើរព្រះថេរៈថា "លោកម្ចាស់អង្គនេះ ទើបបំជាសមណសក្យបុត្តពិតមែន" ហើយអារាធនាឲ្យលោកគង់នៅក្នុងក្រុងវេសាលីតទៅ ។ លុះព្រះថេរនិមន្តត្រឡប់មកកាន់អារាមវិញ ពួកវជ្ជីបុត្តកភិក្ខុសួរភិក្ខុអនុទូតថា ព្រះយសទៅសូមខមាទោសពួកឧបាសកហើយឬ? ។ ទៅសូមទោសឯណា ត្រឡប់ជាទៅពោលប្រាប់ឧបាសកថាពួកយើងនេះ មិនមែនជាសមណៈទៅវិញ គេក៏បែរមកជ្រះថ្លានឹងលោកហើយ ។ ពួកវជ្ជីបុត្តកភិក្ខុ កាលដឹងដូច្នោះទើបគិតគ្នានឹងចុះឧក្ខេបនីយកម្មដល់ព្រះយសត្ថេរ ដោយហេតុដែលលោកទៅត្រដាងទោសរបស់ពួកខ្លួនប្រាប់ឧបាសក បាននាំគ្នាទៅឡោមកុដិរបស់លោក ។ ដឹងខ្លួនក៏ហោះឡើងទៅតាមអាកាសដល់ក្រុងកោសម្ពី ហើយបញ្ជូនភិក្ខុជាទូតឲ្យនាំដំណឹងការណ៍នោះទៅប្រាប់ ដល់ពួកបាវេយ្យកភិក្ខុ (ភិក្ខុនៅក្នុងដែនបាវ៉ា) និងពួកអវន្តិទក្ខិណាបថភិក្ខុផង ចំណែកព្រះយសត្ថេរឯង បាននិមន្តទៅកាន់សំណាក់ព្រះសម្ភូតត្ថេរនាអហោគង្គបព៌ត ។ គ្រានោះព្រះមហាថេរជាព្រះខីណាស្រពក្នុងដែនបាវ៉ា ៦០ អង្គ, ក្នុងអវន្តិទក្ខិណាបថជនបទ ៨០ អង្គ; កាលបើបានឮដំណឹងអំពីភិក្ខុអនុទូតដូច្នោះហើយ ក៏នាំគ្នាចុះមកកាន់អហោគង្គបព៌ត រួមទាំងអស់ដែលបានមកប្រជុំ

ក្នុងទីនោះចំនួន ៩ ម៉ឺនអង្គ សុទ្ធតែព្រះខីណាស្រព ពិភាក្សាគ្នាអំពីកិច្ចដែលត្រូវរម្ងាប់អធិករណ៍នោះ ។

ក្សណនោះ, ព្រះរេវតត្ថេរជាសទ្ធិវិហារិកនៃព្រះអានន្ទនៅអាស្រ័យក្នុងនគរសោរេយ្យ លោកជាពហុស្សូត ឈ្លាសក្នុងព្រះត្រៃបិដក ។ ព្រះមហាថេរទាំងនោះ ក៏ទៅរកលោកឯនគរសោរេយ្យ តែមិនជួប ក៏តាមទៅជួបដល់សហជាតិនគរ, ទើបព្រះយសត្ថេរ លើកវត្ថុ ១០ ប្រការដែលពួកវជ្ជីបុត្តកភិក្ខុបញ្ញត្តឡើងសួរព្រះរេវតត្ថេរ ។ តបថាមិនគួរទាំងអស់ទំនាស់ទីងព្រះវិន័យទាំងស្រុង; លំដាប់នោះព្រះមហាថេរទាំងនោះ ក៏ព្រមព្រៀងមូលមតិគ្នាជាឯងរម្ងាប់អធិករណ៍នោះ ។ ប៉ែកខាងវជ្ជីបុត្តកភិក្ខុកាលបើបានឮដំណឹងដឹងដំណើរនោះហើយ ក៏គិតទីងយកព្រះរេវតត្ថេរឲ្យចូលជាពួកខ្លួនទើបចាត់ចែងគ្រឿងសមណបរិក្ខារ ប្រញាប់ប្រញាល់ទៅសហជាតិនគរដើម្បីប្រគេនព្រះរេវតត្ថេរ ។ ព្រះសាឡ្ហត្ថេរ ជាសិស្សព្រះអានន្ទ កាលបើបានឮដំណឹងអធិករណ៍នោះហើយ ក៏ពិចារណាឃើញច្បាស់ថា ពួកភិក្ខុដែលនៅខាងបាចីនទិស (ទិសខាងកើត) ជាអធម្មវាទី (អ្នកនិយាយខុសធម៌, ខុសច្បាប់) ឯពួកភិក្ខុដែលនៅក្នុងដែនបាវជាធម្មវាទី (អ្នកនិយាយត្រូវធម៌ ត្រូវច្បាប់) ទាំងមហាព្រហ្មក៏បានចុះមកប្រកាសបញ្ជាក់ដល់លោកថែមទៀត ។

កាលពួកវជ្ជីបុត្តកភិក្ខុ ទៅដល់សហជាតិនគរហើយក៏នាំយកគ្រឿងសមណបរិក្ខារទាំងនោះចូលទៅប្រគេនព្រះរេវតត្ថេរ ។ មិនទទួល ទើបចូលទៅរកឧត្តរភិក្ខុជាសិស្សឧបដ្ឋាករបស់លោក សុំឲ្យជួយនិយាយឧបត្ថម្ភពួកខ្លួនផង ។ ឧត្តរភិក្ខុក៏ចូលទៅអង្វរព្រះរេវតត្ថេរ ។ មិនជឿមិនស្តាប់ត្រឡប់ជាបណ្តេញឧត្តរភិក្ខុមកវិញ ។ ឯពួកវជ្ជីបុត្តកភិក្ខុ កាលបើស្វែងរកពួកបក្សមិនបានទីពឹងតែហើយ ក៏នាំគ្នាទៅក្រុងវេសាលីវិញ ចូលទៅទូលល្បួងចិត្តព្រះបាទកាលាសោកថា ពួកខ្ញុំបានយកចិត្តទុកដាក់ជម្រះបោសសំអាតព្រះគន្ធកុដិរបស់សម្តេចព្រះដ៏មានបុណ្យ គង់វិហារមហាវនវជ្ជីភូមិ ឥឡូវនេះពួកភិក្ខុគាមវាសីនមកដណ្តើមយកវិហារនោះ សូមព្រះអង្គទ្រង់ព្រះមេត្តាជួយហាមឃាត់ផង ។ ព្រះបាទកាលាសោកទ្រង់មិនបានពិចារណាជាមុន ក៏ទ្រង់មានព្រះរាជសទ្ធាជឿស៊ប់; ពួកវជ្ជីបុត្តកភិក្ខុទាំងនោះក៏នាំគ្នាត្រឡប់មកកាន់វិហារវិញ ។

ភិក្ខុប្រមាណ ១១ សែន ៩ ម៉ឺនអង្គ បានមកប្រជុំគ្នាក្នុងសហជាតិនគរ ដើម្បីវិនិច្ឆ័យរម្ងាប់អធិករណ៍នោះ ក្នុងសហជាតិនគរ តែព្រះរេវតត្ថេរទទឹងទាស់ព្រោះគាត់ថា ពួកវជ្ជីបុត្តកភិក្ខុនៅក្រុងវេសាលីជាអ្នកបញ្ញត្តវត្ថុ ១០ ប្រការនេះឡើង ទីងវៀវពួកដែលបង្កហេតុចេញមិនគួរ, ទើបព្រមព្រៀងគ្នាទៅរម្ងាប់អធិករណ៍នៅក្រុងវេសាលីវិញ ។

កាលព្រះមហាថេរទាំងនោះ និមន្តទៅដល់ក្រុងវេសាលីហើយ, ព្រះបាទកាលាសោក ទ្រង់ពុំទាន់បានពិចារណាឲ្យឃើញខុសត្រូវ ព្រោះទ្រង់ជឿស្លុងក្នុងពាក្យល្បួងរបស់ពួកវជ្ជីបុត្តកភិក្ខុ ទើបទ្រង់ព្រះបញ្ជាអាមាត្យម្នាក់ ឲ្យទៅហាមឃាត់ភិក្ខុដទៃកុំឲ្យនៅក្នុងវិហារ ក្រៅអំពីភិក្ខុដែលបាននៅមកយូរហើយ ។ អាមាត្យអ្នកទទួលព្រះរាជបញ្ជានោះ ដោយអានុភាពនៃទេវតាមកបណ្ដាល ក៏វង្វេងផ្លូវរកផ្លូវទៅវត្តមិនឃើញ ។ នៅវេលាអធ្រាត្រ ព្រះបាទកាលាសោករាជ ទ្រង់យល់ព្រះសុបិនដ៏លាមកថា នាយនិរយបាលមកចាប់ចងព្រះអង្គទាំងរស់ បោះទៅក្នុងលោហកុម្ភី (ខ្ទះទង់ដែង); ទ្រង់តើនឡើងក៏ទ្រង់តក់ស្លុតរន្ធត់ញាប់ញ័រព្រះហឫទ័យយ៉ាងខ្លាំង ។

ព្រះនាងនន្ទាថេរីជាព្រះរាជភគិនី (ប្អូនស្រីរបស់ព្រះបាទកាលាសោករាជ) បានក្រាបថា ព្រះបាទកាលាសោករាជ ទ្រង់ប្រកាន់ខុស ជឿតាមពួកភិក្ខុអលជ្ជី ដែលនឹងនាំឲ្យព្រះពុទ្ធសាសនាអាប់ឱន ដូច្នោះហើយក៏ប្រញាប់និមន្តមកតាមផ្លូវអាកាស, ដល់ហើយក៏បានក្រាបសុបិននិមិត្តរបស់ព្រះរាជាទើបថ្វាយឱវាទថា "បពិត្រព្រះមហារាជ! ព្រោះតែព្រះអង្គទៅជឿតាមពួកវជ្ជីបុត្តកភិក្ខុជាអ្នកមិនខ្លាចបាប, បានជាយល់សុបិននិមិត្តដ៏អាក្រក់យ៉ាងនេះ ចូរព្រះអង្គប្រតិបត្តិតាមពួកភិក្ខុ ជាធម្មវាទី.វិនយវាទីវិញ ចូរទ្រង់យាងទៅសូមខមាទោសនឹងលោកហើយ ជួយឧបត្ថម្ភព្រះពុទ្ធសាសនាផង", កាលថ្វាយឱវាទស្រេចហើយ ព្រះនាងក៏ថ្វាយព្រះពរលាចេញទៅ ។

កាលព្រះបាទកាលាសោករាជ ទ្រង់បានស្តាប់ទុក្ខព្រះនាងថេរី ហើយ ទ្រង់តក់ស្លុតសង្វេគក្នុងព្រះហឫទ័យជាខ្លាំង ។ ព្រឹកឡើង ស្តេចយាងទៅមហាវិហារជាមួយនឹងពួកសេវកាមាត្យរាជបរិពារ ទ្រង់ឲ្យអារាធ-នាប្រជុំព្រះសង្ឃទាំងអស់ ។ កាលព្រះសង្ឃមកប្រជុំគ្រប់អង្គហើយព្រះរាជាក៏ទ្រង់ស្តាប់សេចក្តីនៃព្រះសង្ឃទាំងពីរខាង គឺខាងពួកវជ្ជីបុត្តកភិក្ខុនឹងខាងពួកបាវេយ្យកភិក្ខុ ។ ទីបំផុតទ្រង់ពិចារណាឃើញច្បាស់ថាពួកវជ្ជីបុត្តកភិក្ខុជាអលជ្ជីប្រកាន់ខុសចាកវិន័យពុទ្ធបញ្ញត្តិមែន ។ ទើបទ្រង់សុំឲ្យព្រះសង្ឃពួកបាវេយ្យកភិក្ខុអត់ទោសឲ្យ ហើយថ្វាយព្រះអង្គជាញោមទទួលជួយឧបត្ថម្ភកិច្ចវិន័យ រម្ងាប់អធិករណ៍និងធ្វើសង្គាយនាស្រេចហើយទ្រង់ថ្វាយបង្គំលាព្រះសង្ឃ ស្តេចវិលត្រឡប់ទៅព្រះរាជវាំងវិញ ។

ចំណែកខាងព្រះសង្ឃ ក៏ប្រឹក្សាគ្នាអំពីកិច្ចដែលត្រូវរម្ងាប់អធិករណ៍; លំដាប់នោះ ព្រះរេវតត្ថេរញ៉ាំងសង្ឃឲ្យដឹង ដោយឧព្វាហិកកម្មវាចា គឺធ្វើសេចក្តីសន្និដ្ឋានកំណត់ក្នុងកណ្តាលទីប្រជុំសង្ឃ សន្មតិព្រះថេរណាស្រេច ៤ អង្គ ឲ្យជាពួកបាចីនកភិក្ខុជាអធម្មវាទី; ៤ អង្គទៀត ឲ្យជាពួកបាវេយ្យ-កភិក្ខុជាធម្មវាទី, សន្មតិ ១ អង្គទៀតឲ្យជាអ្នកក្រាលអាសនៈ; ស្រេចហើយ ក៏នាំគ្នានិមន្តទៅវាលុការាម ។

### ខាងបាចីនកភិក្ខុ ៤ រូបគឺ

១– ព្រះសព្វកាមិត្ថេរ; ២– ព្រះសាឡ្ហត្ថេរ; ៣– ព្រះ

ខុជ្ជសោភិតត្ថេរ; ៤- ព្រះវាសភគាមិកត្ថេរ ។

## ខាងបាឋេយ្យកភិក្ខុ ៤ រូបគឺ

១- ព្រះរេវតត្ថេរ; ២- ព្រះសម្ភូតត្ថេរ; ៣- ព្រះយស-ត្ថេរ; ៤- ព្រះសុមនត្ថេរ ។

ព្រះអជិតភិក្ខុអ្នកក្រាលអាសនៈ ។

ការវិនិច្ឆ័យរម្ងាប់អធិករណ៍នេះ គឺធ្វើដោយវិធីសួរឆ្លើយគ្នាកណ្ដាលទីប្រជុំសង្ឃ, ព្រះរេវតត្ថេរខាងបាឋេយ្យកភិក្ខុជាអ្នកសួរ ព្រះសព្វកាមិត្ថេរខាងបាចីនកភិក្ខុ ជាអ្នកវិស្សជ្ជនានូវវត្ថុ ១០ ប្រការ ។

## វត្ថុ ១០ ប្រការ

១- កប្បតិ សិង្គិលោណកប្បោ វិនយបញ្ញត្តិក្នុងសន្និធិការកសិក្ខាបទក្នុងសុត្តវិភង្គថា “របស់ជាយាវកាលិក បើភិក្ខុបានទទួលប្រគេនហើយទុកឲ្យកន្លងរាត្រី យកមកឆាន់ត្រូវអាបត្តិបាចិត្តិយៈ” ។ ពួកវជ្ជីបុត្តកភិក្ខុសំដែងឡើងថា “អំបិលដែលដាក់ទុកក្នុងក្បាក់ស្នែង បើទុកឲ្យកន្លងរាត្រីហើយយកមកឆាន់ជាមួយនឹងអាហារបិណ្ឌបាតដែលសាបបាន មិនត្រូវអាបត្តិឡើយ” ។

២ កប្បតិ ទ្វង្គុលកប្បោ វិនយបញ្ញត្តិក្នុងវិកាលភោជនសិក្ខាបទក្នុងសុត្តវិភង្គថា “ភិក្ខុឆាន់របស់ជាយាវកាលិកក្នុងវេលាវិកាល

ត្រូវអាបត្តិបាចិត្តិយៈ" ។ ពួកវជ្ជីបុត្តកភិក្ខុសំដែងឡើងថា "បើព្រះអាទិត្យជ្រេទៅហើយប្រមាណពីរធ្នាប់ ក៏គួរទទួលទានរបស់ជាយាវកាលិកបាន មិនត្រូវអាបត្តិឡើយ" ។

៣- កប្បតិ គាមន្តរកប្ប វិនយប្បញ្ញត្តិ ក្នុងបឋមបវារណាសិក្ខាបទក្នុងសុត្តវិភង្គថា "ភិក្ខុហាមភោជនហើយ ក្រោកចាកទីនោះទៅឆាន់អនតិរិត្តភោជន ត្រូវអាបត្តិបាចិត្តិយៈ" ។ ពួកវជ្ជីបុត្តកភិក្ខុសំដែងឡើងថា "បើគិតថា អញនឹងចូលទៅកាន់ស្រុកដូច្នេះ, ក៏ត្រូវឆាន់អនតិរិត្តភោជនបាន មិនត្រូវអាបត្តិឡើយ" ។

៤- កប្បតិ អាវាសកប្ប វិនយប្បញ្ញត្តិក្នុងឧបោសថក្ខន្ធកទី២ ក្នុងខុទ្ទកវិន័យថា "ទីអាវាសដែលនៅក្នុងសីមាជាមួយគ្នា ភិក្ខុនឹងធ្វើសង្ឃកម្មទាំងពួងមានឧបោសថកម្មជាដើម ផ្សេងគ្នាមិនគួរ បើធ្វើដូច្នោះ ត្រូវអាបត្តិទុក្កដ, កម្មដែលធ្វើនោះសោតក៏មិនមែនជាសង្ឃកម្មឡើយ" ។ ពួកវជ្ជីបុត្តកភិក្ខុសំដែងឡើងថា "ត្រូវធ្វើបាន ឥតមានទាស់ឡើយ" ។

៥- កប្បតិ អនុមតិកប្ប វិនយប្បញ្ញត្តិក្នុងចម្មេយ្យក្ខន្ធកៈ ទី៩ ក្នុងខុទ្ទកវិន័យថា "ភិក្ខុនឹងធ្វើសង្ឃកម្មទាំងពួង ត្រូវប្រជុំភិក្ខុដែលមាននៅក្នុងសីមាជាមួយគ្នា ឲ្យមកប្រជុំព្រមជាប់ហត្ថបាសគ្នា ឬបាននាំឆន្ទៈបរិសុទ្ធិនៃភិក្ខុដែលមានកិច្ចធុរៈ មិនបានមកកាន់ហត្ថបាសនោះ ទើបធ្វើ

បាន, បើមិនធ្វើដូច្នេះ ហៅថាធ្វើកម្មជាពួក ត្រូវអាបត្តិទុក្កដ កម្មដែលធ្វើនោះ សោតក៏មិនមែនជាសង្ឃកម្មឡើយ" ។ ពួកវជ្ជីបុត្តកភិក្ខុសំដែងឡើងថា "មិនចាំបាច់មកជួបជុំគ្នាដូច្នោះទេ បើមកដល់មុនទឹងធ្វើសង្ឃ-កម្មមុនបណ្តើរទៅក៏បាន ឥតមានទោសឡើយ" ។

៦- កាប្បតិអាចិណ្ណកប្បោ ព្រះធម្មវិន័យពុទ្ធសាសនានោះ មានរបៀបរៀបរៀងជាខ្នាតជាបន្ទាត់កំណត់ទុកជាខុសជាត្រូវមករួចជាស្រេចហើយ, សេចក្តីប្រតិបត្តិជាចរិតរបស់ព្រះឧបជ្ឈាយ៍អាចារ្យតៗមកបើត្រូវសមតាមរបៀបធម្មវិន័យនោះ ទើបឲ្យសិស្សានុសិស្សទាំងពួងប្រតិបត្តិតាម, បើមិនត្រូវមិនសមទេ នោះសិស្សានុសិស្សទាំងពួងមិនត្រូវប្រតិបត្តិតាមឡើយ ។ ពួកវជ្ជីបុត្តកភិក្ខុសំដែងឡើងថា "សេចក្តីប្រតិបត្តិជាចរិតចំនៀមទម្លាប់របស់ឧបជ្ឈាយ៍អាចារ្យ ទោះខុសក្តី ត្រូវក្តី សិស្សានុសិស្សទាំងពួងត្រូវប្រតិបត្តិតាមបានឥតមានទោសឡើយ" ។

៧- កប្បតិ អមថិតកប្បោ ទឹកដោះស្រស់ដែលប្រែបាកភាពដើមហើយ តែនៅមិនទាន់ក្លាយទៅជាទធិនៅឡើយ មានវិនយប្ប-ញត្តិថា "ភិក្ខុហាមភោជនហើយក្រោកចាកទីនោះ ហើយឆាន់ទឹកដោះជាអនតិរិត្តនោះត្រូវអាបត្តិបាចិត្តិយៈ" (តាមន័យក្នុងបឋមបវារណាសិក្ខាបទ) ពួកវជ្ជីបុត្តកភិក្ខុសំដែងឡើងថា "ឆាន់បាន មិនត្រូវអាបត្តិឡើយ" ។

៨- កប្បតិ ជលោគី ចាតុំ តរុណសុរា គឺសុរាដែលគេដាក់គ្រឿងស្រវឹងផ្សំត្រាំជាមួយគ្នាហើយ តែនៅខ្សោយមិនទាន់ពេញជាទឹកស្រវឹងនៅឡើយ បើភិក្ខុផឹកត្រូវអាបត្តិបាចិត្តិយៈ" (តាមន័យក្នុងសុរាបានសិក្ខាបទក្នុងសុត្តវិភង្គ) ។ ពួកវជ្ជីបុត្តកភិក្ខុសំដែងឡើងថា "តរុណសុរានោះ ភិក្ខុត្រូវផឹកបាន មិនត្រូវអាបត្តិឡើយ" ។

៩- កប្បតិ អទសកំ និសីទនំ វិនយបញ្ញត្តិក្នុងនិសីទនសិក្ខាបទ ក្នុងសុត្តវិភង្គថា "ភិក្ខុនឹងធ្វើសំពត់និសីទនៈត្រូវធ្វើឲ្យមានជាយ បើមិនធ្វើដូច្នោះ ត្រូវអាបត្តិបាចិត្តិយៈ" ។ ពួកវជ្ជីបុត្តកភិក្ខុសំដែងឡើងថា "មិនបាច់ធ្វើឲ្យមានជាយ ក៏ត្រូវប្រើបាន មិនត្រូវអាបត្តិឡើយ" ។

១០- កប្បតិ ជាតរូបរជតំ វិនយបញ្ញត្តិក្នុងរូបិយសិក្ខាបទក្នុងសុត្តវិភង្គថា "ភិក្ខុមិនត្រូវទទួលឬត្រេកអរចំពោះមាសប្រាក់, បើទទួលឬត្រេកអរត្រូវនិស្សគ្គិយបាចិត្តិយៈ" ។ តែក្នុងមេណ្ឌកបញ្ញត្តិ ក្នុងភេសជ្ជខន្ធកទី ៦ ក្នុងខន្ធកវិន័យមានពុទ្ធានុញ្ញាត ឲ្យភិក្ខុត្រេកអរចំពោះបច្ច័យដែលកើតអំពីរូបិយៈ គឺមាសឬប្រាក់នោះបាន ។ ពួកវជ្ជីបុត្តកភិក្ខុសំដែងឡើងថា "ភិក្ខុគួរទទួល ទាំងគួរត្រេកអរចំពោះមាសប្រាក់នោះ មិនត្រូវអាបត្តិឡើយ" ។

វត្ថុទាំង ១០ ប្រការនេះ ខុសចាកធម៌ ខុសចាកវិន័យក្នុងព្រះពុទ្ធសាសនា, ព្រះសង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយថាមិនមែនជាធម៌ មិន

មែនជាវិន័យ, ហើយពុទ្ធសាសនិកជន មិនត្រូវជឿនិងមិនត្រូវប្រតិបត្តិតាមឡើយ ។

បណ្ដាព្រះថេរទាំង ៨ អង្គ ដែលវិនិច្ឆ័យរម្ងាប់អធិករណ៍នោះ ៦ អង្គជាសិស្សព្រះអានន្ទគឺ

១-ព្រះសព្វកាមិត្ថេរ; ២-ព្រះសាឡ្ហត្ថេរ; ៣-ព្រះរេវតត្ថេរ; ៤-ព្រះខុជ្ជសោភិតត្ថេរ; ៥-ព្រះយសត្ថេរ; ៦-ព្រះសម្ភូតត្ថេរ; ។

ជាសិស្សព្រះអនុរុទ្ធ២ អង្គ ១ ព្រះវាសភគាមិកត្ថេរ;

២-ព្រះសុមណត្ថេរ ។

ព្រះថេរទាំង៨អង្គនេះ លោកបានទាន់ឃើញព្រះពុទ្ធជាម្ចាស់កាលព្រះអង្គគង់ព្រះជន្មនៅ ។

ព្រះសង្ឃដែលប្រជុំរម្ងាប់អធិករណ៍គ្រានោះ មានចំនួន១២សែនអង្គ, ក្នុងចំនួននេះ ព្រះសព្វកាមីជាសង្ឃវុឌ្ឍាចារ្យ លោកមានវស្សា ១២០ តាំងពីឧបសម្បទមក ជាព្រះថេរចាស់ជាងព្រះសង្ឃទាំងពួងក្នុងលោក ។

កាលស្រេចការរម្ងាប់អធិករណ៍ហើយ, ព្រះរេវតត្ថេរក៏ប្រឹក្សានឹងសង្ឃដើម្បីធ្វើសង្គាយនា ជ្រើសយកសុទ្ធតែជាព្រះខីណាស្រព ទ្រទ្រង់នូវបដិសម្ភិទា បានចំនួន៧០០អង្គ, វិធីធ្វើដូចបឋមសង្គាយនា ផ្សេងតែ

ការសន្ទិអ្នកបុច្ឆា-វិស្សជ្ជនា, ការសន្ទិក្នុងគ្រានេះ មានត្រឹមតែពីររូបគឺ

ព្រះរេវតត្ថេរ ជាអ្នកបុច្ឆា ព្រះវិន័យ, ព្រះសូត្រ, ព្រះបរមត្ថ ។

ព្រះសព្វកាមិត្ថេរ ជាអ្នកវិស្សជ្ជនា ព្រះវិន័យ, ព្រះសូត្រ, ព្រះបរ-មត្ថ ។

សង្គាយនាគ្រានេះ ទើងហៅថា "សត្តសតិកាសង្គាយនា" ក៏បាន ព្រោះប្រជុំធ្វើដោយការកសង្ឃ ៧០០ អង្គ មានព្រះរេវតត្ថេរជាប្រធាន ធ្វើនៅនាវាលុការាម ក្រុងវេសាលី, ព្រះបាទកាលាសោកកជ ជាសាសនូ-បត្ថម្ភក៍, ធ្វើ ៨ ខែទើបសម្រេច, រាប់អំពីពុទ្ធបរិនិព្វានមកគន្ទងទៅហើយ បាន ១០០ ឆ្នាំ ។ សង្គីតិបរិយោសានេ ក្នុងកាលជាទីបំផុតនៃសង្គីតិកម្ម ហេតុអស្ចារ្យទាំងឡាយមានមហាប្រថពីកំរើកញាប់ញ័រជាដើម បានបង្កើតឡើងហើយជាកោលាហល ។

## បប់ទុតិយសង្គីតិ

## តតិយសង្គីតិ

ទុតិយសង្គីតឹ សង្គាយិត្វា តេ ថេរា · កាលព្រះថេរទាំងឡាយ មានព្រះយសត្ថេរជាដើមនោះ បានធ្វើទុតិយសង្គាយនារួចស្រេចហើយ ក៏ប្រារព្ធពិចារណាមើលទៅអនាគតថា អំពីនេះទៅ ២១៨ ឆ្នាំទៀត បើរាប់អំពីពុទ្ធបរិនិព្វានទៅគន្ទងបាន ២១៨ ឆ្នាំ នោះនឹងមាន

មហាក្សត្រ ១ អង្គ ទ្រង់ព្រះនាមធម្មាសោករាជ ជាព្រះរាជបុត្ររបស់ព្រះបាទពិម្ពិសារ បានឡើងគ្រងរាជសម្បត្តិនៅក្រុងបាតលីបុត្តជាឯករាជ្យក្នុងជម្ពូទ្វីប ទ្រង់មានព្រះរាជសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាដ៏មុតមាំ ញុំាងលាភសក្ការៈដ៏ច្រើនឲ្យកើតឡើងដល់ភិក្ខុសង្ឃ; ឯពួកតិរ្ថិយក៏នឹងចូលមកបួមបួសជាច្រើន ព្រោះឃើញលាភសក្ការៈ; លុះបួសហើយក៏នឹងសំដែងទិដ្ឋិរៀង ១ ខ្លួន ធ្វើឲ្យព្រះពុទ្ធសាសនាមានមន្ទិលសៅហ្មង" ។ លុះព្រះអរហន្តទាំងឡាយពិចារណាឃើញដូច្នោះហើយ ក៏នាំគ្នាឡើងទៅអារាធនាតិស្សមហាព្រហ្មក្នុងព្រហ្មលោក ដែលមានអាយុជិតអស់ហើយ នឹងទៅកើតក្នុងឋានព្រហ្ម ខាងលើទៀត, សូមឲ្យច្យុតមកកើតក្នុងមនុស្សលោកនាផ្ទះមោគ្គលីព្រាហ្មណ៍ នឹងបានជួយជំរះមន្ទិលព្រះពុទ្ធសាសនាឲ្យរុងរឿងនឹងឋិតថេរថេរកាលទៅក្នុងអនាគត តិស្សមហាព្រហ្មក៏ព្រមទទួល ។ ព្រះថេរទាំងនោះកាលត្រឡប់មកពីព្រហ្មលោកវិញហើយ ក៏ដំនុំគ្នាចុះទោសដាក់ទណ្ឌកម្មដល់ភិក្ខុថ្មីពីររូបគឺ ព្រះសិគ្គវត្ថេរ នឹងព្រះចន្ទវជ្ជិត្ថេរ ជាព្រះខីណាស្រពទ្រទ្រង់នូវព្រះត្រៃបិដកបដិសម្ភិទា (ដ្បិតព្រះថេរទាំងពីររូបនេះ នឹងមានជន្មាយុរស់នៅទាន់អធិករណ៍នោះ) ដោយអាងថាលោកមិនបានចូលមកប្រជុំក្នុងកាលរម្ងាប់អធិករណ៍នឹងធ្វើសង្គាយនាគ្រាទី ២ នេះ ថាបើតិស្សមហាព្រហ្ម ចុះមកកើតក្នុងត្រកូលមោគ្គលីព្រាហ្មណ៍

ហើយ លោក ១ រូបត្រូវទទួលធុរៈនាំខ្លួនមកបំបួសឲ្យបាន, ១ រូបទៀត ត្រូវទទួលបង្រៀនពុទ្ធវចនៈឲ្យចេះលទ្ធិព្រះពុទ្ធសាសនា; ព្រះថេរៈទាំងពីររូបក៏ទទួលធ្វើតាមអាជ្ញាសង្ឃដោយស្មោះត្រង់ឥតប្រកែក ។

កាលតិស្សមហាព្រហ្ម បានមកកើតក្នុងត្រកូលមោគ្គលីព្រាហ្មណ៍ ហើយ, ព្រះសិគ្គវត្ថេរក៏ព្យាយាមអស់វេលា ៧ ឆ្នាំ ទើបនាំតិស្សកុមារមក បំបួសបាន កាលទៅនាំមកបំបួសបានហើយ ក៏ប្រគល់ឲ្យនៅសិក្សា ពុទ្ធវចនៈ ក្នុងសំណាក់ព្រះចណ្ឌវជ្ជិត្ថេរ ហេតុបានសម្រេចជាព្រះអរហន្ត មាននាមប្រាកដថា "មោគ្គលីបុត្តតិស្សត្ថេរ" ជានាមជាប់ដោយ វង្សត្រកូលរបស់លោក ។ ចំណេរកាលតមក, ដល់រជ្ជសម័យនៃព្រះ បាទធម្មាសោករាជ ដែលទ្រង់ជាចក្រពត្តិក្នុងជម្ពូទ្វីបទាំងមូល ទ្រង់មាន ព្រះរាជពលានុភាពផ្សាយទៅក្នុងទិសផ្សេង ៗ ប្រកបដោយបុញ្ញាភិសម្ភារដ៏ មហាស្ចារ្យ ទ្រង់បរិបូណ៌ដោយទ្រព្យនឹងគ្រឿងឧបភោគជាអនេក, ទ្រង់ មានព្រះរាជសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាដ៏មុតមាំ ទ្រង់បានបរិច្ចាគទាន ដោយវត្ថុផ្សេង ៗ ជាច្រើន ព្រមទាំងទ្រង់បូជាព្រះរតនត្រ័យ នឹងទំនុកបំរុង ភិក្ខុសង្ឃជានិច្ចរាល់ៗថ្ងៃ; ក្នុងសម័យនោះ លាភសក្ការៈបានកើតឡើង ដល់ព្រះពុទ្ធសាសនាយ៉ាងមហោឡារិក ។

កាលព្រះមហាក្សត្រនឹងពលរដ្ឋភាគច្រើនចូលកាន់ព្រះពុទ្ធសាសនា

យ៉ាងនេះហើយពួកតិរ្ថិយ ក្នុងយុគនោះក៏សាបសូន្យលាភសក្ការៈ សូម្បីតែបាយក៏សឹងតែរកមកបរិភោគមិនបានផង; ក៏នាំគ្នាតែចូលមកបួមបួសជាភិក្ខុនៅប្រឡំបល់ក្នុងព្រះពុទ្ធសាសនាជាច្រើន សំដែងលទ្ធិរបស់ខ្លួនថា នេះជាធម៌ នេះជាវិន័យតាមទឹកឃើញ ហើយប្រតិបត្តិផ្តេសផ្តាសខុសពុទ្ធវិន័យមានការប្រតិបត្តិបំរើភ្លើងជាដើម, ពួកខ្លះមិនចូលទៅសូមបួសតាមព្រះវិន័យមិនមានឧបជ្ឈាយ៍អាចារ្យទេ ត្រាប់តែកោរសក់ ស្លៀកស្បង់ ដណ្តប់សំពត់កាសាវៈខ្លួនឯងតែម្តង ហើយចូលរួមធ្វើឧបោសថសង្ឃកម្មជាមួយនឹងភិក្ខុសង្ឃ ជាមន្ទិលយ៉ាងធំដែលប្រឡាក់ព្រះពុទ្ធសាសនា, ឯភិក្ខុសង្ឃបើទុកជាដឹងហើយក៏មិនមានឱកាសនឹងហាត់ការបង្ក្រាបទៅបាន ម្ល៉ោះហើយក៏ស្ងៀមត្រប់ៗអន្តទៅ, គ្រាន់តែមិនព្រមរួមធ្វើឧបោសថសង្ឃកម្មផងទៀយ ៗ ឯពួកតិរ្ថិយក៏កាន់តែមានចូលបួមបួសច្រើនឡើង ៗ រហូតដល់ដើរឃើញគ្នាហើយ ស្ទើរតែមិនដឹងថាអ្នកណាជាអ្នកណាទៀតផង, ព្រះសង្ឃក៏បញ្ឈប់ការធ្វើសង្ឃកម្ម ចំនួន ៧ ឆ្នាំ ។

ចំណែកព្រះមោគ្គលីបុត្តតិស្សត្ថេរ លោកពិចារណាឃើញថាអធិករណ៍នេះរឹងរូសធំដុំពេកណាស់ មិនអាចនឹងរម្ងាប់បានដោយងាយ, ទើបលោកប្រគល់អស់បណ្តាភិក្ខុជាសិស្សគណរបស់លោកឲ្យព្រះមហិន្ទត្ថេរគ្រប់គ្រង ឯអង្គលោកគេចចេញទៅគង់តាំវស្សា នៅអហោគង្គបព៌តអស់រយៈកាល ៧ ឆ្នាំ ។

ព្រះបាទធម្មាសោកពជ ទ្រង់ពុំបានសាកសួរហេតុផលឲ្យជ្រាប ច្បាស់នៅឡើយ គ្រាន់តែជ្រាបថា ព្រះសង្ឃមិនព្រមធ្វើឧបោសថសង្ឃកម្ម ក៏ទ្រង់ត្រាស់បង្គាប់អាមាត្យម្នាក់ឲ្យទៅរម្ងាប់អធិករណ៍នោះ ហើយឲ្យព្រះសង្ឃព្រមព្រៀងគ្នាធ្វើឧបោសថទៅ ។ អាមាត្យនោះ មិនដឹងជានឹងទៅរម្ងាប់អធិករណ៍ យ៉ាងណា, អាមាត្យខ្វះឲ្យន័យ ថា ព្រះរាជាទ្រង់ឲ្យប្រហារភិក្ខុឯណាដែលរឹងទទឹងមិនព្រមធ្វើឧបោសថ ដូចជាទ្រង់បង្គាប់ឲ្យរម្ងាប់បច្ចន្តគ្រាម ដែលមានចោរកំរើកបះបោរដូច្នោះឯង ។ អាមាត្យនោះទៅដល់អារាមហើយ ក៏បង្គាប់ឲ្យសង្ឃធ្វើឧបោសថ ; ឯព្រះសង្ឃអ្នកធ្ងន់ក្នុងធម្មវិន័យ មិនអាចធ្វើឧបោសថ រួមជាមួយនឹងពួកតិរ្ថិយទាំងនោះបាន អាមាត្យឃើញថារឹងទទឹង ក៏ប្រហារជីវិតអស់ ២-៣ អង្គទៅ ។

ព្រះតិស្សៈ ជាព្រះអនុជរួមផ្ទៃនៃព្រះបាទធម្មាសោកពជបានចេញទ្រង់ព្រះផ្នួសក្នុងសំណាក់ព្រះមហាធម្មរក្ខិតត្ថេរកាលទតឃើញអាការរបស់អាមាត្យធ្វើដូច្នោះ ក៏ក្រោកមកគង់ពាំងហាមឃាត់អាមាត្យនោះ ។ អាមាត្យស្គាល់ជាក់ហើយ ក៏ដាក់គ្រឿងសស្ត្រាចុះ ត្រឡប់មកក្រាបទូលព្រះរាជាវិញថា " ទូលព្រះបង្គំ ទទួលព្រះរាជបញ្ជាទៅរម្ងាប់អធិករណ៍នោះ បានប្រាប់ឲ្យព្រះសង្ឃធ្វើឧបោសថតែព្រះសង្ឃរឹងទទឹងមិនព្រមធ្វើតាម ទូលព្រះបង្គំក៏បានកាត់ព្រះសិរអស់ ២-៣ អង្គទៅហើយ លុះដល់មកលំដាប់ព្រះតិស្សត្ថេរជាម្ចាស់ គេទ្រង់បង្គាប់ឲ្យទូលព្រះបង្គំធ្វើដូចម្ដេច

ទៀត?" ។ ព្រះរាជាទ្រង់ជ្រាបភ្លាមហើយ ក៏ដេរបន្ទោសអាមាត្យជាអនេកប្បការ ទ្រង់កើតវិប្បដិសារីក្តៅក្រហាយពុំសប្បាយក្នុងព្រះហឫទ័យ ខ្លាចក្រែងមានទោសដល់ព្រះអង្គផង ទ្រង់បំណងចង់ដឹងសេចក្តីពិត ទើបទ្រង់ប្រញាប់ប្រញាល់យាងទៅកាន់អារាម ថ្លែងសេចក្តីឲ្យព្រះសង្ឃស្តាប់ ហើយត្រាស់សួរថា "បពិត្រព្រះសង្ឃដ៏ចំរើន! ខ្ញុំពុំបានបង្គាប់ឲ្យអាមាត្យមកប្រហារព្រះសង្ឃយ៉ាងនេះទេ បើដូច្នេះតើបាបនឹងធ្លាក់ទៅលើអ្នកណា?" ។ ព្រះសង្ឃទាំងអស់ថ្វាយព្រះពរមិនស្របគ្នា ព្រះសង្ឃខ្លះថ្វាយព្រះពរថា "បាបនឹងធ្លាក់ទៅលើមហារាជ ព្រោះព្រះអង្គជាអ្នកបង្គាប់ឲ្យគេមក" ។ ឯព្រះសង្ឃខ្លះថ្វាយព្រះពរថា "បាបនឹងធ្លាក់ទៅលើអាមាត្យតែម្នាក់ឯងមិនជាប់ជិតដាមដល់មហារាជឡើយ ព្រោះព្រះអង្គពុំបានត្រាស់បង្គាប់ឲ្យមកសម្លាប់" ។ កាលទ្រង់ព្រះសណ្តាប់ពាក្យថ្វាយព្រះពររបស់ព្រះសង្ឃទាំងអស់មិនត្រូវគ្នាដូច្នេះ ទ្រង់ក៏រឹងរិតតែសង្ស័យខ្លាំងឡើង, ទើបត្រាស់សួររកព្រះសង្ឃអង្គឯណា ដែលប្រកបដោយបញ្ញាជាមហាបណ្ឌិត អាចនឹងជំរះសេចក្តីសង្ស័យនៃទ្រង់ឲ្យជ្រះស្រឡះបាន ។ ព្រះសង្ឃក៏ថ្វាយព្រះពរថា "មានតែព្រះមោគ្គល្លីបុត្តតិស្សត្ថេរប៉ុណ្ណោះ ដែលអាចនឹងកំចាត់បង់នូវសេចក្តីសង្ស័យរបស់ព្រះអង្គនេះបាន" ។ កាលទ្រង់ព្រះសណ្តាប់ដូច្នេះហើយ ទ្រង់ចាត់ព្រះមហាថេរនឹងអាមាត្យព្រមដោយបរិវារឲ្យទៅអារាធនា ដកបដល់ពីរលើកព្រះថេរក៏មិននិមន្តមក ព្រោះទៅទូល

ថា "ឥឡូវនេះព្រះពុទ្ធសាសនាកំពុងសៅហ្មង សូមនិមន្តព្រះថេរទៅជម្រះមន្ទិលសាសនា" ។

លើកទី១បានចាត់ព្រះមហាថេរជាធម្មកថិក ៤ អង្គ មានភិក្ខុជាបរិវារមួយអង្គ១ពាន់, នឹងអាមាត្យ១នាក់ មានបរិវារ១ពាន់ឲ្យទៅអារាធនានិមន្ត ។

លើកទី២ ព្រះមហាថេរ៨រូប មានបរិវារ៨ពាន់នឹងអាមាត្យ៨នាក់ មានបរិវារ៨ពាន់ ។

លើកទី ៣ ព្រះមហាថេរ ១៦អង្គ មានបរិវារ ១៦ពាន់, នឹងអាមាត្យ ១៦នាក់ មានបរិវារ ១៦ ពាន់ ។

កាលព្រះមោគ្គល្លីបុត្តតិស្សត្ថេរ និមន្តមកដល់ហើយ, ព្រះមហាក្សត្រក៏ទ្រង់ជ្រើនូវបច្ចុគ្គមនាការ (ក្រោកទទួល) និមន្តព្រះថេរឲ្យគង់សំរាកក្នុងឧទ្យានលុម្ពសមគួរហើយ ទើបទ្រង់ថ្លែងរឿងរ៉ាវតាំងតែពីដើមរហូតដល់អាមាត្យទៅសម្លាប់ព្រះសង្ឃ ឲ្យព្រះថេរៈស្តាប់ ហើយត្រាស់សួរថា "បើយ៉ាងនេះ តើបាបនឹងធ្លាក់ទៅលើអ្នកណា?" ។ ព្រះថេរថ្វាយព្រះពរថា "បាបនឹងធ្លាក់ទៅលើអាមាត្យអ្នកសម្លាប់តែម្នាក់ឯង ពុំមានជិតជាប់ដល់ព្រះអង្គឡើយ ដ្បិតមហាពជមិនបានមានផែកចេតនាប្រើអាមាតឲ្យទៅសម្លាប់" ។ ព្រះថេរៈលើកយកពុទ្ធភាសិតត្រង់ ចេតនាហំ ភិក្ខវេ កម្មំ វទាមិ "ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ចេតនាជាតួកម្ម" នេះឡើងមកជាគោលវិនិច្ឆ័យ ញ៉ាំងព្រះមហាក្សត្រឲ្យអស់សេចក្តី

សង្ស័យ ព្រមទាំងបានលើកតិត្តិរជាតកមកសំដែងអានជាគ្រឿងអារកាត់ថែមទៀត ។

ព្រះមោគ្គលីបុត្តតិស្សត្ថេរ បានញ៉ាំងព្រះមហាក្សត្រឲ្យរីករាយព្រះកដហឫទ័យដោយមធុរធម្មកថាដូច្នេះហើយក៏គង់នៅក្នុងឧទ្យាននោះ អស់រយៈកាល ៧ ថ្ងៃ, បង្រៀនព្រះមហាក្សត្រឲ្យចេះដឹងជាបច្ចាស់នូវលទ្ធិសម័យក្នុងព្រះពុទ្ធសាសនាទាំងលទ្ធិដទៃសព្វគ្រប់ហើយ លុះដល់ថ្ងៃគំរប់៧ ព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់អាមាត្យឲ្យដើរនិមន្តព្រះសង្ឃទាំងអស់ ឲ្យមកប្រជុំក្នុងអសោការាម ដើម្បីនឹងរម្ងាប់អធិករណ៍ ។

## វិធីរម្ងាប់អធិករណ៍

វិធីរម្ងាប់អធិករណ៍នោះដូច្នេះគឺ កាលព្រះសង្ឃមកប្រជុំគ្រប់ព្រះអង្គហើយ, ព្រះបាទធម្មាសោករាជទ្រង់ត្រាស់បង្គាប់ឲ្យនិមន្តពួកភិក្ខុដែលប្រកាន់លទ្ធិដូចគ្នាមកគង់ជាពួក ៗ ហើយត្រាស់សួរថា: “ព្រះសម្មាសម្ពុទ្ធព្រះអង្គជាវាទីអ្វី?” ។ ពួកដែលមិនបរិសុទ្ធ ក៏ថ្វាយព្រះពរតាមលទ្ធិខ្លួន មានឧច្ឆេទវាទ សស្សតវាទជាដើម ។

លុះទ្រង់ជ្រាបថា មិនមែនជាសង្ឃបរិសុទ្ធដូច្នោះហើយ ក៏ទ្រង់បង្គាប់ឲ្យសឹកចេញ បានផ្សឹកពួកតិរ្ថិយមិច្ឆាទិដ្ឋិក្នុងសម័យនោះចំនួន ៦ ម៉ឺនរូប ។ ឯព្រះសង្ឃដែលបរិសុទ្ធ ក៏ថ្វាយព្រះពរថា “ព្រះសម្មាសម្ពុទ្ធព្រះអង្គ

ជាវិភជ្ជវាទី" ។ ព្រះរាជាត្រាស់សួរព្រះមោគ្គលីបុត្តតិស្សត្ថេរថា "ព្រះសម្មាសម្ពុទ្ធជាវិភជ្ជវាទីមែនឬ?" ។ ព្រះថេរៈថ្វាយព្រះពរថា "មែន" ។ កាលទ្រង់ម្ចាស់ជម្រះអធិករណ៍រួចស្រេចហើយ ក៏ទ្រង់អារាធនាព្រះសង្ឃឲ្យមានសេចក្តីសាមគ្គីសាមគ្គារួមគ្នា ធ្វើឧបោសថសង្ឃកម្មឡើង រួចស្តេចត្រឡប់ទៅព្រះរាជវាំងវិញ ។ ភិក្ខុសង្ឃដែលមកប្រជុំក្នុងទីសង្ឃសន្និបាតនោះចំនួន៦លានរូប ។

## ការធ្វើសង្គាយនា

កាលជម្រះអធិករណ៍ផ្សែកពួកបួសបួមផ្តេសផ្តាសជ្រះស្រឡះហើយ , ព្រះមោគ្គលីបុត្តតិស្សត្ថេរ បានជ្រើសព្រះសង្ឃក្នុងចំនួន៦លានរូប យកសុទ្ធតែព្រះថេរៈទ្រទ្រង់ព្រះត្រៃបិដក បែកធ្លាយក្នុងបដិសម្ភិទាញាណទាំង៤ បានចំនួន១ពាន់អង្គ ប្រជុំធ្វើសង្គាយនា, វិធីធ្វើដូចបឋមសង្គាយនា ។ ព្រះមោគ្គលីបុត្តតិស្សត្ថេរជាប្រធាន, ធ្វើនៅអសោការាម ក្រុងបាតលីបុត្ត, ព្រះបាទធម្មាសោករាជជាពុទ្ធសាសនូបត្ថម្ភក៍, ធ្វើ៩ខែទើបសំរេច រាប់អំពីពុទ្ធបរិនិព្វានមក គន់ទៅហើយបាន២៣៤ឆ្នាំ ។ សង្គាយនាលើកទី៣នេះ ទើបហៅថា "សហស្សិកាសង្គាយនា" ក៏បាន ព្រោះប្រជុំធ្វើដោយការកសង្ឃ១ពាន់អង្គ ។ សង្គីតិ បរិយោសានេ និមិត្តតែបប់សង្គីតិកម្មកាលណាហើយ មហាប្រថពី ក៏បានកំរើកញាប់ញ័របន្ទឺសព្ទឮរំពងឡើងក្នុងកាលនោះ ។

បប់តតិយសង្គីតិ

## ចតុត្ថសង្គីតិ

មោគ្គលីបុត្តតិស្សត្ថេរោ ធម៌ តតិយសង្គីតិ កត្វា កាល ព្រះមោគ្គលីបុត្តតិស្សត្ថេរ ធ្វើតតិយសង្គាយនារួចស្រេចហើយ ក៏ពិចារ-ណាឃើញថា "ក្នុងអនាគតកាល ព្រះពុទ្ធសាសនា នឹងឋិតនៅរុងរឿងក្នុងបច្ចន្តជនបទ" ទើបលោកចាត់ការបញ្ជូនព្រះថេរៈទាំងឡាយឲ្យទៅប្រកាសផ្សាយព្រះសាសនាក្នុងបច្ចន្តជនបទផ្សេងៗ ។ ឯព្រះថេរៈដែលបានទទួលថេរបញ្ជាទៅប្រកាសព្រះសាសនានោះគឺ

១- ព្រះមជ្ឈន្តិកត្ថេរ ទៅកាន់ដែនកស្មីរៈនិងគន្ធារៈបានទូន្មានស្តេចនាគឈ្មោះអារវាឡធ្វើឲ្យអស់ព្យសនកំណាចហើយសំដែងធម្មកថាញ៉ាំងនាគរាជព្រមទាំងបរិវារឲ្យតាំងនៅក្នុងសរណគមន៍ និងសីល ៥ ។ បញ្ចូកយក្សនឹងនាងហារិតីយក្ខិនី ព្រមទាំងបុគ្គល ៥០០ នាក់ ស្តាប់នូវធម្មកថានៃព្រះថេរៈ បានសម្រេចសោតាបត្តិផលទាំងអស់ ។ ព្រះថេរៈសំ-ដែងនូវអាសីវិសូបមសូត្រដល់ពួកមនុស្ស, មហាជនបានសម្រេចមគ្គផល ៨ ម៉ឺន ៤ ពាន់នាក់ ចេញបព្វជ្ជាក្នុងព្រះពុទ្ធសាសនា ១០០០ ត្រកូល ។

២- ព្រះមហាទេវត្ថេរ ទៅមហិសកមណ្ឌល បានសំដែងនូវទេវទូតសូត្រ, កាលចប់ធម្មទេសនា សត្វដែលមានឧបនិស្ស័យបានធម្ម-ចក្ខុ ប្រមាណ ៤ ម៉ឺននាក់, ចេញបព្វជ្ជាក្នុងព្រះពុទ្ធសាសនា ប្រមាណ ៤ ម៉ឺននាក់ ។

៣- ព្រះរក្ខិតត្ថេរ ទៅវនវាសីប្រទេស បានសំដែងអនមតគ្គ-បរិយាយកថា (កថាពណ៌នាអំពីសង្សារដែលមានទីបំផុតខាងដើមមិនប្រាកដ) មហាជន ៦ ម៉ឺននាក់ បានសំរេចមគ្គផល, ចេញបព្វជ្ជា ៣ ម៉ឺន ៧ ពាន់នាក់, មានអារាមក្នុងសាសនាកើតឡើង ៥០០ ។

៤- ព្រះយោនកធម្មរក្ខិតត្ថេរ ទៅអបរន្តកជនបទ បានសំ-ដែងអគ្គិក្ខន្ធូបមសូត្រ ញុំាងមហាជន ៧ ពាន់នាក់ ឲ្យក្រេបផឹកនូវ អម្ពុត-រស, បុរសចេញចាកខត្តិយត្រកូលទៅបព្វជ្ជា ១ ពាន់នាក់, ស្ត្រី ៦០០០ នាក់ ។

៥- ព្រះមហាធម្មរក្ខិតត្ថេរ ទៅមហារដ្ឋ បានសំដែងម-ហានារទជាតកនឹងកស្សបជាតក, មហាជនតាំងនៅក្នុងអរិយមគ្គអរិយផល ៨ ម៉ឺន ៤ ពាន់នាក់, ចេញបព្វជ្ជា ១ ម៉ឺន ៣ ពាន់នាក់ ។

៦- ព្រះមហារក្ខិតត្ថេរ ទៅយោនករដ្ឋ បានសំដែងកាឡកា-រាមសូត្រ, ញុំាងមហាជនឲ្យតាំងនៅក្នុងអរិយមគ្គអរិយផល ១ សែន ៣ ម៉ឺន ៧ ពាន់នាក់, ចេញបព្វជ្ជាក្នុងសំណាក់ព្រះថេរៈមួយម៉ឺននាក់ ។

៧- ព្រះមជ្ឈិមត្ថេរ នឹងព្រះថេរ ៤ អង្គទៀតគឺព្រះកស្សបគោ-ត្តត្ថេរ ១ ព្រះអឡកទេវត្ថេរ ១ ព្រះទុន្ទុភិស្សរត្ថេរ ១ ព្រះសហស្សទេវត្ថេរ ១ ទៅប្រទេសជាចំណែកមួយនៃព្រៃហិមពាន្ត បានសំដែងធម្មចក្កប្បវត្តន-

សូត្រញុំាងមហាជនឲ្យបានសំរេចមគ្គផល ៨ កោដិ, កុលបុត្រចេញបព្វជ្ជាក្នុងសំណាក់ព្រះថេរមួយអង្គ ១ សែន ៗ ។

៨– ព្រះសោណត្ថេរ និង ព្រះឧត្តរត្ថេរ ទៅសុវណ្ណភូមិ បានទេសនាព្រហ្មជាលសូត្រ, ញុំាងមហាជនឲ្យតាំងនៅក្នុងសរណគមន៍ និងសីល ពួកដែលមានឧបនិស្ស័យ បានសំរេចមគ្គផល ៦ ម៉ឺននាក់, ក្មេងប្រុសៗ ៣ ពាន់៥ រយនាក់ និងក្មេងស្រីៗ ១ ពាន់៥ រយនាក់ចេញបព្វជ្ជាក្នុងព្រះពុទ្ធសាសនា ។

៩– ព្រះមហិន្ទត្ថេរ ទៅលង្កាទ្វីប បានសំដែងចូឡហត្ថិបទោប-មសូត្រ ប្រោសព្រះបាទទេវានម្បិយតិស្សៈ ព្រមទាំងជនានុជន ៤ ម៉ឺននាក់ឲ្យតាំងនៅក្នុងត្រៃសរណគមន៍ និងសីល ។

លោកសំដែងសមចិត្តសូត្រ ប្រោសពួកទេវតា, គ្រានោះទេវតាចំនួន ១ អសង្ខេយ្យបានសម្រេចមគ្គផល ។

លោកសំដែង បេតវត្ថុ, វិមានវត្ថុ, សច្ចសំយុត្ត, ស្ត្រី ៥ រយនាក់ មានព្រះនាងអនុឡាជាទេវីជាប្រធាន បានសម្រេចសោតាបត្តិផល ។

អាមាត្យឈ្មោះអរិដ្ឋ ព្រមទាំងបងប្អូន ៥៥ នាក់ ក្រាបបង្គំទូលលាព្រះបាទទេវានម្បិយតិស្ស ចេញបព្វជ្ជាក្នុងសំណាក់ព្រះថេរៈ បានសំរេចព្រះអរហត្តទាំងអស់ ។

តមក, ព្រះបាទទេវានម្បិយតិស្សៈ ទ្រង់បរិច្ចាគព្រះរាជទ្រព្យឲ្យសាង

ព្រះស្តូប ហើយអារាធនាសុមនសាមណេរជាក្មួយព្រះមហិន្ទត្ថេរ ឲ្យទៅ
ស្វែងរកព្រះសារីរិកធាតុយកមកបញ្ចុះក្នុងព្រះស្តូប សំរាប់ធ្វើសក្ការបូជា
ស្រេចហើយព្រះមហិន្ទត្ថេរនិមន្តទៅគង់នៅមហាមេឃវ័នឧទ្យាន ។

គ្រានោះ, សម្តេចព្រះអនុឡារាជទេវី អគ្គមហេសីនៃព្រះបាទម-
ហានាគជាព្រះមហាឧបរាជនិងជាព្រះអនុជាធិរាជ នៃព្រះបាទទេវានម្បិយ-
តិស្សព្រមដោយស្ត្រីជាបរិវារ ១ ពាន់ មានសេចក្តីជ្រះថ្លា ប្រាថ្នាបួសជា
ភិក្ខុនីក៏សមាទាន សីល ១០ ទ្រង់សំពត់កាសាវពស្ត្រ (ឧទ្ទិសបព្វជ្ជា) ។
ព្រះបាទទេវានម្បិយតិស្សៈ ទ្រង់ជ្រាបហើយ ស្តេចយាងទៅកាន់សំ-
ណាក់ព្រះមហិន្ទត្ថេរ មានព្រះបរមរាជឧង្ការ ត្រាស់រឿងនោះឲ្យព្រះថេរៈ
ជ្រាប ។ ព្រះថេរថ្វាយព្រះពរថា " បើដូច្នោះ សូមព្រះអង្គចាត់រាជបុរស
ឲ្យទៅឯសំណាក់សម្តេចព្រះបិតារបស់អាត្មាភាព (ព្រះបាទធម្មាសោករាជ)
ដែលជាអទិដ្ឋសហាយ របស់ព្រះអង្គ សូមព្រះមហាពោធិព្រឹក្សនឹងនាង
សង្ឃមិត្តាថេរីមកផង ដើម្បីនឹងបានឧបសម្បទពួកឧបាសិកាក្នុងលង្កាទ្វីប
នេះ ។ ព្រះមហាក្សត្រក៏ទ្រង់ចាត់អរិដ្ឋអាមាត្យជាព្រះរាជភាគិនេយ្យឲ្យទៅ
កាន់សំណាក់សំឡាញ់ព្រះអង្គឯក្រុងបាតលីបុត្រ សូមព្រះមហាពោធិព្រឹក្ស
និងព្រះនាងសង្ឃមិត្តាថេរី, ឯមហាមាត្យមុននឹងចេញទៅបានក្រាបបង្គំ
ទូលសុំលាបួសក្នុងពេលដែលត្រឡប់មកដល់វិញ, ព្រះមហាក្សត្រក៏ទ្រង់
ព្រះរាជានុញ្ញាត ។ កាលអាមាត្យទៅដល់ក្រុងបាតលីបុត្រហើយ បាន

ចូលទៅគាល់ព្រះបាទធម្មាសោករាជ ក្រាបបង្គំទូលហេតុការណ៍តាំងតែពីដើម រហូតដល់សូមនិមន្តព្រះមហាពោធិព្រឹក្សនឹងព្រះនាងសង្ឃមិត្តាថេរី ទៅទំនុកបំរុងព្រះពុទ្ធសាសនាក្នុងលង្កាទ្វីប ។ ព្រះរាជាក្រាស់បង្គាប់ឲ្យទៅជួបនឹងព្រះនាងសង្ឃមិត្តាថេរី, កាលទៅដល់ហើយ ក៏ថ្វាយបង្គំទូលពត៌មានសព្វគ្រប់ ព្រះនាងមានសេចក្តីត្រេកអរជាប្រិន ព្រោះជាកិច្ចនាំឲ្យចំរើនព្រះពុទ្ធសាសនា ។ ព្រឹកឡើង, ព្រះនាងក៏និមន្តទៅថ្វាយព្រះពរលាព្រះបរមរាជបិតា ។ ទ្រង់មានព្រះបន្ទូលថា "បើព្រះនាងទៅលង្កាទ្វីប ចូរនិមន្តមែកព្រះមហាពោធិព្រឹក្សទៅផង" ។ ទើបព្រះរាជាទ្រង់ចាត់ការនិមន្តមែកព្រះមហាពោធិព្រឹក្សខាងស្តាំ ប្រតិស្ឋានក្នុងផើងមាស រួចប្រគល់ឲ្យព្រះនាងសង្ឃមិត្តាថេរីនាំចុះសំពៅទៅលង្កាទ្វីប ។ ឯព្រះមហិន្ទត្ថេរ កាលបានជ្រាបថា សំពៅជិតមកដល់ហើយ ក៏ថ្វាយដំណឹងដល់ព្រះបាទទេវានម្បិយតិស្ស: ។ ព្រះអរហន្តទាំងឡាយនឹងព្រះរាជា ព្រមទាំងរាជបរិពារប្រជាជនលង្កាទ្វីប បាននិមន្តនឹងយាងទៅចាំទទួលនៅមាត់កំពង់ជម្ពុកោឡ: ។ កាលព្រះរាជាទតព្រះនេត្រឃើញសំពៅព្រះមហាពោធិព្រឹក្សមកអំពីចម្ងាយហើយ ក៏ទ្រង់មានព្រះបីតិប្រាមោទ្យយ៉ាងក្រៃលែង, លុះសំពៅចូលមកដល់កំពង់ ទ្រង់ក៏ទទួលដោយអភិកមហោឡារ ទាំងមនុស្សទេពតា បាននាំគ្នាធ្វើសក្ការបូជាគឹកកងរំពងនៅមាត់កំពង់, ស្រេចហើយក៏និមន្តចូលមកក្រុងអនុរាធបុរី តាមទិសទក្សិណនៃព្រះនគរ ។ ព្រះ

មហាពោធិព្រឹក្សក៏សំដែងឥទ្ធិបាដិហារ្យផ្សេង ៗ, មានបញ្ចេញឆព្វណ្ណរង្សី ជាដើមអ្នកក្រុងលង្កាទ្វីបប្រមាណ ១ ម៉ឺននាក់ បានឃើញហើយ កើតសេចក្ដីជ្រះថ្លាជឿជាក់ក្នុងព្រះពុទ្ធសាសនា ញ៉ាំងបញ្ញាឲ្យចុះកាន់ព្រះត្រៃ-លក្ខណ៍ បានសំរេចអរហត្តទាំងអស់ ហើយនាំគ្នាចូលបព្វជ្ជាក្នុងសំណាក់ព្រះមហិន្ទត្ថេរ ។ ព្រះបាទទេវានម្បិយតិស្សត្រាស់សួរព្រះមហិន្ទត្ថេរថា "នឹងនិមន្តព្រះមហាពោធិព្រឹក្ស ទៅប្រតិស្ឋានទុកក្នុងតំបន់ណាទើបសម-គួរ ? " ។ ព្រះថេរៈថ្វាយព្រះពរថា "ត្រូវប្រតិស្ឋានខាងទក្ខិណទិសនៃអនុរាធបុរីចម្ងាយ ៥០០ ធ្នូ (៥០០ ព្យាយាម) អំពីទក្ខិណទ្វារ ទីនោះឯងជាបរិភោគចេតិយ៍នៃព្រះសព្វញ្ញុពុទ្ធមុន ៗ " ។ ព្រះរាជាក៏ទ្រង់នាំយកទៅប្រតិស្ឋានទុកក្នុងទីនោះ, តមកមានផលដុះឡើងជាលំដាប់ប្រមាណ ៤០ ដើម ព្រះរាជាទ្រង់នាំយកទៅប្រតិស្ឋានទុកក្នុងទីផ្សេង ៗ មានទីក្បែរមាត់កំពង់ជម្ពូកោឡៈជាដើម ។

ឯសម្ដេចព្រះអនុឡារាជទេវី ព្រមទាំងខត្តិយកញ្ញា នឹងអន្តេបុរិក-កានារី (ស្ដ្រីក្នុងព្រះរាជដំណាក់) បាននាំគ្នាចូលមកបួសក្នុងសំណាក់ព្រះសង្ឃមិត្តាថេរី ប្រមាណ ១ ពាន់នាក់បានសំរេចអរហត្តទាំងអស់ ។

អរិដ្ឋអាមាត្យ ដែលជាព្រះរាជភាគិនេយ្យ ព្រមទាំងបរិវារ ៥០០ បានចូលបព្វជ្ជាក្នុងសំណាក់ព្រះមហាមហិន្ទត្ថេរ មិនយូរប៉ុន្មានក៏បានសំរេចព្រះអរហត្តទាំងអស់ទៅទៀត ។

ថ្ងៃមួយព្រះបាទទេវានម្បិយតិស្ស ត្រាស់សួរព្រះមហាមហិន្ទត្ថេរថា “ព្រះពុទ្ធសាសនា បានឈ្មោះថាប្រតិស្ឋានទៅស៊ប់សួនក្នុងលង្កាទ្វីបនេះហើយឬនៅឡើយ?” ។ ព្រះថេរៈថ្វាយព្រះពរថា “ព្រះរតនត្រ័យ គឺព្រះពុទ្ធព្រះធម៌ព្រះសង្ឃ មានបរិបូណ៌ហើយ តែឯឫសកែវរបស់ព្រះពុទ្ធ-សាសនាមិនទាន់ចាក់ជាប់ស៊ប់មាំនៅឡើយ, លុះតែពួកកុលបុត្រដែលនៅក្នុងលង្កាទ្វីបនេះ បានចេញទៅបួសសិក្សាព្រះវិន័យចេះចាំស្ទាត់ជំនាញអាចបង្ហាត់បង្រៀនគ្នាទៅទៀតបាននោះ ទើបឫសកែវព្រះពុទ្ធសាសនាឈ្មោះថាចាក់ជាប់មាំមួនឥតកំរើក” ។ កាលទ្រង់ជ្រាបថាព្រះវិន័យជាឫសកែវព្រះពុទ្ធសាសនាដូច្នេះហើយក៏ទ្រង់ប្រារព្ធចាត់ការឲ្យរៀបចំសាងមហាមណ្ឌប ដើម្បីឲ្យព្រះសង្ឃប្រជុំធ្វើសង្គាយនា ដោយទ្រង់មានព្រះបំណងនឹងឲ្យឫសកែវព្រះពុទ្ធសាសនាចាក់ជាប់ក្នុងលង្កាទ្វីប ។

សង្គាយនាគ្រានេះ ធ្វើនូវមហាមណ្ឌប នាថូបារាម ក្រុងអនុរាធបុរី លង្កាទ្វីប ប្រជុំព្រះសង្ឃ៦ម៉ឺន៨ពាន់អង្គ ព្រះមហាមហិន្ទត្ថេរ នឹងព្រះមហាអរិដ្ឋត្ថេរ ជាព្រះរាជភាគិនេយ្យនៃព្រះបាទទេវានម្បិយតិស្សជាប្រធាន ។ ព្រះមហាមហិន្ទត្ថេរជាអ្នកបុច្ឆា ព្រះមហាអរិដ្ឋត្ថេរជាអ្នកវិស្សជ្ជនា; ព្រះបាទទេវានម្បិយតិស្សជាសាសនូបត្ថម្ភក៍, ធ្វើ១០ខែទើបសម្រេច រាប់អំពីពុទ្ធ-បរិនិព្វានមក គន្លងទៅហើយបាន២៣៦ឆ្នាំ, របៀបធ្វើដូចបឋមសង្គាយ-នា ។ សង្គីតិបរិយោសានេ ក្នុងកាលជាទីចប់នៃសង្គីតិកម្ម ហេតុ

អស្ចារ្យទាំងឡាយ មានការក្រើកញាប់ញ័រមហាប្រឹថពីជាដើម បានបង្កើតឡើងព្រមគ្នាជាឧឡារិក ។

## ចប់ ចតុត្ថសង្គីតិ

## បញ្ចមសង្គីតិ

ទេវានម្បិយតិស្សោ លង្កិន្ទោ កាលព្រះបាទទេវានម្បិយតិស្សៈ ជាអគ្គរាជមានអំណាចធំក្នុងលង្កាទ្វីប ទ្រង់ឧបត្ថម្ភទំនុកបំរុងព្រះពុទ្ធសាសនា ដោយសេចក្ដីជ្រះថ្លាយ៉ាងមុតមាំ ដរាបដល់អស់ព្រះជន្មសោយព្រះទិវង្គតទៅ ព្រះបាទឧត្តិយរាជ ជាព្រះរាជអនុជ បានឡើងគ្រងរាជសម្បត្តិក្នុងអនុរាធបុរីតមក ។

កាលចំណោរចេរតមក ព្រះមហាមហិន្ទត្ថេរដល់នូវជរាភាព ក៏រលត់ខន្ធបរិនិព្វានទៅ ព្រះបាទឧត្តិយរាជទ្រង់ចាត់ការធ្វើសរីរៈឈាបនកិច្ចសពព្រះថេរៈ នៅនាថេរៈពុទ្ធមាលកៈ ខាងបាចីនទិសនៃមហាវិហារ ហើយសាងព្រះស្តូបទុកក្នុងទីនោះ, កន្លងមក ១ ឆ្នាំ ព្រះសង្ឃមិត្តាថេរី ក៏រលត់ខន្ធចូលកាន់បរិនិព្វានទៅទៀត ព្រះមហាក្សត្រក៏ទ្រង់ចាត់ការធ្វើសរីរៈឈាបនកិច្ចសពព្រះថេរី ខាងបូព៌ទិសនៃថូបារាម ហើយសាងព្រះចេតិយបញ្ចុះព្រះបរមធាតុទុកក្នុងទីនោះ ។ កាលព្រះបាទឧត្តិយរាជសោយទិវង្គតហើយ, ព្រះបាទមហាសិវៈនឹងព្រះបាទសុរតិស្សៈជាព្រះអនុជ

បានឡើងគ្រងរាជសម្បត្តិជាលំដាប់តមក ៗ ក្នុងសម័យនោះ បានកើតមានចម្លែងដណ្តើមរាជសម្បត្តិ ផ្លាស់ប្តូររាជវង្ស ១ មក រហូតមកដល់រជ្ជ-ម័យព្រះបាទខល្លាតនាគ ជាព្រះអនុជនៃព្រះបាទលជ្ជិកតិស្សៈ, ព្រះរាជាអង្គនេះ ទ្រង់មានព្រះរាជសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាដ៏មុតមាំ ទ្រង់បានសាងព្រះវិហារឈ្មោះ កុរុន្ទបាសកវិហារ ; គ្រប់គ្រងរាជសម្បត្តិបាន ៦ ឆ្នាំ ក៏មានសេនាបតីរបស់ព្រះអង្គម្នាក់ក្បត់បានធ្វើគតព្រះអង្គទៅ ហើយឡើងគ្រងរាជសម្បត្តិតមក ៗ វដ្តគាមណីកុមារ ជាព្រះរាជកនិដ្ឋានៃព្រះបាទខល្លាតនាគ ចាប់សេនាបតីនោះសំឡាប់បង់ហើយឡើងគ្រងរាជសម្បត្តិតទៅទៀត ទើបនឹងបាន ៥ ខែ ក៏មានចម្លែង ៧ នាក់ នឹងបរិវារជាច្រើនបានមកដណ្តើម ព្រះរាជសម្បត្តិបានទៅទៀត ១ ព្រះបាទវដ្តគាមណី ទ្រង់ទប់ទល់មិនឈ្នះ ក៏នាំព្រះនាងអនុឡាទេវីនឹងព្រះនាងសោមទេវី ព្រមទាំងព្រះរាជឱរស គេចចេញអំពីព្រះនគរទៅបំពួនលាក់ព្រះអង្គនៅក្នុងព្រៃជិតតិស្សគិរិវិហារ ដែលព្រះមហាតិស្សត្ថេរគង់នៅ ៗ ព្រះថេរជ្រាបថា ព្រះមហាក្សត្រទ្រង់គេចចេញអំពីភ័យមកលាក់បំពួនព្រះអង្គនៅក្នុងទីនោះ; កាលបិណ្ឌបាតបានមកក៏បែងចំណែកយកទៅថ្វាយរាល់ ៗ ថ្ងៃ, ទ្រង់ពេញព្រះហឫទ័យ ទើបក្នុងកាលខាងក្រោយ ទ្រង់សាងព្រះវិហារមួយថ្វាយជាសង្ឃបរិភោគ; តមក ព្រះថេរបានឲ្យស្តេចទៅគង់សំណាក់នៅនឹងឧបាសកៈឈ្មោះតនសីវៈ ជាឧបដ្ឋាករបស់លោក ព្រះរាជា

ទ្រង់គង់នៅទីនោះអស់រយៈ ១៩ ឆ្នាំ ។ កាលខាងក្រោយ ព្រះបាទវដ្ដ-
គាមណី ទ្រង់មានកំឡាំងរេហ៍ពលច្រើនឡើង ក៏ទ្រង់លើកមកច្បាំងដ-
ណ្ដើមយករាជសម្បត្តិវិញ, ពួកទមិឡក៏បរាជ័យ ទើបទ្រង់បានឡើង
សោយរាជសម្បត្តិ ក្នុងអនុរាធបុរីតមកទៀត, ទ្រង់បានបង្គាប់ឲ្យទម្លាយ
អារាមនិគ្រន្ថតិត្ថិយ ក្នុងដំបន់នោះចេញ ហើយទ្រង់សាងព្រះវិហារពុទ្ធ-
សាសនាជំនួសឡើងវិញ, ទ្រង់សាងអភយគិរីវិហារថ្វាយព្រះមហាតិស្ស-
ត្ថេរ ; កាលសាងស្រេចហើយទ្រង់និមន្តព្រះថេរមកគង់ ព្រោះអាស្រ័យ
ការលឹកដល់ឧបការគុណរបស់ព្រះថេរ ដែលមានលើព្រះអង្គ, ទ្រង់វេរ
ថ្វាយអភយគិរីវិហារនោះចំពោះព្រះសង្ឃ ព្រមទាំងទ្រង់ទំនុកបំរុងផ្គត់ផ្គង់
ព្រះសង្ឃដោយចតុប្បច្ច័យរាល់ ៗ ថ្ងៃ, សូម្បីតែទីដែលទ្រង់បង្គាប់ឲ្យព្រះ
នាងសោមទេវីចុះអំពីរថ កាលគ្រាទ្រង់គេចចេញអំពីពួកទមិឡ ទ្រង់ឲ្យ
សាងអារាម ១ ឡើងដែរ ប្រទាននាមថាសោមារាម ។

ចំណែកយោធារបស់ព្រះអង្គ ៩ នាក់បានសាងអារាមមួយម្នាក់ដែរ គឺ

ឧត្តិយអាមាត្យ សាងទក្ខិណាវិហារ ខាងទិសទក្សិណនៃអនុ-
រាធបុរី ។

មូលវអាមាត្យ សាងមូលវិហារខាងទិសឧត្តរនៃអនុរាធបុរី ។

សាលិយអាមាត្យ សាងសាលិយារាមខាងទិសឧត្តរនៃអនុ-
រាធបុរី ។

បុត្តអាមាត្យ សាងបុត្តារាម ខានចំសេចក្ដីនៃអនុពន្ធបុរី ។ តិស្សអាមាត្យ សាងតិស្សារាម ខានចំសេចក្ដីនៃអនុពន្ធបុរី ។

កាលសាងរួចស្រេចហើយ ក៏វេរថ្វាយព្រះមហាតិស្សត្ថេរ ព្រះថេរក៏ចាត់បញ្ជូនព្រះសង្ឃឲ្យទៅគង់នៅគ្រប់អារាម, ឯអាមាត្យជាម្ចាស់អារាម ក៏នាំគ្នាទំនុកបំរុងព្រះសង្ឃដោយចតុប្បច្ច័យតាមសមគួរជានិរន្តរកាល ។

ក្សិណនោះ ព្រះសង្ឃប៉ែកខាងមហាវិហារពោលតិះដៀលលើកទោស ព្រះតិស្សមហាថេរ ថាជាអ្នកច្រឡុកច្រឡំដោយត្រកូលគ្រហស្ថ នាំគ្នាកំចាត់លោកចេញពីអារាម ។ ព្រះតិស្ស ១ រូបទៀតជាសិស្សចូលខាងអាចារ្យ ឃើញព្រះសង្ឃខាងមហាវិហារ ធ្វើអាការដល់អាចារ្យខ្លួនដូច្នោះក៏ទោមនស្សតូចចិត្តទើបគេចចេញទៅអភយគិរីវិហារ ។ តាំងពីគ្រឹមនោះមក ព្រះសង្ឃបានបែកគ្នាជាពីរពួក គឺពួកមហាវិហារ ១ ពួកអភយគិរីវិហារ ១ ។

ពួកព្រះសង្ឃដែលបរិបូណ៌ដោយបញ្ញា ឃើញព្រឹត្តិការណ៍ដូច្នោះក៏ពិចារណាឃើញថា "អនាគតពួកកុលបុត្រនឹងមានបញ្ញាអប្បអោយចុះទៅពុំមានអ្នកទ្រទ្រង់ពុទ្ធវចនៈដោយមុតមាំឡើយ ព្រះពុទ្ធសាសនាក៏នឹងវៀរពេយសាបសូន្យទៅដោយរហ័ស" ទើបព្រះមហាតិស្សត្ថេរជ្រើសព្រះអរហន្តដែលទ្រទ្រង់ព្រះត្រៃបិដកព្រមទាំងបាលីនិងអដ្ឋកថាបាន ១ ពាន់អង្គប្រជុំគ្នាលើកយកពាក្យរបស់គិក្ខុអលជ្ជីមកពិភាក្សា ណែនាំព្រះសង្ឃឲ្យមាន

សេចក្ដីពេញចិត្តក្នុងការធ្វើសង្គាយនាថា “ម្នាលអាវុសោទាំងឡាយ! សាសនាព្រះបរមគ្រូកន្លងទៅបាន ៤៣៣ ឆ្នាំហើយ មានកើតមន្ទិលសៅហ្មងឡើង ពេលនេះបើយើងទាំងឡាយធ្វេសប្រហែស មិនលើកព្រះត្រៃបិដកឡើងចារដាក់ក្នុងស្លឹករឹតទេ អនាគតទៅព្រះពុទ្ធសាសនាក៏នឹងសាបសូន្យបាត់, ព្រោះមិនមាននរណាទ្រទ្រង់ចាំចប់សព្វគ្រប់បាន បើដូច្នេះត្រូវតែយើងរាល់គ្នាសង្គាយនាព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា រួចហើយចារឹកជាលាយលក្ខអក្សរ ដាក់ក្នុងស្លឹករឹតឡើង ទើបនឹងអាចញ៉ាំងព្រះពុទ្ធសាសនាឲ្យស្ថិតស្ថេររុងរឿងនឹងរីកផ្សាយទៅក្នុងអនាគតកាលបាន ។

ព្រះសង្ឃទាំងអស់កាលពិភាក្សាមូលមតិគ្នា ស្រេចហើយក៏ចូលទៅថ្វាយព្រះពរព្រះបាទវដ្តគាមណីសូមឲ្យព្រះអង្គជួយឧបត្ថម្ភ, ព្រះរាជាទ្រង់ជ្រាបហើយ ក៏ទ្រង់មានព្រះរាជហឫទ័យសោមនស្សត្រេកអរពន់ពេកទ្រង់ថ្វាយព្រះអង្គជាអ្នកឧបត្ថម្ភពេញទីក្នុងការធ្វើសង្គាយនា, ទើបទ្រង់ត្រាស់បង្គាប់ឲ្យវិស្វករបាត់ការកសាងមហាមណ្ឌបឡើង ក្នុងតិស្សមហាវិហារក្រុងអនុរាធបុរី ។

សង្គាយនាគ្រានេះ បានធ្វើនៅតិស្សមហាវិហារក្រុងអនុរាធបុរីលង្កាទ្វីប ប្រជុំការកសង្ឃជាព្រះអរហន្ត ១០០០ អង្គ មានព្រះពុទ្ធទត្តថេរនឹងព្រះមហាតិស្សត្ថេរជាប្រធាន ។ ព្រះពុទ្ធទត្តថេរជាអ្នកបុច្ឆា ព្រះមហាតិស្សត្ថេរជាអ្នកវិស្សជ្ជនាបិដកទាំងបី, ព្រះបាទវដ្តគាមណី ទ្រង់ជា

សាសនូបត្ថម្ភ, ធ្វើ១ឆ្នាំទើបសំរេច រាប់អំពីពុទ្ធបរិនិព្វានមក កន្លងទៅហើយបាន ២៣៣ ឆ្នាំ ។ សង្គីតិបរិយោសានេ ក្នុងកាលជាទីសម្រេចនៃសង្គីតិកម្ម ហេតុអស្ចារ្យទាំងឡាយមានកំរើកញាប់ញ័រមហាប្រថពីជាដើម បានបង្កើតឡើងព្រមហើយ ។ កាលសង្គាយនា រួចស្រេចហើយ លោកបានចារឹកព្រះពុទ្ធវចនៈ ទាំងបាលីនិងអដ្ឋកថាជាតួអក្សរដាក់ក្នុងស្លឹករឹត, នេះជាគ្រាដំបូង ដែលប្រើអក្សរជាគ្រឿងចារឹកព្រះពុទ្ធវចនៈ ។ សង្គាយនានេះទីងហៅថា “បោត្ថការុឡ្ហសង្គីតិ” ក៏បាន ព្រោះជាសង្គាយនាឡើងកាន់ក្បួនឬ គម្ពីរ ៗ

## បប់បញ្ចមសង្គីតិ

ព្រះពុទ្ធសាសនាក្នុងកំឡុងសតវត្សទី ១០ (ព. ស.) ពុទ្ធស្ស ភគវតោ បរិនិព្វានតោ រាប់អំពីឆ្នាំដែលព្រះបរមគ្រូបរិនិព្វានកន្លងទៅហើយបាន ៩៥៦ ឆ្នាំ ។ ក្នុងសម័យនោះមានព្រាហ្មណ៍មាណពម្នាក់ កើតក្នុងត្រកូលព្រាហ្មណ៍ រៀនចេះចប់ទូវត្រៃវេទជាអ្នកមានបញ្ញា ឈ្លាសវៃក្លៀវក្លាក្នុងសិល្បវិទ្យាគ្រប់ប្រភេទ អាចគ្របសង្កត់អ្នកប្រាជ្ញរាជបណ្ឌិតទាំងឡាយក្នុងជម្ពូទ្វីបទាំងមូល ដោយសំដីវោហារដ៏ឈ្លាសប្រតិភាពរបស់ខ្លួន មាណពនោះឈ្មោះ “ឃោសរ:” នៅក្នុងជម្ពូទ្វីបមជ្ឈិមប្រទេសជិតពោធិមណ្ឌល ៗ តមកខាងក្រោយដោយមានបំណងចង់

បេះពុទ្ធសាសនាទៀ ទើបចូលបព្វជ្ជាក្នុងព្រះពុទ្ធសាសនា នៅក្នុងសំណាក ព្រះរេវតត្ថេរជាមហាខីណាស្រពបដិសម្ភិទា, ព្រះរេវតត្ថេរបានបង្រៀនពុទ្ធវចនៈទាំងអស់ ៗ ឃោសភិក្ខុ ជាអ្នកមានប្រាជ្ញាសិក្សាព្រះពុទ្ធវចនៈ បានបេះចាំច្រើនយ៉ាងឆាប់រហ័ស ត្រៀសត្វាសក្នុងការសំដែងធម៌ដកបដល់ល្បីនាមទៅក្នុងលោកថា "ពុទ្ធឃោសៈ"; លោកបានរចនាបករណ៍ ១ ឈ្មោះញាណោទយៈ ហើយប្រារព្ធនឹងធ្វើអដ្ឋកថាព្រះអភិធម្មសង្គណីទៀត ៗ

ក្បែណនោះ, ព្រះរេវតត្ថេរជាព្រះឧបជ្ឈាយ៍ឃើញថាព្រះពុទ្ធឃោសៈ មានប្រាជ្ញាល្មមនឹងរចនាប្រែអដ្ឋកថាជាសីហឡភាសាមកជាមគធភាសាបាន ក៏មានថេរវាចាថា "ម្នាលអាវុសោពុទ្ធឃោសៈក្នុងជម្ពូទ្វីបនេះ មានព្រះត្រៃបិដកជាបាលីសុទ្ធតែប៉ុណ្ណោះ ឯអដ្ឋកថានឹងថេរវាទពុំទាន់មាននៅឡើយ, អដ្ឋកថាដែលព្រះថេរទាំងឡាយ មានព្រះសារីបុត្តជាដើមបានធ្វើមកហើយ ៗ ដែលបានឡើងកាន់មហាសង្គីតិបីលើកមកហើយនោះព្រះមហិន្ទត្ថេរ បានធ្វើជាសីហឡភាសា មាននៅក្នុងសីហឡទ្វីបឯណោះមិនអាចញុំាងប្រយោជន៍ឲ្យកើតឡើងយ៉ាងធំទូលាយដល់សត្វលោកបាន ចូរលោកទៅសីហឡទ្វីប ពិចារណាមើលអដ្ឋកថាទាំងអស់ ហើយប្រែមកជាមគធភាសា អដ្ឋកថា ដែលលោកប្រែហើយនោះ នឹងនាំមកនូវប្រយោជន៍ធំដល់សត្វលោក" ៗ ឯវំ វុត្តេ អាយស្មា ពុទ្ធឃោសោ

ព្រះពុទ្ធឃោសៈដ៏មានអាយុ កាលបើបានព្យាករបញ្ហាយ៉ាងនេះហើយក៏មានបីតិសោមនស្សកើតឡើងក្រៃពេក ទើបថ្វាយបង្គំលាព្រះឧបជ្ឈាយ៍ទាំងភិក្ខុសង្ឃនិមន្តទៅកាន់កំពង់ឡើងគង់លើសំពៅឆ្លងមហាសមុទ្រទៅឡើងនៅកំពង់ផែលង្កាទ្វីប ។ ព្រះមហាក្សត្រ ដែលគ្រងរាជសម្បត្តិនៅលង្កាទ្វីបក្នុងសម័យនោះ គឺព្រះបាទមហានាម ។ កាលព្រះពុទ្ធឃោសៈនិមន្តដល់លង្កាទ្វីបហើយ ក៏បានចូលទៅកាន់សំណាក់ព្រះសង្ឃបាលត្ថេរ ក្នុងមហាបធានឃរៈ នាវត្តមហាវិហារ ក្រុងអនុរាធបុរី, និយាយសុំគម្ពីរទាំងព្រះសង្ឃ ដើម្បីធ្វើអដ្ឋកថា ព្រះត្រៃបិដក ។

អថខោ ភិក្ខុសង្ឃា លំដាប់នោះព្រះសង្ឃទាំងអស់ បានលើកយកគាថាត្រៃសិក្ខាដែលសំដែង អំពីសីល សមាធិ បញ្ញា ជាគោលព្រះពុទ្ធសាសនាដែលព្រះសាស្តាដោះស្រាយប្រស្នាទេវតា មកឲ្យលោកអធិប្បាយ ដើម្បីពិសោធ មើលសមត្ថភាពរបស់លោកសិនថាតើអាចធ្វើកើតឬមិនកើត ។ ព្រះពុទ្ធឃោសៈ បានយកគាថានោះទៅ ដកស្រង់សេចក្តីសង្ខេបពីក្នុងគម្ពីរផ្សេងៗ មករៀបរៀងអធិប្បាយពង្រីកសេចក្តីដោយច្បាស់លាស់ចារចុះក្នុងស្លឹករឹតជាគម្ពីរមួយ ឲ្យឈ្មោះថា "វិសុទ្ធិមគ្គ" ប្រែថា "ផ្លូវនៃសេចក្តីបរិសុទ្ធ" លុះធ្វើរួចហើយ ក៏បានយកទៅប្រគេន ព្រះសង្ឃទាំងនោះមានព្រះសង្ឃបាលត្ថេរជាប្រធាន ព្រះសង្ឃទាំងអស់បានប្រជុំគ្នាអានគម្ពីរនោះ ឥតឃើញគក់ទាស់ត្រង់ណាសោះ ក៏ស្ញើច

សរសើរត្រូវៗ អន្ត ប្រគេនពរសព្ទសាធុការកងរំពងហើយប្រកាសថា៖ "ភិក្ខុអង្គនេះ ប្រាកដជាតួអង្គព្រះអរិយមេត្រីពោធិសត្វមកជួយយកលោកសាសនា" ។

តតោ មហាពជា តំ សុត្វា លំដាប់នោះព្រះមហាក្សត្រទ្រង់ព្រះសវនាការដំណឹងនោះហើយ ក៏ទ្រង់យាងទៅមហាវិហារមួយអន្លើដោយរាជបរិស័ទជាច្រើន មានសេចក្តីជ្រះថ្លា អស្ចារ្យក្នុងព្រះហឫទ័យទ្រង់អារាធនាបវារណាព្រះពុទ្ធឃោសៈ ឲ្យទទួលចង្ហាន់បិណ្ឌបាត ក្នុងព្រះរាជដំណាក់នឹងទ្រង់ថ្វាយព្រះអង្គជាឧបដ្ឋាក ត្រាតែសម្រេចកិច្ចប្រែគម្ពីរ ។ ឯព្រះសង្ឃ ក៏បានយកគម្ពីរ ព្រះត្រៃបិដកបាលីសុទ្ធ ព្រមទាំងអដ្ឋកថាមកប្រគល់ដល់លោកតាមត្រូវការ ។ ព្រះពុទ្ធឃោសៈ បានទទួលយកគម្ពីរទាំងនោះហើយ ក៏និមន្តទៅគង់ធ្វើការ នៅលើ មហាប្រាសាទឈ្មោះ "បធានឃរៈ" នៅទក្ខិណភាគនៃមហាវិហារ ។

សីហលដ្ឋកថា តិវិធា ហោតិ អដ្ឋកថាជាភាសាសីហលមាន៣ប្រការគឺ៖ មហាអដ្ឋកថា១ បច្ចរិយដ្ឋកថា១ កុរុន្ទដ្ឋកថា១ ។

មហាអដ្ឋកថា គឺអដ្ឋកថា ដែលបានឡើងកាន់មហាសង្គីតិហើយ ដែលព្រះមហិន្ទត្ថេរបាននាំយកទៅធ្វើជាសីហឡភាសា ។ បច្ចរិយដ្ឋកថា គឺអដ្ឋកថាដែលព្រះអដ្ឋកថាចារ្យគង់ធ្វើនៅលើក្បូន ។

កុរុន្ទដ្ឋកថា គឺអដ្ឋកថា ដែលព្រះអដ្ឋកថាចារ្យ ធ្វើក្នុងកុរុន្ទវេឡុ-វិហារ ។ ឯថេរវាទ សំដៅយកពាក្យ ដែលព្រះថេរទាំងឡាយក្នុងកាលមុនៗ លោកកំណត់យកតាមន័យនៃបាលី ហើយធ្វើឡើង ។

មុនដំបូង, ព្រះពុទ្ធឃោសៈ បានប្រែកុរុន្ទដ្ឋកថា ផ្នែកវិនយបិដកអំពីសីហលភាសា, តាំងជាអដ្ឋកថានៃព្រះវិន័យ ឈ្មោះ "សមន្តបាសាទិ-កា" ដោយបកពាក្យភាសាដែលជាមូលភាសា បន្ទាប់អំពីនេះទៅ លោកប្រែមហាអដ្ឋកថា ផ្នែកសុត្តន្តបិដក, តាំងជាអដ្ឋកថានៃព្រះសូត្រមានឈ្មោះដូច្នេះគឺ៖

សុមង្គលវិលាសិនី អដ្ឋកថា ទីឃនិកាយ ។

បបញ្ចសូទនី អដ្ឋកថា មជ្ឈិមនិកាយ ។

សារត្ថប្បកាសិនី អដ្ឋកថា សំយុត្តនិកាយ ។

មនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ ។

បរមត្ថជោតិកា អដ្ឋកថា ខុទ្ទកនិកាយ ។

បន្ទាប់អំពីនេះទៅទៀត លោកប្រែបច្ចរិយដ្ឋកថាផ្នែកអភិធម្មបិដក, តាំងជាអដ្ឋកថានៃព្រះអភិធម្មមានឈ្មោះដូច្នេះគឺ

អដ្ឋសាលិនី អដ្ឋកថា ធម្មសង្គណីប្បករណ៍

សម្មោហវិនោទនី អដ្ឋកថា វិភង្គប្បករណ៍

បរមត្ថទីបនី អដ្ឋកថា បញ្ចប្បករណ៍

ព្រះពុទ្ធឃោសៈដ៏មានអាយុ បានប្រែអដ្ឋកថាព្រះត្រៃបិដក អំពីសីហលមកជាមគធភាសាដែលជាមូលភាសាដោយប្រការដូច្នេះឯង អដ្ឋកថានោះ បាននាំនូវប្រយោជន៍ដ៏ធំដល់សត្វលោកទាំងអស់ ។ ធ្វើការនេះចំនួនមួយឆ្នាំ ទើបសម្រេច ។

បិដកត្តយដ្ឋកថាយ បរិវត្តនាវសានេ បថវីកម្បោ អហោសិ ក្នុងកាលជាទីសម្រេចនៃការប្រែគម្ពីរអដ្ឋកថា ព្រះត្រៃបិដកនេះ មហាប្រឹថពី បានកំរើកញាប់ញ័រខ្ទរខ្ទារឡើងហើយ ។

គ្រាណោះ ព្រះពុទ្ធឃោសៈដ៏មានអាយុ កាលសំរេចកិច្ចហើយ ក៏ថ្វាយបង្គំលាព្រះសង្ឃក្នុងមហាវិហារ នាំយកគម្ពីរអដ្ឋកថាទាំងអស់ ត្រឡប់មកកាន់ជម្ពូទ្វីបវិញ ។ ការប្រែគម្ពីរអដ្ឋកថា ព្រះត្រៃបិដកពុទ្ធវចនៈ អំពីសីហលភាសាមកជាមគធភាសា នៃព្រះពុទ្ធឃោសាចារ្យនេះលោកចាត់ទុកថាជាសង្គីតិកម្មមួយដែរ ហៅថា "ឆដ្ឋមសង្គីតិ" គឺសង្គាយនាគ្រាទី ៦ ។

## វប្បវម្មព្រះពុទ្ធវចនៈទាំងអស់

ព្រះពុទ្ធវចនៈទាំងអស់ បើរាប់ដោយកិច្ចមានតែមួយយ៉ាង, ដោយធម៌និងវិន័យមាន ២ យ៉ាង, ដោយវចនៈនិងបិដក មាន ៣ យ៉ាង, ដោយនិកាយមាន ៥ យ៉ាង, ដោយអង្គមាន ៩ យ៉ាង, ដោយធម្មក្ខន្ធ មាន ៨៤០០០ ។ ព្រះពុទ្ធវចនៈ ដែលរាប់ដោយកិច្ចមានតែមួយយ៉ាងនោះដូច្នេះ

គឺព្រះពុទ្ធវចនៈទាំងអស់ដែលព្រះបរមសាស្ដា ទ្រង់សំដែងប្រោសមនុស្ស ទេវតា នាគ យក្ស ជាដើមតាំងពីពេលដែលព្រះអង្គបានត្រាស់ដឹង ដរាបដល់ទ្រង់រំលត់ខន្ធយានចូលកាន់ អនុបាទិសេសនិព្វាន ចំនួន ៤៥ ព្រះវស្សានោះ រួមមកមានកិច្ច ឬរសតែម្យ៉ាង ហៅថាវិមុត្តិរស ។

ដែលពោលដោយធម៌និងវិន័យមាន ២ យ៉ាងនោះគឺៈ ព្រះពុទ្ធវចនៈរបស់ព្រះបរមសាស្ដាទាំងអស់ រួមមកមានត្រឹមតែ២ផ្នែក គឺធម៌១ វិន័យ១ ។ ព្រះវិន័យបិដកទាំងមូលហៅថាវិន័យ, ព្រះសុត្តន្តបិដកនិងព្រះអភិធម្មបិដក ហៅថា ធម៌ ។ ព្រោះហេតុនោះ បានជាកាលផ្ដើមធ្វើបឋមសង្គាយនា ព្រះមហាកស្សបត្ថេរ មានថេរវាចាណែនាំព្រះសង្ឃថា "យន្នូន មយំ អាវុសោ ធម្មញ្ច វិនយញ្ច សង្គាយេយ្យាមៈ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ មានតែយើងរាល់គ្នា សង្គាយនាផ្ទៀងផ្ទាត់ធម៌និងវិន័យឡើង" ។ សូម្បីព្រះពុទ្ធដីកាដែលទ្រង់ផ្ដាំព្រះអានន្ទក្នុងកាលជៀបនឹងបរិនិព្វាន ក៏សំដៅត្រឹមតែពាក្យពីរម៉ាត់នេះដែរថា "យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថាៈ ម្នាលអានន្ទ! ធម៌ឯណាដែលតថាគតបានសំដែងហើយក្ដី វិន័យឯណាដែលតថាគតបានបញ្ញត្តហើយក្ដី ធម៌និងវិន័យនោះ លុះឥតអំពីតថាគតទៅ នឹងជាសាស្ដារបស់អ្នកទាំងឡាយ តាងអង្គតថាគត" ។

ដែលពោលដោយវចនៈ មាន៣ នោះគឺ បឋមពុទ្ធវចនៈ១ មជ្ឈិមពុទ្ធវចនៈ១ បច្ឆិមពុទ្ធវចនៈ១ ។ ព្រះពុទ្ធដីកា ដែលទ្រង់បន្លឺឡើងជាដំបូង ដៀលក្នុះគណ្ហាក្នុងកាលទើបទ្រង់បានត្រាស់ សំដៅយកខុទានគាថា ថា "អនេកជាតិសំសារំ ។ បេ ។ តណ្ហានំ ខយមជ្ឈគា" ហៅថា បឋមពុទ្ធវចនៈ ។ ព្រះពុទ្ធដីកា ដែលទ្រង់មានព្រះបន្ទូលចុងក្រោយបំផុត សំដៅយកព្រះវាចាដែលទ្រង់ផ្តាំភិក្ខុទាំងឡាយក្នុងកាលទៀបនឹងបរិនិព្វានថា "ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ ម្នាលភិក្ខុទាំងឡាយ ! ឥឡូវនេះ តថាគតដាស់តឿនអ្នកទាំងអស់គ្នា សង្ខារទាំងឡាយដែលបច្ច័យតាក់តែងមកមានកិរិយាសាបសូន្យទៅជាធម្មតា អ្នកទាំងឡាយចូរញុំាងកិច្ចទាំងពួងដែលជាប្រយោជន៍របស់ខ្លួន និងប្រយោជន៍របស់បុគ្គលដទៃឲ្យសម្រេចដោយសេចក្តីមិនប្រមាទចុះណា ! នេះហៅថាបច្ឆិមពុទ្ធវចនៈ ។ ឯមជ្ឈិមពុទ្ធវចនៈ សំដៅយកព្រះពុទ្ធដីកាទាំងអស់ដែលទ្រង់សំដែងក្នុងចន្លោះកណ្តាលបឋមពុទ្ធវចនៈ និងបច្ឆិមពុទ្ធវចនៈទាំងពីរនេះ ។

ដែលពោលដោយបិដកមាន៣ នោះគឺ វិន័យបិដក១ សុត្តន្តបិដក១ អភិធម្មបិដក១ រួមទាំង៣ ហៅថាព្រះត្រៃបិដក ។ បាដិមោក្ខ ២ គឺភិក្ខុបាតិមោក្ខ ១ ភិក្ខុនីបាតិមោក្ខ១, វិភង្គ ២ គឺ ភិក្ខុវិភង្គ ១ ភិក្ខុនីវិភង្គ ១ ខន្ធក២២ មានមហាខន្ធកជាដើម; វារៈ ១៦ មានកត្តបញ្ញត្តិវារៈជាដើម

ដែលព្រះធម្មសង្គាហកត្ថេរទាំងឡាយលោកប្រជុំទុកក្នុងបឋមសង្គីតិ ហៅជាវិន័យបិដក ។

ព្រះពុទ្ធវចនៈក្នុងនិកាយទាំង ៥ គឺៈ ទីឃនិកាយ ៣៤ សូត្រមានព្រហ្មជាលសូត្រជាដើម ១ សំយុត្តនិកាយ ៧៧៦២ សូត្រមានឱឃតរណសូត្រ ជាដើម ១ អង្គុត្តរនិកាយ ៩៥៥៧ សូត្រមានចិត្តបរិយាទានសូត្រជាដើម ១ ខុទ្ទកនិកាយ ១៥ ប្រភេទ មានខុទ្ទកបាឋជាដើម ១ ហៅជាសុត្តន្តបិដក ។

ព្រះពុទ្ធវចនៈនៅក្នុងគម្ពីរទាំង ៧ គឺធម្មសង្គណី, វិភង្គ, ធាតុកថា, បុគ្គលបញ្ញត្តិ, កថាវត្ថុ, យមក, បដ្ឋាន, ហៅថា អភិធម្មបិដក ។

ព្រះពុទ្ធវចនៈ ដែលពោលដោយនិកាយ ៥ គឺៈ ទីឃនិកាយ ១ មជ្ឈិមនិកាយ ១ សំយុត្តនិកាយ ១ អង្គុត្តរនិកាយ ១ ខុទ្ទកនិកាយ ១ ។

ដែលពោលដោយអង្គមាន ៩ នោះគឺ សុត្តៈ ១ គេយ្យៈ ១ វេយ្យាករណៈ ១ គាថា ១ ឧទានៈ ១ ឥតិវុត្តកៈ ១ ជាតកៈ ១ អព្ភូតធម្មៈ ១ វេទល្លៈ ១ ។ សុត្តៈ នោះលោកសង្គ្រោះយកឧភតោវិភង្គ, និទ្ទេស, ខន្ធកៈ ទឹងបរិវារៈជាដើមផង, ពួកសូត្រក្នុងសុត្តនិបាតមានមង្គលសូត្រ, រតនសូត្រ, នាលកសូត្រ, តុវដ្ដកសូត្រជាដើមផង ទឹងបានដល់ពុទ្ធវចនៈដទៃដែលមានឈ្មោះថា សុត្តន្តៈផង ។ គេយ្យៈ បានដល់សូត្រដែលប្រកបដោយគាថាទាំងអស់ ហើយនឹងសគាថកវគ្គទាំងអស់ក្នុងសំយុត្តនិកាយ ។

វេយ្យាករណៈ បានដល់អភិធម្មបិដកទាំងសូត្រដែលមិនលាយដោយគាថា ហើយទាំងពុទ្ធវចនៈដទៃ ដែលមិនបានសង្គ្រោះចូលក្នុងអង្គ៨ ក្រៅនេះផង ៗ គាថា បានដល់ធម្មបទ ថេរគាថា, ថេរីគាថា ទាំងពាក្យដែលជាគាថាសុទ្ធ ហើយមិនមានឈ្មោះថាសូត្រក្នុងសុត្តនិបាតផង ៗ ឧទានៈ បានដល់សូត្រ ៨២ ដែលប្រកបដោយគាថាអស្រ័យសោមនស្សញ្ញាណ ៗ ឥតិវុត្តកៈ សំដៅយកសូត្រ ១១០ ដែលពួកព្រះសាវកសំដែងអាងដល់ព្រះពុទ្ធដីកាជាបន្ទាល់ថា: "វុត្តំ ហេតំ ភគវតា សមដូចជាពាក្យនេះ ដែលព្រះដ៏មានព្រះភាគត្រាស់សំដែងហើយ" យ៉ាងនេះជាដើម ៗ ជាតកៈ សំដៅយកជាតក ៥៥០ មានអបណ្ណកជាតកជាដើម ៗ អព្ភូតធម្មៈ បានដល់ព្រះសូត្រទាំងអស់ ដែលប្រកបដោយ អច្ឆរិយព្ភូត-ធម៌ ដូចសូត្រដែលមានបាលីថា:- ចត្តារោ មេ ភិក្ខវេ អច្ឆរិយា អព្ភូតធម្មា អានន្ទេ ម្នាលភិក្ខុទាំងឡាយ! ធម៌មិនដែលកើតហើយកើតឡើងបាន ដែលគួរអស្ចារ្យ ៤ ប្រការនេះ រមែងមានក្នុងអានន្ទ" យ៉ាងនេះជាដើម ៗ វេទល្លៈ សំដៅយកពួកសូត្រដែលមានបុគ្គលសួរហើយបានបេះដឹង បានសេចក្ដីជ្រះថ្លារីករាយ មានចូឡវេទល្លសូត្រជាដើម ៗ ព្រះពុទ្ធវចនៈ ដែលពោលដោយអង្គមាន ៩ យ៉ាងដូច្នេះឯង ៗ

ព្រះពុទ្ធវចនៈទាំងអស់ ដែលពោលដោយធម្មក្ខន្ធមាន ៨៤០០០ ព្រះធម្មក្ខន្ធនោះដូច្នេះ បើក្នុងព្រះសូត្រ, សូត្រណាដែលមានអនុសន្ធិ ១

ចាត់ជាធម្មក្ខន្ធ ១ សូត្រណាដែលមានអនុសន្ធិច្រើន ត្រូវរាប់យកអនុសន្ធិមួយ ៗ ក្នុងសូត្រនោះ ចាត់ជាធម្មក្ខន្ធមួយ ១; ក្នុងគាថាពន្ធ ពាក្យសួរបញ្ហា ចាត់ជាធម្មក្ខន្ធ ១ ពាក្យឆ្លើយក៏ចាត់ជាធម្មក្ខន្ធ ១ ដែរ ៗ ឯក្នុងព្រះអភិធម្ម ផ្នែកតិកៈ ទុកៈ មួយ ១ ឬផ្នែកចិត្តវារៈ មួយ ១ ចាត់ជាធម្មក្ខន្ធមួយ ១ ៗ ក្នុងព្រះវិន័យមានរឿង មានមាតិកា មានបទភាជនីយ មានអន្តរាបត្តិ មានអាបត្តិ មានអនាបត្តិ មានតិកច្ឆេទ (កំណត់តិកៈ) ក្នុងរឿងមួយ ១ ត្រូវចាត់ជាធម្មក្ខន្ធមួយ ១ មាតិកាមួយ ១ ចាត់ជាធម្មក្ខន្ធមួយ ១ ដូចគ្នាតទៅ ; ព្រះពុទ្ធវចនៈ ដែលចែកដោយធម្មក្ខន្ធយ៉ាងនេះ រួមទាំងអស់ត្រូវជា ៨៤០០០ ព្រះធម្មក្ខន្ធ សមដូចថេរប្រកាសរបស់ព្រះអានន្ទថា៖

ទ្វាសីតិ ពុទ្ធតោ គណ្ហឹ ទ្វេសហស្សានិ ភិក្ខុតោ
ចតុរាសីតិ សហស្សានិ យេ មេ ធម្មា បវត្តិនោ ។

"ធម៌ទាំងឡាយ ដែលមាននៅក្នុងហឫទ័យរបស់ខ្ញុំចំនួន ៨៤០០០ ធម្មក្ខន្ធនោះ ខ្ញុំបានរៀនផ្ទាល់អំពីសំណាក់ព្រះពុទ្ធអង្គ ៨២០០០ ធម្មក្ខន្ធ, រៀនអំពីសំណាក់ភិក្ខុ ២០០០ ធម្មក្ខន្ធ ៗ

## ចប់សង្គីតិកថា

# តារាងសង្គាយនា

| គ្រាទី | ពុទ្ធសករាជកន្លងបាន | លោកជាប្រធាន | ព្រមដោយព្រះសង្ឃ | ប្រារព្ធហេតុ | ធ្វើត្រង់ទី | ធ្វើអស់វារៈ | សាសនូបត្ថម្ភ |
|---|---|---|---|---|---|---|---|
| ១ | ៣ ខែ | ព្រះមហាកស្សបៈ, ព្រះឧបាលី និងព្រះអានន្ទ | ៥០០ អង្គ | បំពោះពាក្យសុភទ្ទវុឌ្ឍបព្វជិត ពោលពាក្យចំរូងចំរាសក្នុងធម៌វិន័យ កាលដែលដើរផ្លូវមកអំពីក្រុងបាវា ពេលដែលព្រះសាស្តាបរិនិព្វានទៅបាន ៧ ថ្ងៃ ។ | សត្តបណ្ណគុហាទៀបភ្នំវេភារៈជិតក្រុងរាជគ្រឹះ | ៧ ខែ | ព្រះបាទអជាតសត្តុ |
| ២ | ១០០ ឆ្នាំ | ព្រះយសកាកណ្ឌកបុត្រ, ព្រះរេវតត្ថេរ នឹងព្រះសព្វកាមី | ៧០០ អង្គ | ចំពោះពួកវជ្ជីបុត្តកភិក្ខុដែលសំដែងវត្ថុ ១០ ប្រការ ស្មើលវិនយប្បញ្ញត្តិ | វាលុការាមជិតក្រុងវេសាលី | ៨ ខែ | ព្រះបាទកាលាសោក |
| ៣ | ២៣៤ ឆ្នាំ | ព្រះមោគ្គលីបុត្តតិស្សត្ថេរ | ១០០០ អង្គ | បំពោះពួកតិរ្ថិយចូលមកបួសបួមក្នុងគណៈសង្ឃ ហើយសំដែងលិទ្ធរបស់ខ្លួនចូលបួមឲ្យជាហេតុកើតឡើង | អសោការាមជិតក្រុងបាដលីបុត្រ | ៩ ខែ | ព្រះបាទអសោកមហារាជ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤ | ២៣៦ ឆ្នាំ | ព្រះមហិន្ទត្ថេរ នឹងព្រះអរិដ្ឋត្ថេរ | ៦.៨០០០ អង្គ | ដើម្បីឲ្យព្រះពុទ្ធសាសនាឋិតនៅក្នុងលង្កាទ្វីប | ថូបារាម ជិតក្រុងអនុរាធបុរី | ១០ខែ | ព្រះបាទទេវានម្បិយតិស្សៈ |
| ៥ | ៤៣៣ ឆ្នាំ | ព្រះពុទ្ធទត្តត្ថេរ នឹងព្រះតិស្សត្ថេរ | ១០០០ អង្គ | បំពោះពួកភិក្ខុបែកគ្នាជាពីរពួកឲ្យជាហេតុកើតឡើង | តិស្សមហាវិហារ ជិតក្រុងអនុរាធបុរី | ១ ឆ្នាំ | ព្រះបាទវដ្ដគាមណីអភ័យ |

យើងខ្ញុំជាកូន ជ្រា ស៊ីផាត និង ជ្រា សុនដារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ លោកឪពុក **ជា គ្រី** និង អ្នកម្តាយ **កៅ ប៊ុក**

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ គីម វាសនា

កក្កដា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការប្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្មៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

## មានជាវដុំ និង ជាវរាយ

នូវសៀវភៅធម៌គ្រប់មុខគ្រប់ប្រភេទ នៅ

“ បណ្ណាគារត្រៃរតន៍ ” ផ្ទះលេខ ១៣៦អឺ០

វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ទូរស័ព្ទលេខ : ០១២ ៧០៦ ៥៨១

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។